ក្រសួងអប់រំ យុវជន និងកីឡា
Ministry of Education, Youth, and Sport

វិទ្យាស្ថានជាតិអប់រំ
National Institute of Education

# និក្ខេបបទ

# ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅអនុវិទ្យាល័យ ក្នុងខេត្តកណ្ដាល

# THE SITUATION OF TEACHER ALLOCATION AND UTILIZATION AT JUNIOR HIGH SCHOOL IN KANDAL PROVINCE

**ដោយ/By**

**ទុន វណ្ណៈ/TUN VANNAK**

**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់**

**ឯកទេស៖ វិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី៣**

**ឆ្នាំសិក្សា ២០១៩- ២០២០**

ក្រសួងអប់រំ យុវជន និងកីឡា
Ministry of Education, Youth, and Sport

វិទ្យាស្ថានជាតិអប់រំ
National Institute of Education

# និក្ខេបបទ

# ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅអនុវិទ្យាល័យ ក្នុងខេត្តកណ្ដាល

# THE SITUATION OF TEACHER ALLOCATION AND UTILIZATION AT JUNIOR HIGH SCHOOL IN KANDAL PROVINCE

ដោយ/By
**ទុន វណ្ណៈ**
**TUN VANNAK**

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

ឯកទេស៖ វិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី៣

ឆ្នាំសិក្សា ២០១៩-២០២០

សាស្ត្រាចារ្យណែនាំ៖ លោក លឹម វ៉ាន់

# លិខិតបញ្ជាក់ និងទទួលស្គាល់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ:......៥........ វជអ.

## លិខិតបញ្ជាក់ និងទទួលស្គាល់

**នាយកវិទ្យាស្ថានជាតិអប់រំ**

**សូមបញ្ជាក់ និងទទួលស្គាល់ថា៖**

លោក **ទុន ធណ្ណា** និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី៣ ឆ្នាំសិក្សា ២០១៩-២០២០ ពិតជាបានការពារគម្រោងស្រាវជ្រាវ និងសរសេរនិក្ខេបបទ ដែលមានប្រធានបទ "**ស្ថានភាពនៃប្រើប្រាស់គ្រូបង្រៀននៅអនុវិទ្យាល័យក្នុងខេត្តកណ្ដាល**" ស្របតាមលក្ខខណ្ឌកម្មវិធីបណ្ដុះបណ្ដាល ឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ពិតប្រាកដមែន។

ថ្ងៃព្រហស្បតិ៍ ១០រោច ខែបឋមាសាឍ ឆ្នាំជូត ទោស័ក ពុទ្ធសករាជ ២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២០

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុវណ្ណា

# **លិខិតបញ្ជាក់**

**លោក លឹម វ៉ាន់** ជាសាស្ត្រាចារ្យដឹកនាំ

**សូមបញ្ជាក់ និងទទួលស្គាល់ថា**

លោក **ទុន វណ្ណះ** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ «**ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅអនុវិទ្យាល័យក្នុងខេត្តកណ្តាល**» ពិតប្រាកដមែន។

ថ្ងៃ ខែ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ

....................................

**លឹម វ៉ាន់**

# សេចក្ដីអះអាងរបស់បេក្ខជន

ខ្ញុំបាទសូមបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា "**ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅមធ្យមសិក្សាក្នុងខេត្តកណ្ដាល**" សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្រវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ នៅវិទ្យាស្ថានជាតិអប់រំ ពិតជាស្នាដៃស្រាវជ្រាវរបស់ខ្ញុំបាទប្រាកដមែន។ ហើយកន្លងមក ក៏ពុំទាន់មានករណីសិក្សាស្រាវជ្រាវលើប្រធានបទនេះនៅឡើយទេ។ ទ្រឹស្ដីនិងខ្លឹមសារដែលខ្ញុំបាទបានដកស្រង់ ដើម្បីដាក់ជាឯកសារយោង និងបោះពុម្ពជាសាធារណៈ ខ្ញុំបាទបានប្រាប់ពីប្រភព អ្នកនិពន្ធ និងឆ្នាំបោះពុម្ពបានច្បាស់លាស់ដើម្បីធ្វើយ៉ាងណាឲ្យស្នាដៃនៃសារណាបស់ខ្ញុំបាទមានតម្លៃ គុណភាព និងត្រូវបានទទួលស្គាល់ពីគណៈកម្មការវាយតម្លៃ។

ថ្ងៃ ខែ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ

..............................

**ទុន វណ្ណះ**

# លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ :៣៣៤.....ឧជអ. ជក

**លិខិតឧទ្ទេសនាម**

យោង៖ -លិខិតលេខ២៩៥៥ អយក.វជអ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០។
-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី៣ ឆ្នាំសិក្សា២០១៩-២០២០ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៩។

បុគ្គលិកអប់រំនៃវិទ្យាស្ថានជាតិអប់រំដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងឱ្យចូលរួមវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ នៅថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០២០ ចាប់ពីម៉ោង៨:០០នាទី ព្រឹកតទៅ នៅមជ្ឈមណ្ឌលវប្បធម៌ **សម្តេច ហ៊ុន សែន និងលោកជំទាវ៖**

I. **គណៈកម្មការវាយតម្លៃ**

**ក្រុមទី១**

| | | | |
|---|---|---|---|
| ១ | ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា | នាយកវិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២ | លោកបណ្ឌិត នី វង្ហា | ប្រធានការិយាល័យសិក្សា | អនុប្រធាន |
| ៣ | លោក ម៉ៅ សារឿន | ប្រធានដេប៉ាតឺម៉ង់អប់រំ | សមាជិក |
| ៤ | លោកបណ្ឌិត គួយ សុគាន | គ្រូឧទ្ទេស | សមាជិក |
| ៥ | ល.ស នូ ចន្ទី | គ្រូឧទ្ទេស | សមាជិក |
| ៦ | លោក សៀង វាសនា | គ្រូឧទ្ទេស | សមាជិក |

**ក្រុមទី២**

| | | | |
|---|---|---|---|
| ១ | លោកបណ្ឌិត នូវ វីរ៉ា | នាយករងវិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២ | លោក ម៉ន មុនិន្ទ | ប្រធានដេប៉ាតឺម៉ង់ផែនការ | អនុប្រធាន |
| ៣ | លោក ប៉ូ ប៊ុន្នន | អនុប្រធានការិយាល័យសិក្សា | សមាជិក |
| ៤ | លោកបណ្ឌិត ឈាង សង្វាត | គ្រូឧទ្ទេស | សមាជិក |
| ៥ | លោកបណ្ឌិត អាន រ៉ូប្រាវ | គ្រូឧទ្ទេស | សមាជិក |
| ៦ | ល.ស ខែក សំណាង | គ្រូឧទ្ទេស | សមាជិក |

អាសយដ្ឋានលេខ ១២៣ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ (៨៥៥-២៣) ២១៥/៨៨៤ គេហទំព័រ www.nie.edu.kh

II. **លេខាកត់ត្រា** (កត់ត្រាមតិយោបល់គណៈកម្មការវាយតម្លៃ បូកសរុបពិន្ទុ និងបញ្ចូលមធ្យមភាគក្នុងតារាងពិន្ទុ)

**ក្រុមទី១**

| | | | |
|---|---|---|---|
| ១ | លោក ចាប រតនា | អនុប្រធានដេប៉ាតឺម៉ង់ផែនការ | ប្រធាន |
| ២ | លោក លន លីណា | មន្ត្រីដេប៉ាតឺម៉ង់ផែនការ | សមាជិក |
| ៣ | ល.ស សុខ វណ្ណា | មន្ត្រីដេប៉ាតឺម៉ង់ផែនការ | សមាជិក |

**ក្រុមទី២**

| | | | |
|---|---|---|---|
| ១ | លោក ឡុច ចាន់ថន | មន្ត្រីដេប៉ាតឺម៉ង់ផែនការ | ប្រធាន |
| ២ | លោក ចាន់ ធឿន | មន្ត្រីដេប៉ាតឺម៉ង់ផែនការ | សមាជិក |
| ៣ | លោក ម៉ែន សុខសុន្នី | មន្ត្រីដេប៉ាតឺម៉ង់ផែនការ | សមាជិក |

III. **អ្នកសម្របសម្រួល** (រៀបចំលិខិតបទដ្ឋាន ដំណើរការកម្មវិធី និងបូកសរុបរបាយការណ៍)

| | | | |
|---|---|---|---|
| ១ | លោក លឹម វ៉ាន់ | អនុប្រធានដេប៉ាតឺម៉ង់ផែនការ | ប្រធាន |

ថ្ងៃពុធ ៤រោច ខែកត្ដិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុវណ្ណា

**កន្លែងទទួល៖**

- -នាយក នាយករង នាយិការងវេជអ "ដើម្បីជ្រាបជាព័ត៌មាន និងអនុវត្ត"
- -ប្រធានដេប៉ាតឺម៉ង់-ការិយាល័យក្រោមឱវាទវេជអ "ដើម្បីសហការ"
- -សាមីជន "ដើម្បីអនុវត្ត"
- -កាលប្បវត្តិ
- -ឯកសារ៖ ដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការវេជអ

# សេចក្តីថ្លែងអំណរគុណ

ជាបឋមខ្ញុំសូមសំដែងនូវការគោរពដឹងគុណប្រកបដោយកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុត ចំពោះ លោកឪពុក **ទុន សារ៉ន** និង អ្នកម្តាយ **ម៉ែន ចន្ថា** ដែលបានផ្តល់កំណើត និងលះបង់កម្លាំងកាយ កម្លាំងចិត្ត និងធនធានដើម្បីចិញ្ចឹមបីបាច់ និងអប់រំរូបខ្ញុំបាទរហូតដល់មានអ្វីៗសព្វយ៉ាងដូច សព្វថ្ងៃនេះ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តមបណ្ឌិត **សៀង សុវណ្ណា** នាយកវិទ្យាស្ថានជាតិអប់រំ ដែលមានគំនិតខិតខំផ្តួចផ្តើមបើកបណ្តុះបណ្តាលនាយកសាលាមធ្យមសិក្សាទុតិយភូមិនេះឡើង ដើម្បីពង្រឹងគុណភាពគណៈគ្រប់គ្រងសាលាឱ្យសមស្របទៅនឹងស្តង់ដារអាស៊ាន។

សូមថ្លែងអំណរគុណជ្រាលជ្រៅចំពោះ លោកសាស្ត្រាចារ្យ **លឹម ទ៉ាន់** នៃវិទ្យាស្ថានជាតិអប់រំ និងជាគ្រូដឹកនាំក្នុងការសរសេរនិក្ខេបបទនេះ។ កន្លងមកលោកបានយកចិត្តដាក់ផ្តល់យោបល់ និងធ្វើការណែនាំដល់រូបខ្ញុំបាទ នូវមតិយោបល់ល្អៗពីរបៀបរៀបចំកម្រងសំណួរ ការជ្រើសសំណាកដើម្បីធ្វើការសម្ភាសន៍ ជាពិសេសជម្រុញឱ្យយើងខ្ញុំខិតខំប្រឹងប្រែងជម្នះឧបសគ្គដើម្បីសម្រេចបាននូវការបញ្ចប់នៃសរសេរនិក្ខេបបទប្រកបដោយគុណភាពខ្ពស់។

រូបខ្ញុំមិនបំភ្លេចទេសម្រាប់ឧត្តមភរិយារបស់ខ្ញុំ **សន ដានី** ដែលបានជួយទាំងផ្នែកថវិកា និងស្មារតី ជាពិសេសការលើកទឹកចិត្តរបស់គាត់ឱ្យរូបខ្ញុំបាទបានបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិនៅវិទ្យាស្ថានជាតិអប់រំ។

និងសូមថ្លែងអំណរគុណសាស្ត្រាចារ្យទាំងអស់នៃវិទ្យាស្ថានជាតិអប់រំដែលបានខិតខំលះបង់ពេលវេលា ដើម្បីផ្ទេរចំណេះដឹងដល់និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិទាំងគ្រប់រូប។

សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅដល់ថ្នាក់ដឹកនាំក្រសួង និងមន្ទីរអប់រំ យុវជន និងកីឡាខេត្តកណ្តាល ដែលបានលះបង់ពេលវេលាមានតម្លៃ និងកិច្ចសហការដោយរីករាយបំផុត តាមរយៈការផ្តល់ទីកន្លែងសមរម្យ និងផ្តល់ឱកាសអនុញ្ញាតិបាទបានជួបសម្ភាសន៍ និង បានផ្តល់ចម្លើយតាមកម្រងសំណួរដែលបានរៀបចំរួចជាស្រេចដែលការសិក្សាស្រាវជ្រាវនេះទទួលបានជោគជ័យ។

ជាទីបញ្ចប់ ខ្ញុំបាទសូមប្រសិទ្ធពរជ័យដល់ ឯកឧត្តម លោកគ្រូ អ្នកគ្រូ ព្រមទាំងមិត្តរួមជំនាន់ និងជាពិសេស លោកឪពុកអ្នកម្តាយ ភរិយា និងកូនៗជាទីស្រឡាញ់ សូមមានសុខភាពល្អបរិបូរណ៍ កម្លាំងពលំមាំមួន ទទួលបានជោគជ័យគ្រប់ភារកិច្ច ព្រមទាំងទទួលបាននូវពុទ្ធពរទាំង ៤ ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាងឃ្លាតឡើយ។

# មូលន័យសង្ខេប

ការសិក្សាស្រាវជ្រាវនេះ មានគោលបំណងស្វែងឱ្យរកឃើញច្បាស់អំពីស្ថានភាពជាក់ស្តែង និង ប្រសិទ្ធភាពនៃការប្រើប្រាស់គ្រូបង្រៀននៅតាមអនុវិទ្យាល័យនៅនានាក្នុងខេត្តកណ្តាល។ វិធីសាស្រ្តដែល អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់ដើម្បីប្រមូលទិន្នន័យនេះតាមវិធីសាស្រ្ត បែបបរិមាណវិស័យ (Quantitative Method)។ ទិន្នន័យបរិមាណវិស័យត្រូវបានប្រមូលតាមរយៈការបំពេញកម្រងសំណួរ និង ស្ថិតិរបស់សាលារៀន រួចវិភាគតាមបែបស្ថិតិក្នុងកម្មវិធី Excel។ ការស្រាវជ្រាវនេះបានបង្ហាញអំពីលទ្ធផល ៖ ១)ស្ថានភាពនៃការបែងចែក និងប្រើប្រាស់ គ្រូបង្រៀន នៅតាមអនុវិទ្យាល័យនានានាពេលបច្ចុប្បន្នមិន ទាន់មានប្រសិទ្ធភាពនៅឡើយ ពោលគឺសាលាខ្លះលើសគ្រូ ដែលមានគុណវុឌ្ឍិកម្រិតមូលដ្ឋាន និងសាលា ខ្លះបែជាខ្វះគ្រូទៅវិញ ២)ចំនួនសិស្សថ្នាក់មិនទាន់អនុវត្តបានតាមនិយាមដែល កំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា គឺ៤០ទៅ៥០នាក់ក្នុងមួយថ្នាក់ ៣)ការប្រើប្រាស់គ្រូបង្រៀន ខុសជំនាញ ឯកទេស និង ខុសកម្រិតកំពុងត្រូវបានអនុវត្តដើម្បីដោះស្រាយបញ្ហាប្រឈមនៃការខ្វះគ្រូបង្រៀនធ្វើឱ្យគុណភាពនៃការ អប់រំនៅមានកម្រិត។

# តារាងមាតិកា


លិខិតបញ្ជាក់ និងទទួលស្គាល់ ........ i

លិខិតបញ្ជាក់ ........ ii

សេចក្តីអះអាងរបស់បេក្ខជន ........ iii

លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ ........ iv

សេចក្តីថ្លែងអំណរគុណ ........ vi

មូលន័យសង្ខេប ........ viii

តារាងមាតិកា ........ ix

បញ្ជីតារាង ........ xii

បញ្ជីរូបភាព ........ xiii

ជំពូកទី១៖ សេចក្តីផ្តើម ........ 1

១.១.សាវតារ ........ 1

១.២. បញ្ហានៃការស្រាវជ្រាវ ........ 4

១.៣.គោលបំណងនៃការស្រាវជ្រាវ ........ 6

១.៤.សំណួរស្រាវជ្រាវ ........ 6

១.៥.សារៈសំខាន់នៃការស្រាវជ្រាវ ........ 6

១.៦.វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ ........ 7

១.៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ 7

ជំពូកទី២៖ រំលឹកទ្រឹស្តី ........ 9

២.១. និយមន័យ ........ 9

២.២. អភិបាលកិច្ចល្អសាលារៀន ........ 9

២.២.១. តួនាទី និងភារកិច្ចរបស់នាយកសាលារៀន ........ 10

២.២.២. តួនាទី និងការទទួលខុសត្រូវរបស់គ្រូបង្រៀន ........ 12

២.៣. ការគ្រប់គ្រងគ្រូបង្រៀន ........ 13
២.៣.១. ការអនុវត្តនិយាមប្រើប្រាស់បុគ្គលិកអប់រំនៅមធ្យមសិក្សា ........ 14
២.៣.២ ការដោះស្រាយស្ថានភាពលើស ឬខ្វះគ្រូបង្រៀន ........ 19
២.៣.៣ ការផ្លាស់ប្តូរទីកន្លែងធ្វើការរបស់គ្រូបង្រៀន ........ 21
២.៤. កម្មវិធីសិក្សាគោលសម្រាប់អប់រំមូលដ្ឋានចំណេះទូទៅ ........ 22
២.៥. ក្របខណ្ឌកម្មវិធីសិក្សា ........ 23
២.៦. ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ........ 27
២.៧. ក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន ........ 30
២.៨. គោលនយោបាយស្តីពីគ្រូបង្រៀន ........ 33
ជំពូកទី៣៖ វិធីសាស្ត្រស្រាវជ្រាវ ........ 38
៣.១. គម្រោងវិភាគ ........ 38
៣.២. ការប្រមូលទិន្នន័យ ........ 38
៣.៣. ឧបករណ៍ស្រាវជ្រាវ ........ 38
៣.៤. ការជ្រើសរើសភាគសំណាក ........ 39
៣.៥. ការវិភាគទិន្នន័យ ........ 39
ជំពូកទី៤៖ លទ្ធផលនិងការបកស្រាយ ........ 40
៤.១. ការកំណត់ពីតម្រូវការ ........ 40
៤.១.១. ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងបច្ចេកទេសឆ្នាំ២០១៦ និងតាមជាក់ស្តែង ក្នុងខេត្តកណ្តាល ........ 40
៤.១.២. ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែង ក្នុងខេត្តកណ្តាល ........ 41
៤.១.៣. ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិ ក្នុងស្រុកទី១ ........ 43
៤.១.៤. ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិ ក្នុងស្រុកទី២ ........ 46
៤.១.៥. ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិ ក្នុងស្រុកទី៣ ........ 49
៤.១.៦. ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិ ក្នុងស្រុកទី៤ ........ 52
៤.១.៧. ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិ ក្នុងស្រុកទី៥ ........ 55

៤.១.៨. ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិ ក្នុងស្រុកទី៦ ....... 58
៤.១.៩. ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិ ក្នុងស្រុកទី៧....... 61
៤.១.១០. ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិ ក្នុងស្រុកទី៨ .... 63
៤.១.១១. ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិ ក្នុងស្រុកទី៩ .... 66
៤.១.១២. ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិ ក្នុងស្រុកទី១០ 69
៤.១.១២. ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិ ក្នុងស្រុកទី១១ 72
៤.២. ទស្សនៈរបស់នាយកលើការជ្រើសរើសគ្រូ.......................................................75
៤.២.១. ស្ថិតិចំនួនគ្រូទទួលបានតាមការស្នើសុំ ក្នុងរយៈពេល៥ឆ្នាំចុងក្រោយ.............. 75
៤.២.២. បញ្ហាប្រឈម ក្នុងការកំណត់ពីចំនួនគ្រូបង្រៀននៅតាមអនុវិទ្យាល័យ ......... 76
៤.២.៣. ការផ្តល់សំណូមពរចំពោះក្រសួង ក្នុងករណីលើស និងខ្វះ គ្រូ .......................... 76
៥.២. សំណូមពរ .........................................................................................78
ឯកសារយោង...........................................................................................80
ឧបសម្ព័ន្ធ...............................................................................................81

# បញ្ជីតារាង


តារាងទី១៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម ក្របខណ្ឌកម្មវិធីសិក្សាឆ្នាំ ២០១៦ និងតាមជាក់ស្តែង នៅមធ្យមសិក្សាបឋមភូមិ (ខេត្តកណ្តាល)....................40

តារាងទី២៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែង នៅមធ្យមសិក្សាបឋមភូមិ (ខេត្តកណ្តាល)....................42

តារាងទី៣៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែងក្នុងស្រុកទី១....................44

តារាងទី៤៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែងក្នុងស្រុកទី២....................47

តារាងទី៥៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែងក្នុងស្រុកទី៣....................50

តារាងទី៦៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែងក្នុងស្រុកទី៤....................53

តារាងទី៧៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែងក្នុងស្រុកទី៥....................56

តារាងទី៨៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែងក្នុងស្រុកទី៦....................59

តារាងទី៩៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែងក្នុងស្រុកទី៧....................61

តារាងទី១០៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែងក្នុងស្រុកទី៨....................64

តារាងទី១១៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែងក្នុងស្រុកទី៩....................67

តារាងទី១២៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែងក្នុងស្រុកទី១០....................70

តារាងទី១៣៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែងក្នុងស្រុកទី១១....................73

# បញ្ជីរូបភាព

ក្រាបទី១៖ គុណវុឌ្ឍិគ្រូបង្រៀនកម្រិតមូលដ្ឋានតាមមុខវិជ្ជាគិតតាមនិយាម និងតាមតម្រូវការជាក់ស្តែង43
ក្រាបទី២៖ គុណវុឌ្ឍិគ្រូបង្រៀនកម្រិតមូលដ្ឋាននៃមុខវិជ្ជានីមួយៗគិតតាមនិយាម និងតាមតម្រូវការជាក់ស្តែងក្នុងស្រុកទី១ ....45
ក្រាបទី៣៖ តម្រូវការគ្រូបង្រៀនមានគុណវុឌ្ឍិកម្រិតមូលដ្ឋានតាមមុខវិជ្ជានិងតាមអនុវិទ្យាល័យនីមួយៗក្នុងស្រុកទី១....46
ក្រាបទី៤៖ គុណវុឌ្ឍិគ្រូបង្រៀនកម្រិតមូលដ្ឋាននៃមុខវិជ្ជានីមួយៗគិតតាមនិយាម និងតាមតម្រូវការជាក់ស្តែងក្នុងស្រុកទី២ ....48
ក្រាបទី៥៖ តម្រូវការគ្រូបង្រៀនមានគុណវុឌ្ឍិកម្រិតមូលដ្ឋានតាមមុខវិជ្ជានិងតាមអនុវិទ្យាល័យនីមួយៗក្នុងស្រុកទី២ ....49
ក្រាបទី៦៖ គុណវុឌ្ឍិគ្រូបង្រៀនកម្រិតមូលដ្ឋាននៃមុខវិជ្ជានីមួយៗគិតតាមនិយាម និងតាមតម្រូវការជាក់ស្តែងក្នុងស្រុកទី៣....50
ក្រាបទី៧៖ តម្រូវការគ្រូបង្រៀនមានគុណវុឌ្ឍិកម្រិតមូលដ្ឋានតាមមុខវិជ្ជានិងតាមអនុវិទ្យាល័យនីមួយៗក្នុងស្រុកទី៣ .... 51
ក្រាបទី៨៖ គុណវុឌ្ឍិគ្រូបង្រៀនកម្រិតមូលដ្ឋាននៃមុខវិជ្ជានីមួយៗគិតតាមនិយាម និងតាមតម្រូវការជាក់ស្តែងក្នុងស្រុកទី៤ ....54
ក្រាបទី៩៖ តម្រូវការគ្រូបង្រៀនមានគុណវុឌ្ឍិកម្រិតមូលដ្ឋានតាមមុខវិជ្ជានិងតាមអនុវិទ្យាល័យនីមួយៗក្នុងស្រុកទី៤....55
ក្រាបទី១០៖ គុណវុឌ្ឍិគ្រូបង្រៀនកម្រិតមូលដ្ឋាននៃមុខវិជ្ជានីមួយៗគិតតាមនិយាម និងតាមតម្រូវការជាក់ស្តែងក្នុងស្រុកទី៥ ....57
ក្រាបទី១១៖ តម្រូវការគ្រូបង្រៀនមានគុណវុឌ្ឍិកម្រិតមូលដ្ឋានតាមមុខវិជ្ជានិងតាមអនុវិទ្យាល័យនីមួយៗក្នុងស្រុកទី៥....58
ក្រាបទី១២៖ គុណវុឌ្ឍិគ្រូបង្រៀនកម្រិតមូលដ្ឋាននៃមុខវិជ្ជានីមួយៗគិតតាមនិយាម និងតាមតម្រូវការជាក់ស្តែងក្នុងស្រុកទី៦ ....59
ក្រាបទី១៣៖ តម្រូវការគ្រូបង្រៀនមានគុណវុឌ្ឍិកម្រិតមូលដ្ឋានតាមមុខវិជ្ជានិងតាមអនុវិទ្យាល័យនីមួយៗក្នុងស្រុកទី៦....60
ក្រាបទី១៤៖ គុណវុឌ្ឍិគ្រូបង្រៀនកម្រិតមូលដ្ឋាននៃមុខវិជ្ជានីមួយៗគិតតាមនិយាម និងតាមតម្រូវការជាក់ស្តែងក្នុងស្រុកទី៧....62

ក្រាបទី១៥៖ តម្រូវការគ្រូបង្រៀនមានគុណវុឌ្ឍិកម្រិតមូលដ្ឋានតាមមុខវិជ្ជានិងតាមអនុវិទ្យាល័យនីមួយៗ ក្នុងស្រុកទី៧ ........ 63
ក្រាបទី១៦៖ គុណវុឌ្ឍិគ្រូបង្រៀនកម្រិតមូលដ្ឋាននៃមុខវិជ្ជានីមួយៗគិតតាមនិយាម និងតាមតម្រូវការជាក់ស្តែងក្នុងស្រុកទី៨ ........ 65
ក្រាបទី១៧៖ តម្រូវការគ្រូបង្រៀនមានគុណវុឌ្ឍិកម្រិតមូលដ្ឋានតាមមុខវិជ្ជានិងតាមអនុវិទ្យាល័យនីមួយៗ ក្នុងស្រុកទី៨ ........ 66
ក្រាបទី១៨៖ គុណវុឌ្ឍិគ្រូបង្រៀនកម្រិតមូលដ្ឋាននៃមុខវិជ្ជានីមួយៗគិតតាមនិយាម និងតាមតម្រូវការជាក់ស្តែងក្នុងស្រុកទី៩ ........ 68
ក្រាបទី១៩៖ តម្រូវការគ្រូបង្រៀនមានគុណវុឌ្ឍិកម្រិតមូលដ្ឋានតាមមុខវិជ្ជានិងតាមអនុវិទ្យាល័យនីមួយៗ ក្នុងស្រុកទី៩ ........ 69
ក្រាបទី២០៖ គុណវុឌ្ឍិគ្រូបង្រៀនកម្រិតមូលដ្ឋាននៃមុខវិជ្ជានីមួយៗគិតតាមនិយាម និងតាមតម្រូវការជាក់ស្តែងក្នុងស្រុកទី១០ ........ 71
ក្រាបទី២១៖ តម្រូវការគ្រូបង្រៀនមានគុណវុឌ្ឍិកម្រិតមូលដ្ឋានតាមមុខវិជ្ជានិងតាមអនុវិទ្យាល័យនីមួយៗ ក្នុងស្រុកទី១០ ........ 72
ក្រាបទី២២៖ គុណវុឌ្ឍិគ្រូបង្រៀនកម្រិតមូលដ្ឋាននៃមុខវិជ្ជានីមួយៗគិតតាមនិយាម និងតាមតម្រូវការជាក់ស្តែងក្នុងស្រុកទី១១ ........ 74
ក្រាបទី២៣៖ តម្រូវការគ្រូបង្រៀនមានគុណវុឌ្ឍិកម្រិតមូលដ្ឋានតាមមុខវិជ្ជានិងតាមអនុវិទ្យាល័យនីមួយៗ ក្នុងស្រុកទី១១ ........ 75
ក្រាបទី២៤៖ ស្ថិតិចំនួនគ្រូទទួលបានតាមការស្នើសុំ ក្នុងរយៈពេល៥ឆ្នាំចុងក្រោយ ........ 76
ក្រាបទី២៥៖ ករណីខ្វះគ្រូ ........ 77
ក្រាបទី២៦៖ ករណីលើសគ្រូ ........ 77

# ជំពូកទី១៖ សេចក្តីផ្តើម

## ១.១.សាវតារ

កម្ពុជាបានចាប់ផ្តើមកសាងរចនាសម្ព័ន្ធ និងស្ថាប័ននយោបាយ សង្គម និងសេដ្ឋកិច្ចឡើងវិញ បន្ទាប់ពីបានបញ្ចប់ជម្លោះផ្ទៃក្នុង។ ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ វិស័យអប់រំ ក៏ដូចជាវិស័យផ្សេងទៀត ដែរត្រូវបានបំផ្លិចបំផ្លាញដល់កម្រិតសូន្យ ទាំងធនធានមនុស្សទាំងមូលដ្ឋានសម្ភារបរិក្ខារ។ នៅថ្ងៃទី ២៦ ខែមករា ឆ្នាំ ១៩៨០ ក្រសួងអប់រំ យុវជន និងកីឡាត្រូវបានបង្កើតឡើងវិញ សាលារៀនគ្រប់កម្រិតសិក្សា ក្នុងទូទាំងប្រទេសត្រូវបានបើកទ្វារទទួលសិស្សានុសិស្ស។ មន្ទីមនឹងនេះ ការងារបណ្តុះបណ្តាល និងវិក្រឹត ការគ្រូបង្រៀនត្រូវបានចាប់ផ្តើមជាបន្ទាន់ដោយមាននាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការជាអ្នកទទួល ខុសត្រូវ។ ក្នុងស្ថានភាពដ៏លំបាកនេះ ការងារបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀនត្រូវបានចាប់ ផ្តើមពី ការប្រមូលអតីតគ្រូបង្រៀន សិស្ស និស្សិត និងអ្នកមានកម្រិតវប្បធម៌មួយចំនួន ដែលនៅសេសសល់ពីការ កាប់សម្លាប់មកបំប៉នចិត្ត-គរុកោសល្យ និងវិធីសាស្ត្របង្រៀនរយៈពេលខ្លីនៅ តាមសាលាគរុកោសល្យ និង វិក្រឹតការរាជធានី-ខេត្តទាំង១៨ រួចបញ្ជូនទៅកាន់សាលារៀនចំណោះទូទៅក្នុងទូទាំងប្រទេស។ ជាមួយគ្នា នេះដែរ ការបំប៉នមន្ត្រីគ្រប់គ្រងអប់រំ ក៏ត្រូវបានចាប់ផ្តើមផងដែរតាមរយៈការបើកវគ្គបំប៉នប្រមូលផ្តុំនៅ សាលាជាន់ខ្ពស់កម្មាភិបាលគ្រប់គ្រងអប់រំដែលបច្ចុប្បន្នជាវិទ្យាស្ថានជាតិអប់រំ។

ចាប់ពីឆ្នាំ ១៩៨៣ ក្រសួងបានសម្រេចសាលាគរុកោសល្យ និងវិក្រឹតការរាជធានីខេត្តទាំង ១៨ និងសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម បណ្តុះបណ្តាលគ្រូបង្រៀនបឋមសិក្សា និងមត្តេយ្យ សិក្សារយៈពេលវែងដោយ ចាប់ផ្តើមរូបមន្ត 7+1 រហូតដល់ 12+2 សម្រាប់ខេត្តវាលរាប។ ដោយឡែក សម្រាប់ខេត្តភូមិភាគកោះកុង និងតំបន់ដាច់ ស្រយាលមួយចំនួន ការបណ្តុះបណ្តាលគ្រូបឋមសិក្សាត្រូវ បានចាប់ផ្តើមពីរូបមន្ត 3+1 និងបច្ចុប្បន្ន 9+2 និង 12+2។ នៅឆ្នាំ ១៩៨៤ មជ្ឍមណ្ឌលគរុកោសល្យភូមិ ភាគចំនួន ៦ ត្រូវបានបង្កើតឡើងសម្រាប់ បណ្តុះបណ្តាលគ្រូមធ្យមសិក្សាបឋមភូមិដោយផ្តើមពីរូមមន្ត 7+ 3 រហូតបច្ចុប្បន្ន 12 +2។ ដោយឡែកចំពោះការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម បានចាប់ផ្តើម

ពីឆ្នាំសិក្សា 1980-1981 នៅសាលាគរុវិជ្ជាជាន់ខ្ពស់ បច្ចុប្បន្នជាសាកលវិទ្យាល័យភ្នំពេញ ដោយចាប់ផ្ដើមពីការបណ្ដុះបណ្ដាលរយៈពេលខ្លី 4 ខែ 7 ខែ 10 + 3 10 + 4 និងបរិញ្ញា +1 ដែលកំពុងបន្តនៅវិទ្យាស្ថានជាតិអប់រំរហូតដល់បច្ចុប្បន្ន (ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន, ២០១០)។

ប៉ុន្មានឆ្នាំចុងក្រោយនេះ ក្រសួងអប់រំ យុវជន និងកីឡា បាននឹងកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើគុណភាព និងសមត្ថភាព ធនធានមនុស្ស ដើម្បីឆ្លើយតបទៅនឹងសកលភាវូបនីយកម្ម អប់រំទាំងនៅក្នុងតំបន់ និងនៅលើសកលលោក ដោយបានអនុម័តគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តសម្រាប់អភិវឌ្ឍគ្រូបង្រៀន លើកកម្ពស់គុណភាពអប់រំ និងគុណតម្លៃគ្រូបង្រៀន ដូចជាគោលនយោបាយស្តីពីគ្រូបង្រៀនផែនការសកម្មភាពអនុវត្តគោលនយោបាយស្តីពី គ្រូបង្រៀនស្តង់ដានាយកសាលារៀនស្តង់ដាគ្រឹះស្ថានអប់រំគ្រូបង្រៀន គោលនយោបាយស្តីពីការអភិវឌ្ឍវិជ្ជាជីវៈ ជាប្រចាំសម្រាប់បុគ្គលិកអប់រំ ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន កម្មវិធីពន្លឿនឆ្ពោះទៅបរិញ្ញាបត្រដល់គ្រូបង្រៀន (១២+២) និងប្រែក្លាយមជ្ឈមណ្ឌលគរុកោសល្យ ភូមិភាគ និងសាលា គរុកោសល្យ និងរិក្រឹតការរាជធានីភ្នំពេញ និងខេត្តបាត់ដំបង ឱ្យទៅជាវិទ្យាស្ថានគរុកោសល្យសម្រាប់ផ្តល់ការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបរិញ្ញាបត្រ ស្របតាមស្តង់ដាអន្តរជាតិ (ក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន, ២០១៨)។

វិស័យអប់រំមានតួនាទីយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍធនធានមនុស្សឱ្យមានចំណេះដឹង និងសមត្ថភាពសម្បទាគ្រប់គ្រាន់ ជំនាញ ភាពច្នៃប្រឌិត នវានុវត្តន៍ ស្មារតីសហគ្រិនភាព និង ក្រមសីលធម៌ខ្ពស់ ដើម្បីរួមចំណែកលើកកម្ពស់ការអភិវឌ្ឍឧស្សាហកម្ម ដែលជួយបង្កើនកំណើន សេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាប័ន្ន តាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ច ការពង្រឹងភាពប្រកួតប្រជែង និងលើកកម្ពស់ផលិតភាព។ ក្នុងការធានានូវគុណភាព នៃការអប់រំ ឱ្យស្របតាមតម្រូវការ ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញនូវគោលនយោបាយសំខាន់ពីរគឺ គោលនយោបាយទី១៖ ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា និងគោលនយោបាយទី២៖ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់ មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ (យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា២០១៩-២០២៣, ២០១៩)។

ជាមួយគ្នានេះដែរ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ ២០៣០ ស្តីពីការអប់រំនៅកម្ពុជា បានផ្តោតទៅលើគ្រូបង្រៀនកម្ពុជា មានសមត្ថភាព ទទួលបានការលើកទឹកចិត្ត និងទទួលបានការគាំទ្រគ្រប់គ្រាន់ដើម្បីជួយគាំទ្រដល់អ្នកសិក្សាឱ្យទទួលបានការអប់រំប្រកបដោយគុណភាពខ្ពស់។ ប្រព័ន្ធអប់រំកម្ពុជានឹងមានគ្រូបង្រៀនដែលមានសមត្ថភាពវិជ្ជាជីវៈ ទទួលបានការលើកទឹកចិត្ត ទទួលបានការគាំទ្រ និងការបំប៉នចំណេះដឹងមុខវិជ្ជាជំនាញគ្រប់គ្រាន់ ព្រមទាំងជំនាញគរុកោសល្យ និងស្រលាញ់ ការងារបង្រៀន និងសិស្សានុសិស្សរបស់ខ្លួន។ វិជ្ជាជីវៈគ្រូបង្រៀននឹងត្រូវបានលើកកម្ពស់ដើម្បីឱ្យ ការទាក់ទាញ និងរក្សាបាននូវមនុស្សដែលមានគុណវុឌ្ឍខ្ពស់បំផុត និងមានទឹកចិត្តបំពេញការងារ បានល្អ។ គ្រូបង្រៀននឹងទទួលបានការគាំទ្រ ជាប្រចាំ ដើម្បីឱ្យពួកគេអាចអភិវឌ្ឍចំណេះដឹង និង សមត្ថភាពសម្រាប់លើកកម្ពស់ការសិក្សារៀនសូត្ររបស់សិស្ស។ ការបង្រៀន គឺជាវិជ្ជាជីវៈប្រកបដោយក្រមសីលធម៌ ក្នុងនោះ គ្រូបង្រៀនត្រូវបំពេញការងារប្រកបដោយស្តង់ដាវិជ្ជាជីវៈ និងសីលធម៌ខ្ពស់បំផុត ដើម្បីធានាឱ្យសិស្សគ្រប់រូបរបស់ខ្លួនអាចទទួលបានជោគជ័យ (យុទ្ធសាស្រ្តកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា២០១៩-២០២៣, ២០១៩)។

ទន្ទឹមនឹងនេះក្រសួងអប់រំបានធ្វើការកែទម្រង់កម្មវិធីសិក្សាថ្មីដោយ អភិវឌ្ឍក្របខណ្ឌកម្មវិធីសិក្សាសម្រាប់អភិវឌ្ឍកម្មវិធីសិក្សា សៀវភៅសិក្សាគោល និងសម្ភារឧបទេស ដោយមាន ចក្ខុវិស័យៈ ធានាអប់រំពលរដ្ឋ ឱ្យមានលក្ខណសម្បត្តិពេញលេញ ប្រកបដោយភាពរីកចម្រើនគ្រប់ផ្នែក ដោយមានតុល្យភាពរវាងវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា កាយសម្បទា និងមនសិកាស្នេហាជាតិ ដើម្បីអភិវឌ្ឍជាតិ និងធ្វើសមាហរណកម្មកម្ពុជាទៅក្នុងតំបន់ និងពិភពលោក (ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេស, ២០១៦)។ តួអង្គសំខាន់ពីរក្នុងការធានាគុណភាពអប់រំគឺ គ្រូបង្រៀន និងនាយកសាលា។ ប្រសិនបើគ្មានគ្រូបង្រៀនដែលមានសមត្ថភាពខ្ពស់ និងយកចិត្តទុកដាក់ក្នុងការបង្ហាត់បង្រៀននោះទេ កម្ពុជាមិនអាចសម្រេចបានគោលដៅ ក្នុងការផ្តល់សេវាអប់រំប្រកបដោយគុណភាពខ្ពស់ដល់សិស្ស និងនិស្សិត និងទស្សនវិស័យអភិវឌ្ឍន៍កម្ពុជា ជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ ២០៣០ និងប្រទេសមានចំណូលខ្ពស់នៅឆ្នាំ ២០៥០ បានឡើយ (ផែនទីបង្ហាញផ្លូវ ការអប់រំកម្ពុជា ឆ្នាំ២០៣០, ២០១៩)។ គ្រូបង្រៀនខ្លះមានសមត្ថភាព មានមនសិការខ្ពស់ តែគាត់មិនមានចិត្តចង់ធ្វើជានាយកសាលា

រៀនឡើយ ដោយសារតែមានមូលហេតុផ្សេងៗ។ ការមិនសូវគាំទ្រ និងឱ្យតម្លៃពីមជ្ឈដ្ឋានខ្លះដល់វិស័យអប់រំ ក៏ជាមូលហេតុដ៏ធំផងដែរ។ បញ្ហាទាំងអស់នេះកំពុងតែបន្សល់ទុកសម្រាប់ វិស័យអប់រំនាពេលបច្ចុប្បន្នដែលទាមទារឱ្យមានការយកចិត្តទុកដាក់ស្តារ និងអភិវឌ្ឍជាបន្ទាន់។ គ្រូបង្រៀនដែលមានសមត្ថភាពខ្ពស់ និងមានទេពកោសល្យ ក្នុងការបង្ហាត់បង្រៀន គឺជាកត្តាដ៏សំខាន់បំផុត ក្នុងការធ្វើឱ្យសម្រេចបាននូវគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៧)។

ស្របពេលជាមួយគ្នានេះ ក្រសួងអប់រំយុវជន និងកីឡាបានបង្កើតកម្មវិធីវិក្រិត ការជាបន្តបន្ទាប់ដើម្បីលើកកម្ពស់សមត្ថភាពគ្រូបង្រៀន ដែលជាអ្នកផ្តល់ការអប់រំដល់យុវជនជំនាន់ក្រោយឲ្យកាន់តែមានចំណេះដឹង បំណិន និងសីលធម៌ខ្ពស់ ស្របតាមចតុស្តម្ភទាំង ៤ នៃការអប់រំគឺ «រៀនដើម្បីមានចំណេះដឹង រៀនដើម្បីមានចំណេះធ្វើ រៀន ដើម្បីក្លាយជាពលរដ្ឋល្អ និងរៀនដើម្បីចេះរស់នៅជាមួយគ្នា» ព្រមទាំងបណ្តុះបណ្តាល មន្ត្រីគ្រប់គ្រងអប់រំគ្រប់កម្រិត ដើម្បីលើកកម្ពស់អភិបាលកិច្ចល្អនៅក្នុងវិស័យអប់រំ នៅតាមបណ្តាសាលានានាក្នុងទូទាំងប្រទេស។ លើសពីនេះយន្តការធានាគុណភាពអប់រំត្រូវបានរៀបចំ និងកំពុងអនុវត្តជាជំហានៗនូវយន្តការពិនិត្យតាមដាន និងវាយតម្លៃលើលទ្ធផលសិក្សាសិស្ស ក៏ដូចជាការងារគ្រប់គ្រងដឹកនាំនៅតាមគ្រឹះស្ថានសិក្សា ទូទាំងប្រទេសពោលគឺ «ពង្រឹងការធ្វើអធិការកិច្ច»។ ប៉ុន្តែបើទោះបីជាមានការធ្វើវិក្រិតការយ៉ាងដូច្នេះក្តី ក៏សមត្ថភាពអ្នកគ្រប់គ្រងទាំងនោះនៅមានកម្រិត និងពុំទាន់ឆ្លើយតបទៅនឹងការកែទម្រង់របស់ក្រសួងនៅឡើយ ជាហេតុបណ្តាលឱ្យស្ថានភាពនៃការប្រើប្រាស់ និងបែងចែកគ្រូបង្រៀនអាចជួបប្រទះនូវបញ្ហាប្រឈមហើយក៏ជាកត្តាមួយ ដែលធ្វើឱ្យគុណភាពនៃការអប់រំធ្លាក់ចុះផងដែរ។

## ១.២. បញ្ហានៃការស្រាវជ្រាវ

ក្រសួងបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្លា ក្នុងការអនុវត្តវិធានការលើកកម្ពស់គុណភាព និងភាពឆ្លើយតបរបស់សេវាអប់រំពិសេសការលើកកម្ពស់វិជ្ជាជីវៈគ្រូបង្រៀន ការអភិវឌ្ឍសមត្ថភាពនិងការលើកទឹកចិត្តបុគ្គលិក ព្រមទាំងការបង្កើនប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពក្នុងការគ្រប់គ្រងសេវាអប់រំ។ ពីឆ្នាំ ២០១៤

ដល់ ២០១៨ បានបង្ហាញពីដំណាក់កាលការងារដ៏សំខាន់មួយទៀតរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការដាក់ចេញ និងអនុវត្តកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡានៅកម្ពុជា ស្របតាមកំណែទម្រង់នានារបស់រាជរដ្ឋាភិបាល ក្នុងអាណត្តិទី៥តាមរយៈវឌ្ឍនភាពនៃការអនុវត្តវិធានការកំណែទម្រង់ ៨ចំណុច នៅឆ្នាំ២០១៤ និងវឌ្ឍនភាពនៃកំណែទម្រង់ ១៥ ចំណុច ពីឆ្នាំ ២០១៥ ដល់ ២០១៨ (យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា២០១៩-២០២៣, ២០១៩)។

ដោយសារតែការប្រើប្រាស់គ្រូបង្រៀនដែលរួមបញ្ចូលទាំងការពង្រាយ និងផលធៀបគ្រូ-សិស្សមិនទាន់បានអនុវត្តឱ្យបានត្រឹមត្រូវ តាមគោលការណ៍នៅឡើយ ទើបក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញនូវការអនុវត្តគោលនយោបាយស្តីពីគ្រូបង្រៀនក្នុងយុទ្ធសាស្ត្រទី៥៖ ធ្វើសនិទានកម្មគ្រូបង្រៀន ឱ្យឆ្លើយតបទៅនឹងតម្រូវការគ្រឹះស្ថានសិក្សា ក្នុងនោះមានការប្រើប្រាស់មន្ត្រីរាជការឱ្យបានសមស្របតាមនិយាមកំណត់មួយ កែលម្អនិយាមប្រើប្រាស់បុគ្គលិកអប់រំ អនុវត្តនិយាមថ្មីសម្រាប់ប្រើប្រាស់ គ្រូងបង្រៀនថ្មីគ្រប់ភូមិសិក្សាត្រូវមានភារកិច្ចបម្រើការងារនៅតំបន់ដែលខ្វះគ្រូបង្រៀនតាមគោលការណ៍ ជ្រើសរើសពង្រាយ និងរៀបចំភារកិច្ចជូនគ្រូងបង្រៀន ទៅតាមសេចក្តីណែនាំពីការធ្វើប្រតិភូកម្មនិយាមប្រើប្រាស់បុគ្គលិកអប់រំ និងគោលការណ៍ប្រើប្រាស់បុគ្គលិកអប់រំ។

ដូចនេះដើម្បីចូលរួមចំណែកកែលម្អគុណភាពអប់រំនៅកម្ពុជាឲ្យមានការរីកចម្រើនឡើង ខ្ញុំបាទ ជានិស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ នៅវិទ្យាស្ថានជាតិអប់រំ សូមលើកយកប្រធានបទ «ស្ថានភាពនៃប្រើប្រាស់គ្រូបង្រៀននៅអនុវិទ្យាល័យក្នុងខេត្តកណ្តាល» មកសិក្សាស្រាវជ្រាវអំពីចំណុចខ្លាំង ចំណុចខ្សោយ និងបញ្ហាប្រឈមនានាដែលទាក់ទងនឹងការប្រើប្រាស់គ្រូអនុវិទ្យាល័យនៅខេត្តកណ្តាល ដើម្បីបំពេញលក្ខខណ្ឌក្នុងកម្មវិធីបណ្តុះបណ្តាលនិស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិនៅវិទ្យាស្ថានជាតិអប់រំ។

## ១.៣.គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ មានគោលបំណង៖

1. រកឱ្យឃើញពីចំណុចខ្សោយ និងបញ្ហាប្រឈមនានាក្នុងការប្រើប្រាស់គ្រូបង្រៀន នៅតាមអនុវិទ្យាល័យ ក្នុងខេត្តកណ្តាល។
2. រកឱ្យឃើញអំពីប្រសិទ្ធភាពក្នុងការបែងចែកគ្រូអនុវិទ្យាល័យទូទាំងខេត្តកណ្តាល ។

## ១.៤.សំណួរស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានគោលបំណងឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវមួយចំនួន ដែលទាក់ទងទៅនឹងប្រធានបទដូចខាងក្រោម៖

1. តើការប្រើប្រាស់គ្រូបង្រៀន នៅអនុវិទ្យាល័យនានា ក្នុងខេត្តកណ្តាល នៅពេលបច្ចុប្បន្ននេះមានស្ថានភាពយ៉ាងដូចម្តេច?
2. តើយុទ្ធសាស្ត្រសមស្របណាខ្លះដែលមានប្រសិទ្ធភាពក្នុងការបែងចែក និងចាត់ចែងគ្រូបង្រៀនលើស ឬខ្វះ?

## ១.៥.សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានសារៈសំខាន់សម្រាប់ មន្ទីរអយក ការិយាល័យអប់រំស្រុក នាយកនាយិកា ឱ្យយកចិត្តទុកដាក់ ចំពោះការបែងចែកគ្រូ និងអនុវត្តភារកិច្ចរបស់ខ្លួននៅតាមវិទ្យាល័យនានាឱ្យស្របទៅតាមគោលនយោបាយគ្រប់គ្រងគ្រូបង្រៀន និយាមម៉ោងបង្រៀន សិស្ស/គ្រូ គ្រូ/ថ្នាក់ និងស្របតាមបរិបទខេត្ត និងសាលានីមួយៗ ដើម្បីពង្រឹងគុណភាព និងប្រសិទ្ធភាពអប់រំដោយជម្រុញអនុវិទ្យាល័យនីមួយៗប្រើប្រាស់គ្រូបង្រៀនឱ្យចំគោលដៅ តាមមុខវិជ្ជាឯកទេសដើមនីមួយៗរបស់គ្រូបង្រៀនម្នាក់ៗ ដើម្បីធ្វើឱ្យការបង្រៀន និងការរៀនប្រកបដោយសមត្ថភាព រួមមាន ចំណេះដឹង បំណិន (ចំណេះធ្វើ) និងឥរិយាបថ ដើម្បីសមស្របទៅនឹងបរិបទសកលភាវូបនីយកម្មសព្វថ្ងៃ និងក្នុងប្រទេស ក៏ដូចជាប្រទេសទាំងអស់នៅក្នុងតំបន់អាស៊ាន និងអន្តរជាតិ ដើម្បីចូលរួមចំណែក

កាត់បន្ថយភាពក្រីក្រ របស់រាជរដ្ឋាភិបាលតាមរយៈការចំណាយថវិកាខ្ជះខ្ជាយ ទៅលើបុគ្គលិកអសកម្មមួយចំនួននៅតាមសាលាអនុវិទ្យាល័យនានា។

## ១.៦.វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ

ករណីសិក្សា៖ "ការប្រើប្រាស់គ្រូបង្រៀនកម្រិតមធ្យមសិក្សាបឋមភូមិ ក្នុងក្របខណ្ឌមន្ទីរអប់រំ យុវជន និងកីឡាខេត្តកណ្តាល"។

## ១.៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ បានរៀបចំបែងចែកជា៥ជំពូក មានដូចខាងក្រោម៖

- **ជំពូក១ សេចក្តីផ្តើម៖** ជំពូកទី១ចាប់ផ្តើមជាមួយនឹង សាវតា បញ្ហានៃការស្រាវជ្រាវ វត្ថុបំណងនៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ សារសំខាន់នៃការស្រាវជ្រាវ វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។
- **ជំពូក២ ការរំលឹកទ្រឹស្តី៖** ជំពូកទី២មានបំណងបង្ហាញឯកសារយោងមួយចំនួនរបស់ក្រសួងអប់រំ យុវជន និងកីឡា រួមមាន៖ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ(ESP) ប្រព័ន្ធគ្រប់គ្រងព័ត៌មាន និងស្ថិតិអប់រំ(EMIS) សេចក្តីប្រកាសនិងឯកសារគោលនយោបាយមួយចំនួនពាក់ព័ន្ធការជ្រើសរើស និងការប្រើប្រាស់គ្រូបង្រៀន ការលើកកម្ពស់គុណភាពអប់រំ ស្តង់ដានាយកសាលា។ល។ និងទ្រឹស្តីអប់រំរបស់អ្នកនិពន្ធល្បីៗដោយដកស្រង់យកមតិស្រប មតិផ្ទុយមកធ្វើអំណះអំណាងដើម្បីទាញហេតុផលក្នុងក្របខ័ណ្ឌប្រធានបទនេះ។
- **ជំពូកទី៣ វិធីសាស្ត្រស្រាវជ្រាវ៖** នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវនឹងបង្ហាញនូវដែនកំណត់ និងវិសាលភាព ការជ្រើសរើសសំណាក ឧបករណ៍ស្រាវជ្រាវ កម្រងសំណួរស្រាវជ្រាវ វិធីសាស្ត្រប្រមូលទិន្នន័យ ការវិភាគទិន្នន័យ នីតិវិធីក្រមសីលធម៌ និងបង្ហាញពីទំនាក់ទំនងរវាងចំណុចនីមួយៗ ដែលបានចោទក្នុងចំណោទបញ្ហាទៅនិងប្រធានបទ។

❖ **ជំពូក៤ លទ្ធផល និងការពិភាក្សា៖** ជំពូកនេះពន្យល់ និងវិភាគលើទិន្នន័យជាក់ស្តែងដែលប្រមូលបានមកវិភាគ និងបកស្រាយយ៉ាងលម្អិតដើម្បីរកឱ្យឃើញនូវភាពអវិជ្ជមាន និងបញ្ហាប្រឈមនានា ដែលបានលើកមកចោទសួរទាំងអស់ក្នុងចំណោទបញ្ហាក្នុងជំពូកទី១។ ការសិក្សាលើចំណុចខ្លាំងទាំងអស់ដែលបានអនុវត្តជាក់ស្តែង ថាតើវាដូចគ្នាទៅនឹងទ្រឹស្តីដែរឬទេ គឺធ្វើឡើងក្នុងបំណងវិភាគរកឱ្យឃើញចំណុចខ្វះខាតដើម្បីធ្វើការកែលំអ។ ជាលទ្ធផល អ្នកស្រាវជ្រាវបានកំណត់ និងពិភាក្សាលើបញ្ហាធំៗចំនួនពីរគឺ (១) កំណត់ពីតម្រូវការមានដូចជា ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែង (២) ទស្សនៈរបស់នាយកលើការជ្រើសរើសគ្រូមានដូចជា ស្ថិតិចំនួនគ្រូតាមការស្នើសុំក្នុងរយៈពេល៥ឆ្នាំចុងក្រោយ បញ្ហាប្រឈមក្នុងការកំណត់ចំនួនគ្រូបបង្រៀន និងការផ្តល់សំណូមពរក្នុងករណីខ្វះ និងលើសគ្រូ ។

❖ **ជំពូក៥ សេចក្តីសន្និដ្ឋាន និងសំណូមពរ ៖** ជាចុងបញ្ចប់ជំពូកនេះ នឹងនាំមកនូវការវិភាគព្រមទាំងសំណូមពរមួយចំនួនក្នុងគោលបំណងចូលរួមចំណែក លើកកម្ពស់គុណភាព និងប្រសិទ្ធិភាពក្នុងការធ្វើបំណែងចែកភារកិច្ចបុគ្គលិកនៅតាមវិទ្យាល័យនានាក្នុងខេត្ត កណ្តាលឱ្យកាន់តែប្រសើរឡើង និងដើម្បីបង្កើនសាមគ្គីភាព និងទំនាក់ទំនងល្អថែមទៀតរវាង គណៈគ្រប់គ្រង និងសមាជិកដើម្បីអង្គភាពទាំងមូល។

# ជំពូកទី២៖ រំលឹកទ្រឹស្តី

## ២.១. និយមន័យ

- "ការប្រើប្រាស់" មកពីពាក្យ *ការ* ផ្សំជាមួយពាក្យ *ប្រើប្រាស់* មានន័យថា ការប្រើទាំងសព្វទាំងគ្រប់ ប្រើតាមតែប្រទះ (សម្តេចសង្ឃរាជ ជួន ណាត, ១៩៦៧)។
- *គ្រូ* គឺជាអ្នកធ្ងន់ គឺធ្ងន់ទាំងកាយ ធ្ងន់ទាំងចិត្ត, អ្នកដែលគួរគេគោរព គឺអ្នកបង្ហាត់បង្រៀនចំណេះវិជ្ជាសិល្បសាស្រ្តផ្សេងៗដល់សិស្ស (សម្តេចសង្ឃរាជ ជួន ណាត, ១៩៦៧)។
- *គ្រូបង្រៀន* សំដៅដល់បុគ្គលិកបង្រៀននៃបុគ្គលិកអប់រំនៅគ្រឹះស្ថានសិក្សាសាធារណៈ និងគ្រឹះស្ថានសិក្សាឯកជនដែលមានអាជ្ញាប័ណ្ណអប់រំ (អនុក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន, ២០០៨)។
- *ការប្រើប្រាស់គ្រូបង្រៀន* សំដៅដល់ការរៀបចំ ចាត់ចែង ឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាពតាមគុនវុឌ្ឍិរបស់គ្រូបង្រៀន ស្របទៅតាមតម្រូវការរបស់អង្គភាព។
- *ប្រសិទ្ធភាព* តាមវចនានុក្រមភាសាខ្មែរសម្តេចសង្ឃរាជ ជួន ណាត ពាក្យ *ប្រសិទ្ធ* មានន័យថា ធ្វើឱ្យសម្រេច ធ្វើឱ្យគ្រប់គ្រាន់ ធ្វើឱ្យពូកែ។ ដូចនេះ *ប្រសិទ្ធភាព* សំដៅដល់ការធ្វើឱ្យសម្រេចកិច្ចការអ្វីមួយ ប្រកបដោយភាពពេញលេញ គ្រប់គ្រាន់។
- *ប្រសិទ្ធភាព* សំដៅដល់សមត្ថភាពផលិតលទ្ធផលផ្អែកលើវត្ថុបំណង (គោលនយោបាយស្តីពីធនធានមនុស្សក្នុងវិស័យអប់រំ, ២០១២)។

## ២.២. អភិបាលកិច្ចល្អសាលារៀន

យោងតាមសៀវភៅ (រដ្ឋបាលអប់រំ, ២០១៩) សម្រាប់ការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម(បរិញ្ញា+១) របស់វិទ្យាស្ថានជាតិអប់រំបានសរសេរពីអភិបាលកិច្ចសាលារៀនល្អដូចខាងក្រោម៖

បេសកកម្មរបស់រដ្ឋក្នុងក្រសួងអប់រំយុវជន និងកីឡាត្រូវបានទទួលបន្ទុកដោយសាលារៀនសាធារណៈ (ស្ថាប័នសាធារណៈ) ស្ទើរតែទាំងអស់(ក្រៅពីនេះមានសាលារៀនឯកជនមួយចំនួន)។

សេវាសាធារណៈនៅតាមសាលារៀនទាំងនេះត្រូវតែរៀបចំឲ្យបានល្អរវាងអ្នកផ្តត់ផ្គង់ និងអ្នកទទួលសេវា។ គណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀន មានតួនាទីសំខាន់ក្នុងការអនុវត្តគោលនយោបាយអប់រំជាពិសេស ការជានាឲ្យបាននូវនិរន្តភាពបរិស្ថានសាលារៀនល្អ ការរៀន និងបង្រៀន និងលទ្ធផលសិក្សារបស់សិស្ស។

### ២.២.១. តួនាទី និងភារកិច្ចរបស់នាយកសាលារៀន

នាយកសាលារៀន គឺជាប្រធានអង្គភាព ដែលមានសិទ្ធិ និងអំណាចក្នុងការដឹកនាំ និងគ្រប់គ្រងសាលារៀនទាំងមូលឱ្យប្រព្រឹត្តទៅបានល្អតាមភារកិច្ចកំណត់ ដោយត្រូវទទួលខុសត្រូវរួមចំពោះមុខអង្គភាព និងចំពោះឋានានុក្រមរបស់ខ្លួន។

នាយកសាលារៀនមានតួនាទីសំខាន់បួនយ៉ាង៖

- តួនាទី និងភារកិច្ចជាអ្នករដ្ឋបាល
- តួនាទី និងភារកិច្ចជាទីប្រឹក្សាគរុកោសល្យ
- តួនាទី និងភារកិច្ចជាអ្នកគ្រប់គ្រង
- តួនាទី និងភារកិច្ចជាអ្នកទាក់ទងសង្គម

ក. ក្នុងតួនាទីជាអ្នករដ្ឋបាល នាយកសាលារៀនមានភារកិច្ចជាក់ស្តែង ដូចទៅ៖

- ទទួលខុសត្រូវលើការអនុវត្តគោលនយោបាយអប់រំនីតិកម្មសិក្សា សារាចរ សេចក្តីសម្រេច និងសេចក្តីណែនាំផ្សេងៗរបស់ថ្នាក់លើ។
- ចាត់ចែងការចុះឈ្មោះចូលរៀនរបស់សិស្សការបែងចែកសិស្ស ការបែងចែកសិស្សទៅតាមថ្នាក់ ការគោរពបទបញ្ជាផ្ទៃក្នុង ការឡើងថ្នាក់ ការត្រួតថ្នាក់ និងការប្រឡងនានា។
- បែងចែកភារកិច្ចឲ្យគ្រូបង្រៀនបុគ្គលិកស្របទៅតាមតម្រូវការនិងទៅតាមសមត្ថភាពជំនាញ។
- ការគ្រប់គ្រងគ្រូបង្រៀន និងបុគ្គលិកលើកសំណើតែងតាំងផ្លាស់ប្តូរដំឡើងកាំ លើកសរសើរ ឬដាក់វិន័យតាមនីតិវិធីជាធរមាន។
- រៀបចំបង្កើតគណៈកម្មាធិការ និងក្រុមប្រឹក្សានានារបស់សាលារៀន។

- គ្រប់គ្រងលិខិតស្នាម និងឯកសារគ្រប់ប្រភេទ។
- ធ្វើផែនការ កម្មវិធី សកម្មភាព និងយុទ្ធសាស្ត្រការងាររបស់សាលារៀន។
- តាមដានត្រួតពិនិត្យការអនុវត្តការងារ វាយតម្លៃលទ្ធផល និងរាយការណ៍។

ខ. ក្នុងតួនាទីជាទីប្រឹក្សាគរុកោសល្យ នាយកសាលារៀនមានភារកិច្ចជាក់ស្តែងដូចតទៅៈ

- ទទួលខុសត្រូវលើការផ្សព្វផ្សាយ និងការអនុវត្តកម្មវិធីសិក្សាសៀវភៅសិក្សា និងសេចក្តីណែនាំផ្សេងៗស្តីពីសកម្មភាពបង្រៀន និងរៀន។
- ជួយក្រុមបច្ចេកទេស និងសហការជាមួយអធិការក្នុងការចាត់ចែងសកម្មភាពគរុកោសល្យ ការប្រជុំបច្ចេកទេស ការបើកវគ្គសិក្ខាសាលាបំប៉នផ្សេងៗ ដើម្បីលើកកម្ពស់គុណភាពបង្រៀន និងរៀន។
- ត្រួតពិនិត្យ ការបង្រៀនរបស់គ្រូ និងការរៀនរបស់សិស្ស ឬធ្វើអធិការកិច្ច ដូចអធិការដែរ ប៉ុន្តែពុំមានសិទ្ធិឲ្យពិន្ទុដូចអធិការទេ។
- បូកសរុបវាយតម្លៃការបង្រៀន និងរៀន ការរៀនត្រួតថ្នាក់ ការឡើងថ្នាក់ និងការប្រឡងនានា។

គ. ក្នុងតួនាទីជាអ្នកគ្រប់គ្រង នាយកសាលារៀនមានភារកិច្ចជាក់ស្តែងដូចតទៅៈ

- ទទួលខុសត្រូវលើដំណើរការប្រព្រឹត្តទៅរាល់ថ្ងៃរបស់សាលារៀនក្នុងគ្រប់ផ្នែក និងគ្រប់សកម្មភាព។
- គ្រប់គ្រងការប្រើប្រាស់សម្ភារបរិក្ខារ និងថវិកាសាលារៀន ដោយធានាឲ្យមានលក្ខណៈ ត្រឹមត្រូវ យុត្តិធម៌ និងតម្លាភាព តាមគោលការណ៍អភិបាលកិច្ចល្អ(Good Governance)។
- មធ្យោបាយធ្វើការងារឲ្យបង្រៀន និងបុគ្គលិក។
- ការពារថែរក្សា ជួសជុល និងសាងសង់មូលដ្ឋានហេដ្ឋារចនាសម្ព័ន្ធសាលារៀន។
- យកចិត្តទុកដាក់ដល់ជីវភាពរស់នៅរបស់គ្រូបង្រៀន និងបុគ្គលិក។
- លើកសំណើវិធានការដោះស្រាយក្នុងមានការលំបាកហួសពីសមត្ថភាពសាលារៀន។

ឃ. ក្នុងតួនាទីជាអ្នក ទាក់ទងសង្គម នាយកសាលារៀនមានភារកិច្ចជាក់ស្តែងដូចទៅ៖

- ជាតំណាងអង្គភាព ក្នុងការទាក់ទងជាមួយឋានានុក្រមរបស់ខ្លួន ជាមួយអាជ្ញាធរដែនដី មាតាបិតាសិស្ស គ្រួសារ និងសហគមន៍ ដើម្បីដោះស្រាយរាល់បញ្ហា ក្នុងស្មារតីរួមគ្នាកសាង និងអភិវឌ្ឍសាលារៀនតាមគោលការណ៍ «សាលារៀនផ្សារភ្ជាប់នឹងគ្រួសារ និងសង្គម »។
- ចូលរួមក្នុងសកម្មភាព និងក្នុងការប្រជុំផ្សេងៗដែលទាក់ទងនឹងសាលារៀនដើម្បីជានាគុណភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រងសាលារៀន ចាំបាច់ត្រូវមានការចូលរួម ពីសំណាក់បង្រៀន និងបុគ្គលិកទាំងអស់ក្នុងអង្គភាពតាមគោលការណ៍ «អ្នកគ្រប់គ្រងត្រូវសហការជាមួយអ្នកត្រូវគេគ្រប់គ្រង»។ ការរួមចំណែកនេះស្តែងឡើងជាពិសេសតាមរយៈសកម្មភាពរបស់គ្រូបង្រៀនដែលមានតួនាទី ការទទួលខុសត្រូវខ្ពស់ក្នុងការអប់រំ និងការបង្ហាត់បង្រៀនសិស្ស។

## **២.២.២. តួនាទី និងការទទួលខុសត្រូវរបស់គ្រូបង្រៀន**

គ្រូបង្រៀនមានតួនាទី ៣យ៉ាង៖

1- តួនាទី ជាអ្នកអប់រំ

2- តួនាទីជាអ្នកចំណេះដឹង

3- តួនាទីជាអ្នកណែនាំវិធីរៀនសូត្រ

ក្នុងការអនុវត្តតួនាទីនេះ គ្រូបង្រៀនត្រូវយល់ដឹងពីទស្សនាទានគរុកោសល្យមួយចំនួនដូចជា៖

- មនុស្សមានខួរក្បាល និងមានបញ្ញាសម្រាប់ពិចារណារកហេតុផល រកខុសរកត្រូវ (ប៉ុន្តែសម្រាប់ សត្វមានតែសភាវគតិ)។
- ជាមួយមនុស្សគេប្រើវិធានការអប់រំ (ជាមួយសត្វគេប្រើ វិធីផ្សាំង)។

- ខួរក្បាលមនុស្សមិនមែនជាពាងទឹកដែលត្រូវតែចាក់បំពេញនោះទេ ក្នុងការបង្រៀនគ្រូបង្រៀនគ្រាន់តែជាអ្នកណែនាំប៉ុណ្ណោះ ឯសិស្សគឺជាអ្នកធ្វើសកម្មភាព និងជាអ្នករៀនដោយខ្លួនឯង។
- គោលវិធីសិស្សមជ្ឈមណ្ឌល គឺជាវិធីបង្រៀនដែលផ្អែកលើសកម្មភាពសិស្សជាមូលដ្ឋាន (Child Centered Approach)។

បច្ចុប្បន្ននេះ និន្នាការអប់រំលើសកលលោកគឺបណ្ដុះបណ្ដាលសសរស្ដម្ភទាំងបួន ដែលជាមូលដ្ឋានគ្រឹះនៃការអប់រំ ឬហៅថាគោលដៅទាំងបួននៃការអប់រំ៖

- អប់រំឲ្យមានចំណេះដឹង (Learn to know) និងបានទទួលការគោរពរាប់អានពីសង្គម
- អប់រំឲ្យមានចំណេះធ្វើ (Learn to do) ដើម្បីជួយកែលម្អជីវភាពរស់នៅឲ្យកាន់តែប្រសើរ
- អប់រំឲ្យមានសីលធម៌ (Learn to be) ឲ្យក្លាយជាពលរដ្ឋល្អក្នុងការបម្រើសង្គម
- អប់រំឱ្យចេះរស់នៅជាមួយគ្នា (Learn to live together) ក្នុងភាពថ្លៃថ្នូក្នុងសង្គម

គ្រូបង្រៀនមានការទទួលខុសត្រូវបីយ៉ាង គឺ៖

1) ទទួលខុសត្រូវផ្នែកគរុកោសល្យ ដោយធានាការបង្រៀនឲ្យសម្រេចបានលទ្ធផលល្អ។
2) ទទួលខុសត្រូវផ្នែកចិត្តសាស្រ្ត ដោយជួយសិស្សឲ្យមានការអភិវឌ្ឍលើគ្រប់ផ្នែកស្របទៅតាមដំណាក់កាលលូតលាស់នៃចិត្តសាស្រ្តរបស់មនុស្ស។
3) ទទួលខុសត្រូវផ្នែកសីលធម៌ដោយធ្វើជាគំរូល្អក្នុងការងារ និងក្នុងជីវភាពរស់នៅដើម្បីឲ្យសិស្សរៀនសូត្រតាម។

## ២.៣. ការគ្រប់គ្រងគ្រូបង្រៀន

យោងតាម(សេចក្ដីណែនាំលេខ ៥៣ អយក.សណន, ២០១៩) ស្ដីពីការគ្រប់គ្រងគ្រូបង្រៀន ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវវិធានការដូចខាងក្រោម៖

### ២.៣.១. ការអនុវត្តនិយាមប្រើប្រាស់បុគ្គលិកអប់រំនៅមធ្យមសិក្សា

គ្រឹះស្ថានសិក្សាសាធារណៈត្រូវគ្រប់គ្រង និងបែងចែកភារកិច្ចជូនបុគ្គលិកអប់រំ តាមសេចក្តីណែនាំលេខ ២០ អយក.សណន ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៨ ស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំៈ

- នាយកសាលាមានសេវាបង្រៀន ចំពោះសាលាតូច តិចជាង ឬស្មើ៣ថ្នាក់
- ចំនួនបណ្ណារក្ស ត្រូវគិតតាមស្ថានភាពជាក់ស្តែងរបស់សាលារៀន

– មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវម្ចាស់ការត្រួតពិនិត្យនិងរៀបចំស្វ័យប្រកាសសាលារៀន ដែលមានតម្រូវការស្រូបបង្រៀនតាមប្រភេទក្របខណ្ឌ និងមុខវិជ្ជាជំនាញនឹងត្រូវសហការជាមួយនាយកដ្ឋានបុគ្គលិក ក្នុងការបែងចែកតួលេខក្របខណ្ឌ ឱ្យទៅដល់សាលារៀន ដែលកំពុងខ្វះគ្រូបង្រៀន

– គ្រូបង្រៀនចេញថ្មីគ្រប់ប្រភេទក្របខណ្ឌ ត្រូវបញ្ជូនទៅដល់សាលារៀនគោលដៅ ដែលសាមីខ្លួនបានជ្រើសរើសដោយមិនអនុវត្តការផ្តល់អាទិភាពតាមចំណាត់ថ្នាក់ពិន្ទុប្រឡងចេញទៀតឡើយ

– ធ្វើបច្ចុប្បន្នភាពប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្ស ទាំងនៅថ្នាក់ជាតិ និងរាជធានី ខេត្ត

– ចុះពិនិត្យការអនុវត្តនិយាម (ធៀបជាមួយនឹងស្វ័យប្រកាសរបស់សាលារៀន)

– ក្រសួងនឹងពិនិត្យលទ្ធភាពស្នើគោលការណ៍ចុះឈ្មោះគរុសិស្ស និស្សិតក្នុងប្រព័ន្ធព័ត៌មានវិទ្យារបស់ក្រសួងមុខងារសាធារណៈ និងស្នើសុំគោលការណ៍ផ្តល់ក្របខណ្ឌបណ្តោះអាសន្ន

– ក្រសួងនឹងពិនិត្យស្នើគោលការណ៍ ផ្តល់បៀវត្សមូលដ្ឋានដល់គរុសិស្ស គរុនិស្សិត បន្ទាប់ពីបានប្រឡងជាប់។

#### ២.៣.១.១. ម៉ោងបំពេញការងាររបស់បុគ្គលិកអប់រំ

ក/ ការកំណត់ ម៉ោងបំពេញការងារបុគ្គលិកបង្រៀន

| គ្រឹះស្ថានសិក្សាសាធារណៈ | ម៉ោងបង្រៀន ក្នុងថ្នាក់/សប្តាហ៍ | ម៉ោងគាំទ្រដល់ ការបង្រៀនឱ្យគ្រប់ ៤០ ម៉ោង/សប្តាហ៍ |
|---|---|---|
| មធ្យមសិក្សាបឋមភូមិ | ១៨ ម៉ោង | ២២ ម៉ោង |

| | | |
|---|---|---|
| មធ្យមសិក្សាទុតិយភូមិ | ១៦ ម៉ោង | ២៤ ម៉ោង |

ខ/ ម៉ោងប្រចាំសប្តាហ៍ក្នុងការបង្រៀនក្នុងថ្នាក់ និងការបំពេញភារកិច្ចផ្សេងៗ

| ល.រ | ភារកិច្ចដែលត្រូវបំពេញ | អនុវិទ្យាល័យ | វិទ្យាល័យ |
|---|---|---|---|
| ក | **ម៉ោងកំណត់បង្រៀនសិស្សក្នុងថ្នាក់** | **១៨** | **១៦** |
| | ក.១ បង្រៀនសុទ្ធសាធ | ១៨ | ១៦ |
| | ក.២ បង្រៀន+ទទួលបន្ទុកថ្នាក់ | ១៤ | ១២ |
| | ក.៣ បង្រៀន+ប្រធានក្រុមបច្ចេកទេស | ១៦ | ១៤ |
| | ក.៤ បង្រៀន+ទទួលបន្ទុកថ្នាក់+ប្រធានក្រុមបច្ចេកទេស | ១២ | ១០ |
| ខ | **ម៉ោងគាំទ្រការបង្រៀន** | **២២** | **២៤** |
| គ | **ម៉ោងរបស់គ្រូបន្ទុក** | **៤** | **៤** |
| ឃ | **ម៉ោងរបស់ប្រធានក្រុមបច្ចេកទេស** | **២** | **២** |
| **សរុប** | | **៤០** | **៤០** |

**២.៣.១.២. និយាមប្រើបុគ្គលិកអប់រំ**

ក/ និយាមប្រើបុគ្គលិកបង្រៀន

| គ្រឹះស្ថានសិក្សាសាធារណៈ | និយាមប្រើចំនួនគ្រូ-សិស្ស | |
|---|---|---|
| | និយាមថ្នាក់-គ្រូបង្រៀន | ផលធៀប សិស្ស-ថ្នាក់ |
| មធ្យមសិក្សាបឋមភូមិ | ១/១.៨៣៣ | ៤០-៥០ |
| មធ្យមសិក្សាទុតិយភូមិ | | |
| ថ្នាក់ទី១០ | ១/២.០៦២ | ៤០-៥០ |
| ថ្នាក់ទី ១១-១២ | ១/២.១៨៧ | ៤០-៥០ |

ខ/ និយាមប្រើបុគ្គលិកអប់រំទីចាត់ការ និងបង្រៀន

| តួនាទី និងភារកិច្ច | សាលាតូច | | | សាលាមធ្យម | | សាលាធំ | |
|---|---|---|---|---|---|---|---|
| | ៦ | ៧-១៤ | ១៥-២០ | ២១-២៩ | ៣០-៤០ | ៤១-៦០ | ៦០-៨០+ |
| នាយក | ១ | ១ | ១ | ១ | ១ | ១ | ១ |
| នាយករង | | ១ | ២ | ២ | ២ | ៣ | ៣ |
| លេខាធិការ | ១ | ១ | ១ | ១ | ២ | ២ | ២ |
| បណ្ណារក្ស | | ១ | ២ | ២ | ២ | ៣ | ៣ |
| បេឡា | | | | ១ | ១ | ១ | ១ |
| គណនេយ្យ | | ១ | ១ | ១ | ១ | ២ | ២ |
| អ្នកទទួលបន្ទុកយុវជន | | | ១ | ១ | ១ | ២ | ២ |
| អ្នកទទួយបន្ទុកបន្ទប់ពិសោធន៍(បើមាន) | | ២ | ២ | ៣ | ៣ | ៣ | ៤ |
| បុគ្គលិក ឬឆ្មាំ | | | | | | | ២ |
| **សរុប** | ២ | ៧ | ១០ | ១២ | ១៣ | ១៦ | ១៩ |

### ២.៣.១.៣ ការព្យាករណ៍តម្រូវការគ្រូបង្រៀននៅតាមគ្រឹះស្ថានសិក្សា

– គ្រឹះស្ថានសិក្សានីមួយៗ ត្រូវធ្វើការវិភាគ និងព្យាករណ៍អំពីតម្រូវការធនធានមនុស្សតាមប្រភេទក្របខណ្ឌ និងមុខវិជ្ជាជំនាញឱ្យបានច្បាស់លាស់មុននឹង លើកសំណើសុំគ្រូបង្រៀនបន្ថែមរួមបញ្ចូលទាំងគ្រូបង្រៀនជាប់កិច្ចសន្យា គ្រូបង្រៀនថ្នាក់គួប គ្រូបង្រៀនពីរថ្នាក់ពីរពេល។ល។

– ការវិភាគ និងព្យាករណ៍អំពីតម្រូវការធនធានមនុស្ស ត្រូវអនុលោមតាម សេចក្តីណែនាំលេខ២០ អយក.សណន ស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា និងសេចក្តីណែនាំលេខ៤៩៨ មស.សណន ស្តីពីការប្រើប្រាស់គ្រូបង្រៀនថ្នាក់ពីរវេនគ្រូបង្រៀនថ្នាក់គួប

និងគ្រូបង្រៀនជាប់កិច្ចសន្យា នៅតាមគ្រឹះស្ថាន បឋមសិក្សាសាធារណៈ របស់ក្រសួងមុខងារសាធារណៈ។

- គ្រឹះស្ថានសិក្សានីមួយៗ ត្រូវពិនិត្យអំពីសំណើសុំផ្លាស់ចេញរបស់បុគ្គលិក/គ្រូបង្រៀន ដើម្បីធានាថា ការសុំផ្លាស់ចេញ មិនប៉ះពាល់ដល់សេវាបង្រៀន នៅក្នុងឆ្នាំសិក្សាបច្ចុប្បន្ន និងពេលអនាគត។
- គ្រឹះស្ថានសិក្សានីមួយៗត្រូវពិនិត្យអំពីសំណើសុំផ្លាស់ចូល ឬការដាក់ពាក្យសុំប្រឡងចូល ដើម្បីធានាថា បុគ្គលិក/គ្រូបង្រៀនដែលនឹងត្រូវបញ្ជូនមក នឹងបំពេញនូវតម្រូវការធនធានមនុស្សសម្រាប់ពេលបច្ចុប្បន្ន និងមិននៅសល់ក្នុងពេលអនាគត។

### ២.៣.១.៤ ការរៀបចំផែនការក្របខណ្ឌប្រចាំឆ្នាំ

- អង្គភាពពាក់ព័ន្ធនៅថ្នាក់ជាតិត្រូវសហកាគ្នា ដើម្បីរៀបចំផែនការមេស្តីពីតម្រូវការ និងការផ្គត់ផ្គង់គ្រូបង្រៀនដោយផ្អែកលើចំណោលសិស្ស។
- ប្រមូលផ្តុំទិន្នន័យគ្រូបង្រៀន គ្រូបង្រៀនជាប់កិច្ចសន្យា គ្រូបង្រៀនថ្នាក់ពីរវេន គ្រូបង្រៀនថ្នាក់គួប គ្រូបង្រៀន ចូលនិវត្តន៍ គ្រូបង្រៀនផ្លាស់ចេញពីក្របខណ្ឌ និងមរណជន។
- រៀបចំសំណើសុំក្របខណ្ឌថ្មី គ្រូបង្រៀនជាប់កិច្ចសន្យា គ្រូបង្រៀនថ្នាក់គួប គ្រូបង្រៀនថ្នាក់ពីរវេន ដើម្បីដាក់ជូន ក្រសួងមុខងារសាធារណៈ។
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវអនុវត្តដូចគ្នានឹងចំណុចខាងលើ ដោយសហការជាមួយការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងគ្រឹះស្ថានសិក្សា។

### ២.៣.១.៥ ការជ្រើសរើសបុគ្គលិកចូលក្របខណ្ឌ

- បន្តអនុវត្តវិធានការជ្រើសរើសសាលារៀន នៅមុនពេលដាក់ពាក្យសុំចុះឈ្មោះប្រឡងជ្រើសរើសគ្រូបង្រៀនគ្រប់ប្រភេទក្របខណ្ឌ
- បន្តប្រឡងជ្រើសរើសក្របខណ្ឌថ្មី ទៅតាមប្រភេទក្របខណ្ឌ មុខវិជ្ជាជំនាញ
- ផ្តល់អាទិភាពដល់បេក្ខជនមកពីតំបន់ដាច់ស្រយាល តំបន់ជួបការលំបាក និងបេក្ខជនដែលជ្រើសរើសខេត្ត ដាច់ស្រយាល

- បន្តប្រឡងជ្រើសរើសបញ្ចូលក្របខណ្ឌចំពោះបេក្ខជនមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ និង បណ្ឌិត
- ការជ្រើសរើសគ្រូបន្ថែម គួរផ្តល់អាទិភាពដល់ការដោះស្រាយបញ្ចប់ការប្រើប្រាស់គ្រូថ្នាក់គួបបីកម្រិត ព្រមទាំង កាត់បន្ថយថ្នាក់គួបពីរកម្រិត និងថ្នាក់ពីរវេន
- ការជ្រើសរើសគ្រូថ្មី ជំនួសគ្រូចូលនិវត្តន៍ ជាគោលការណ៍គួរបញ្ឈប់ការផ្តល់ទៅកន្លែងដែលកំពុងលើសស្រាប់
- ការប្រឡងជ្រើសរើសគ្រូក្របខណ្ឌថ្មីគួរពិនិត្យជម្រើសប្រឡងជ្រើសរើសក្នុងចំណោមសិស្សក្នុងខេត្តគោលដៅនោះ ដើម្បីកាត់បន្ថយនិន្នាការនៃការស្នើសុំផ្លាស់ប្តូរទីកន្លែងធ្វើការ
- ការបែងចែកក្របខណ្ឌថ្មី សម្រាប់ការប្រឡងជ្រើសរើស ត្រូវរៀបចំតាមដំណាក់កាលៈ
  - បន្ទាប់ពីទទួលបានតួលេខសម្រាប់ការប្រឡងជ្រើសរើសក្របខណ្ឌប្រចាំឆ្នាំ ក្រសួងត្រូវប្រជុំពិនិត្យ ការបែងចែកតួលេខជាកញ្ចប់ឱ្យទៅដល់រាជធានី ខេត្តនីមួយៗ ទាំងគ្រូបង្រៀនកម្រិតឧត្តម កម្រិតមូលដ្ឋាន និងបឋម-មត្តេយ្យសិក្សាដោយផ្អែកលើស្ថានភាពខ្វះជាក់ស្តែង
  - បន្ទាប់ពីទទួលបានតួលេខរួចហើយ មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្តនីមួយៗត្រូវយកទៅ បែងចែកឱ្យទៅដល់សាលារៀនដែលកំពុងខ្វះជាក់ស្តែងតាមប្រភេទក្របខណ្ឌនិងតាមមុខវិជ្ជាជំនាញ ចំពោះគ្រូបង្រៀនកម្រិតមូលដ្ឋាន និងកម្រិតឧត្តម ដោយបញ្ជាក់ឈ្មោះសាលារៀនដែលមានតម្រូវ ការឱ្យបានច្បាស់ លាស់ និងលើកសំណើមកក្រសួងអប់រំ យុវជន និងកីឡា តាមរយៈនាយកដ្ឋានបុគ្គលិក ដើម្បីសុំការសម្រេច
  - បន្ទាប់ពីទទួលបានសំណើ ស្តីពីតម្រូវការគ្រូបង្រៀនរបស់រាជធានី ខេត្ត ក្រសួងត្រូវរៀបចំប្រជុំលើកទី២ ដើម្បីពិនិត្យនិងសម្រេច ហើយបញ្ជូនត្រឡប់ទៅវិញដើម្បីអនុវត្តសម្រាប់ការប្រឡងជ្រើសរើស។

**២.៣.២ ការដោះស្រាយស្ថានភាពលើស ឬខ្វះគ្រូបង្រៀន**

– ពង្រឹងការអនុវត្តសេចក្តីណែនាំលេខ ២៣ អយក.សណន ចុះថ្ងៃទី ៣ ខែកក្កដា ឆ្នាំ ២០១៧ ស្តីពី ការបែងចែកប៉ុស្តិ៍បម្រើការងាររបស់គ្រូបង្រៀនចេញថ្មី (ប៉ុន្តែគួរមានការកែសម្រួលចំណុចមួយចំនួន ដូចខាងក្រោម)

  - ពង្រឹងដំណើរការរបស់គណៈកម្មការគ្រប់គ្រងបុគ្គលិករាជធានី-ខេត្ត គណៈកម្មការជ្រើសរើសប៉ុស្តិ៍
  - គ្រូបង្រៀនចេញថ្មីដែលមានកិច្ចសន្យា ទៅបម្រើការនៅសាលារៀន ដែលបានជ្រើសរើសត្រូវទៅបម្រើការនៅទីនោះ
  - បញ្ឈប់ការប្តូរប៉ុស្តិ៍គ្នា បន្ទាប់ពីការជ្រើសរើសប៉ុស្តិ៍រួច
  - គ្រូបង្រៀនចេញថ្មី ដែលមិនគោរពតាមលិខិតបង្គាប់ការ ឬលិខិតឧទ្ទេសនាម នឹងត្រូវស្នើផ្អាកបៀវត្ស ឬស្នើលុបឈ្មោះចេញពីក្របខណ្ឌភ្លាម។

**២.៣.២.១ សាលារៀនលើសគ្រូបង្រៀន**

***កណ្ណីរាជធានីភ្នំពេញ***

អនុវត្តសាកល្បងនៅរាជធានីភ្នំពេញដោយមានការពិនិត្យឱ្យបានហ្មត់ចត់តួលេខគ្រូបង្រៀន ដែលមានសេវាបង្រៀនមិនគ្រប់តាមនិយាមកំណត់ និងអាសយដ្ឋានបច្ចុប្បន្នរបស់គ្រូបង្រៀនទាំងអស់នោះ ដើម្បីស្នើពង្រាយទៅសាលារៀនដែលកំពុងខ្វះគ្រូបង្រៀន នៅជិតលំនៅដ្ឋានរបស់ពួកគាត់។

***ករណីខេត្តផ្សេងទៀត***

– បន្តទប់ស្កាត់ការផ្លាស់គ្រូបង្រៀនចូលសាលារៀនដែលលើសគ្រូ

– ស្នើសុំគោលការណ៍បង្កើនប្រាក់ឧបត្ថម្ភម្តងគត់ដល់គ្រូបង្រៀន ដែលស្ម័គ្រចិត្តពង្រាយទៅសាលារៀនដែលកំពុងខ្វះគ្រូ

– សុំគោលការណ៍ផ្តល់ប្រាក់បំណាច់មុខងារពិសេស ដល់គ្រូបង្រៀនដែលកំពុងបង្រៀននៅតំបន់ជួបការលំបាកខ្លាំង។

### ២.៣.២.២ សាលារៀនខ្វះគ្រូបង្រៀន

- ធ្វើវិក្រឹតការគ្រូបង្រៀនកម្រិតបឋមសិក្សា ដើម្បីតាំងស៊ប់ក្នុងក្របខណ្ឌ ជាគ្រូបង្រៀនកម្រិតមូលដ្ឋាន និងត្រូវផ្តល់អាទិភាពឱ្យគ្រូបង្រៀនដែលស្ម័គ្រចិត្តពង្រាយទៅសាលារៀនដែលខ្វះគ្រូ ដោយតម្រូវឱ្យសាមីខ្លួនជ្រើសរើសសាលារៀន និងមុខវិជ្ជាមុននឹងដាក់ពាក្យសុំចុះឈ្មោះ
- ពិភាក្សាជាមួយក្រសួងពាក់ព័ន្ធ ដើម្បីរកលទ្ធភាពបង្កើនប្រាក់ឧបត្ថម្ភម្តងគត់ សម្រាប់ការពង្រាយគ្រូបង្រៀនឆ្លងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់
- ការស្នើបញ្ចូលក្របខណ្ឌ (ទាំងគ្រូក្របខណ្ឌ និងគ្រូបង្រៀនជាប់កិច្ចសន្យា) ត្រូវធ្វើឡើងដោយផ្អែកលើផែនការគ្រប់គ្រងជ្រោយ ច្បាស់លាស់ និងស្របតាមគោលការណ៍កំណត់ ដោយចៀសវាងនូវការស្នើសុំបន្ថែមក្នុងឆ្នាំ ដែលធ្វើឱ្យកិច្ចការនេះប្រព្រឹត្តទៅដោយមិនមានតម្លាភាព និងប្រសិទ្ធភាព។

❖ **ការប្រាស់ប្រាក់ម៉ោងបន្ថែម** *(អនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៧)*

- ម៉ោងបន្ថែមសំដៅដល់ចំនួនម៉ោងដែលគ្រូបង្រៀនបានបង្រៀន និងបំពេញការងារគរុកោសល្យព្រមទាំងការងារពាក់ព័ន្ធនឹងការបង្រៀនលើសពីចំនួនម៉ោងកំណត់៖
  - បង្រៀនអាចបង្រៀនម៉ោងបន្ថែមយ៉ាងច្រើនបំផុត៤៨ម៉ោងក្នុង១ខែ ក្នុងគ្រឹះស្ថានសិក្សាសាធារណៈដែលសាមីជនកំពុងបំពេញការងារឬគ្រឹះស្ថានសិក្សាសាធារណៈផ្សេងទៀត
  - មន្ត្រីរាជការមិនមែនជាគ្រូបង្រៀនអាចបង្រៀនម៉ោងបន្ថែមយ៉ាងច្រើនបំផុត ៣២ ម៉ោងក្នុង ១ ខែ
- គ្រឹះស្ថានសិក្សាសាធារណៈដែលអាចអនុវត្តរបបម៉ោងបន្ថែមបាន លុះត្រាតែ៖
  - បានគ្រោងឥណទានថវិកាសម្រាប់របបម៉ោងបន្ថែម
  - ពុំមានគ្រូបង្រៀនគ្រប់គ្រាន់ ដើម្បីបង្រៀនមុខវិជ្ជាស្របតាមនិយាមកំណត់
  - ត្រូវមានការអនុញ្ញាតជាមុនពីក្រសួងសាមី
  - ប្រើប្រាស់របបម៉ោងបន្ថែមក្នុងរង្វង់ឥណទានថវិកាដែលផ្តល់ឱ្យតែប៉ុណ្ណោះ។

– អ្នកមានសិទ្ធិបង្រៀនម៉ោងបន្ថែម លុះត្រាតែះ

- ជាមន្ត្រីរាជការជាគ្រូបង្រៀន ប្រចាំគ្រឹះស្ថានសិក្សា
- ជាមន្ត្រីរាជការមិនមែនជាគ្រូបង្រៀន ដែលត្រូវបានជ្រើសរើសឬចាត់តាំងឱ្យបង្រៀនក្នុងគ្រឹះស្ថានសិក្សា
- មានលិខិតបង្គាប់ការជាផ្លូវការរបស់គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាអនុញ្ញាតឱ្យបង្រៀនម៉ោងបន្ថែម
- ជាគ្រូបង្រៀនបានអនុវត្តពេញលេញការបង្រៀនតាមរបបម៉ោងកំណត់។

– គ្រឹះស្ថានសិក្សាសាធារណៈ ដែលមានប្រភពចំណូលប្រចាំឆ្នាំផ្ទាល់របស់ខ្លួន ពីការបង់ថ្លៃរបស់សិស្ស សកម្មភាពពាណិជ្ជកម្ម ឬអំណោយផ្សេងៗ សរុបលើសពី ៥០% នៃថវិកាប្រចាំឆ្នាំ មិនត្រូវបានអនុញ្ញាត ឱ្យមានការផ្តល់ប្រាក់ម៉ោងបន្ថែមពីថវិកាជាតិឡើយ។

### ២.៣.៣ ការផ្លាស់ប្តូរទីកន្លែងធ្វើការរបស់គ្រូបង្រៀន

– ទប់ស្កាត់ការផ្លាស់ប្តូរគ្រូបង្រៀនចូលសាលារៀនលើសគ្រូ ទោះបីតាមសហព័ទ្ធក៏ដោយ

– អនុញ្ញាតឱ្យផ្លាស់ប្តូរទីកន្លែងធ្វើការឆ្លងរាជធានី ខេត្ត ប៉ុន្តែសាមីខ្លួនត្រូវជ្រើសរើសសាលារៀនជាមុនសិន ហើយ ត្រូវមានយោបល់យល់ព្រមទទួលពីនាយកសាលារៀន និងមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ដែលត្រូវ ផ្លាស់ចូល ទើបអាចដាក់ពាក្យសុំផ្លាស់ប្តូរបាន

– អនុញ្ញាតឱ្យផ្ទេរក្របខណ្ឌចេញក្រៅក្រសួង ចំនួន ៥០ នាក់ ក្នុង១ឆ្នាំ ដោយមិនគិតការផ្ទេរជាករណីដោយឡែក

– មិនអនុញ្ញាតឱ្យគ្រូបង្រៀនចេញថ្មីគ្រប់ប្រភេទក្របខណ្ឌ ប្តូរគ្រឹះស្ថានសិក្សាដែលសាមីខ្លួនបានជ្រើសរើស

– ការផ្លាស់ប្តូរពីរាជធានី ខេត្ត ចូលអង្គភាពនានាក្រោមឱវាទ ទីស្តីការក្រសួងត្រូវឆ្លងកាត់ការប្រឡង វាស់ស្ទង់សមត្ថភាព និងឆ្លងកាត់ការធ្វើសម្ភាសន៍ដោយផ្ទាល់ពីប្រធានអង្គភាពដែលត្រូវផ្លាស់ចូល។

### ២.៣.៣.១ ការផ្លាស់ប្តូរតាមសហព័ន្ធ

- ត្រូវត្រួតពិនិត្យឯកសារឱ្យបានច្បាស់លាស់ (ចៀសវាងការរៀបការក្លែងក្លាយ)
- អនុញ្ញាតឱ្យផ្លាស់ប្តូរតាមសហព័ន្ធ ចូលក្រោមឱវាទទីស្តីការក្រសួង ប៉ុន្តែមិនអនុញ្ញាតផ្លាស់ចូលក្នុងអង្គភាពតែមួយ
- គ្រូបង្រៀនចេញថ្មីដែលសុំប្តូររាជធានី ខេត្ត តាមសហព័ន្ធជាមន្ត្រីរាជការ អនុញ្ញាតឱ្យប្តូរ បន្ទាប់ពីសាមីខ្លួនបានបញ្ចប់កម្មសិក្សាដោយជោគជ័យ។

## ២.៤. កម្មវិធីសិក្សាគោលសម្រាប់អប់រំមូលដ្ឋានចំណេះទូទៅ

❖ **កម្មវិធីអប់រំកម្រិតមូលដ្ឋាន (ថ្នាក់ទី ៧ ដល់ ៩)**

- អប់រំសិល្បៈបញ្ចូលក្នុងបំណិនជីវិតមូលដ្ឋាន
- ភាសាបរទេសជាមុខវិជ្ជាគោល
- ១ម៉ោងសិក្សាមាន ៥០នាទី
- បំណិនបុរេវិជ្ជាជីវៈបញ្ចូលក្នុងមុខវិជ្ជាសិក្សាសង្គម និងបំណិនជីវិតមូលដ្ឋាន
- នៅដំណាច់ថ្នាក់ទី៩ មានការប្រលងថ្នាក់ជាតិ
- បញ្ចូលកីឡាក្នុងអប់រំកាយ និងសុខភាព

| ល.រ | មុខវិជ្ជា កម្មវិធីសិក្សាជាតិ | ម៉ោងក្នុង១សប្តាហ៍ |
|---|---|---|
| ១ | ភាសាខ្មែរ | ៦ |
| ២ | គណិតវិទ្យា | ៦ |
| ៣ | វិទ្យាសាស្ត្រ | ៦ |
| ៤ | សិក្សាសង្គម | ៦ |
| ៥ | ភាសាបរទេស | ៤ |
| ៦ | អប់រំកាយ សុខភាព និងកីឡា | ២ |
| | សរុបម៉ោងកម្មវិធីសិក្សាជាតិ | ៣០ |
| | បំណិជីវិតតាមមូលដ្ឋាន | ២-៥ |
| **សរុបម៉ោងសិក្សា** | | ៣២-៣៥ |

## ២.៥. ក្របខណ្ឌកម្មវិធីសិក្សា

នៅឆ្នាំ ២០១៦ ជាដំណាក់កាលទី ៥ នៃការធ្វើកំណែទម្រង់កម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា គឺបានអភិវឌ្ឍក្របខណ្ឌកម្មវិធីសិក្សា និងកម្មវិធីសិក្សាថ្មីគ្រប់មុខវិជ្ជា ព្រមទាំងបានបន្ថែមមុខវិជ្ជាមួយចំនួនទៀត។ ក្របខណ្ឌកម្មវិធីសិក្សានេះ បានកែសម្រួលលើទម្រង់មុខវិជ្ជា របាយម៉ោង ខ្លឹមសារ វិធីសាស្ត្រ និងការអនុវត្ត។

ដោយផ្អែកលើសៀវភៅក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេស របស់ក្រសួងអប់រំ យុវជន និងកីឡា បោះពុម្ពឆ្នាំ ២០១៦ បានបង្ហាញនូវខ្លឹមសារសំខាន់ៗដូចខាងក្រោម៖

### ក. ចក្ខុវិស័យនៃក្របខណ្ឌកម្មវិធីសិក្សាឆ្នាំ២០១៦

ក្របខណ្ឌកម្មវិធីសិក្សាអប់រំចំណេះទូទៅ និងអប់រំបច្ចេកទេស គឺជានាអប់រំពលរដ្ឋឱ្យមានលក្ខណៈសម្បត្តិពេញលេញ ប្រកបដោយភាពរីកចម្រើនគ្រប់ផ្នែក ដោយមានតុល្យភាពរវាងវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា កាយសម្បទា និងមនសិការស្នេហាជាតិ និងមនុស្សជាតិ ដើម្បីការអភិវឌ្ឍជាតិ និងការធ្វើសមាហរណកម្មកម្ពុជាទៅក្នុងតំបន់ និងពិភពលោក។

### ខ. គោលបំណងនៃក្របខណ្ឌកម្មវិធីសិក្សាឆ្នាំ២០១៦

*ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស* មានគោលបំណងអភិវឌ្ឍ៖

១- សមត្ថភាពភាសាខ្មែរនិងភាសាបរទេសលើបំណិនទាំងបួន (ការស្តាប់ ការនិយាយ ការអាន និងការសរសេរ) ឱ្យបានច្បាស់លាស់សម្រាប់ប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវ និងការប្រាស្រ័យទាក់ទងក្នុងការរស់នៅប្រចាំថ្ងៃ។

២- ចំណេះដឹងគណិតវិទ្យា វិទ្យាសាស្ត្រ បច្ចេកទេសនិងបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ សម្រាប់ជាមូលដ្ឋានដល់ការបន្តការសិក្សានិងការប្រាស្រ័យទាក់ទងក្នុងការរស់នៅប្រចាំថ្ងៃ។

៣- បំណិនសិល្បៈ សុខភាព កីឡា សោភ័ណភាព នវានុវត្តន៍ សហគ្រិនភាព និងពលរដ្ឋវិជ្ជា សម្រាប់ការប្រើប្រាស់ប្រចាំថ្ងៃក្នុងនាមជាបុគ្គលនិងសមាជិកគ្រួសារ សហគមន៍ និងសង្គម។

៤- បំណិនស្វ័យសិក្សា ស្រាវជ្រាវត្រិះរិះពិចារណា ប្រាស្រ័យទាក់ទង និងដោះស្រាយបញ្ហាក្នុងបរិបទផ្សេងៗ ដោយប្រើប្រាស់ចំណេះដឹងទូលំទូលាយ និងស៊ីជម្រៅ។

៥- សមត្ថភាពក្នុងការវាយតម្លៃ និងធ្វើសេចក្ដីសម្រេចចិត្តដោយសុភវិនិច្ឆ័យ និងការទទួលខុសត្រូវប្រកបដោយសេចក្ដីថ្លៃថ្នូរ ចិត្តមេត្តាករុណានូវរាល់សកម្មភាពរបស់ខ្លួនក្នុងនាមជាបុគ្គល និងសមាជិកគ្រួសារ សហគមន៍ និងសង្គម។

៦- ការយល់ដឹងក្នុងការបំពេញកាតព្វកិច្ច និងការប្រើប្រាស់សិទ្ធិពលរដ្ឋដោយមានការទទួលខុសត្រូវក្នុងនាមជាបុគ្គល និងសមាជិកគ្រួសារ សហគមន៍ សង្គម តំបន់ និងពិភពលោក។

៧- បំណិនសិក្សាពេញមួយជីវិត ជួយលើកកម្ពស់គុណតម្លៃជាមូលដ្ឋាន និងបង្កើនចំណេះដឹងឱ្យទូលំទូលាយស្ដីពីសេដ្ឋកិច្ច នយោបាយ ប្រវត្តិសាស្ត្រ វប្បធម៌ សាសនា ជាតិសាសន៍ អត្តសញ្ញាណជាតិ និងបរិស្ថានរបស់ប្រទេសខ្លួន ប្រទេសក្នុងតំបន់ និងពិភពលោក ដើម្បីលើកកម្ពស់ការអប់រំជាពលរដ្ឋសកម្ម និងពលរដ្ឋសាកលប្រកបដោយចីរភាព និងសន្តិសហវិជ្ជមានជាមនុស្សជាតិ។

៣.៨- ស្មារតីស្រឡាញ់ ការពារ និងកសាងជាតិ មាតុភូមិ និងពូជសាសន៍របស់ខ្លួនដោយអនុវត្តគោលការណ៍ប្រជាធិបតេយ្យសេរីពហុបក្ស និងការគោរពសិទ្ធិមនុស្សដោយប្រើច្បាប់ជាតិ និងអន្តរជាតិ។

## គ. មុខវិជ្ជាសិក្សា និងម៉ោងសិក្សានៅមធ្យមសិក្សាបឋមភូមិ

កម្មវិធីសិក្សាត្រូវកំណត់ឱ្យបង្រៀនចំនួន ៣៥ សប្ដាហ៍ ក្នុងមួយឆ្នាំសិក្សា។

### គ.១. សមត្ថភាពរំពឹងទុក

ក្រោយពេលបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ សិស្សនឹងទទួលបាន៖

**វិជ្ជាសម្បទា៖**

- មានចំណេះដឹងមូលដ្ឋានគ្រឹះរឹងមាំផ្នែកភាសាខ្មែរ វិទ្យាសាស្ត្រ វិទ្យាសាស្ត្រសង្គមគណិតវិទ្យា និងអភិវឌ្ឍសុខភាព កាយសម្បទា និងសីលធម៌

- មានចំណេះដឹងមូលដ្ឋានគ្រឹះផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ (ICT) និងភាសាបរទេស។

**បំណិនសម្បទា៖**

- មានបំណិនមូលដ្ឋាន រឹងមាំ និងទូលំទូលាយផ្នែកភាសាខ្មែរ (ការអាន ការសរសេរ ការនិយាយ និងការស្ដាប់)
- មានបំណិនមូលដ្ឋានរឹងមាំផ្នែកគណិតវិទ្យាគណនា ប្រៀបធៀប ពន្យល់ បកស្រាយ និងដោះស្រាយបញ្ហា)
- មានបំណិនប្រើប្រាស់ចំណេះដឹងវិទ្យាសាស្ត្រ បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ (ICT) មូលដ្ឋាន
- មានបំណិនត្រិះរិះពិចារណា និងដោះស្រាយបញ្ហាមូលដ្ឋានក្នុងការសិក្សា និងក្នុងសង្គម
- មានបំណិនប្រាស្រ័យទាក់ទងទូលំទូលាយសម្រាប់ការសិក្សា និងការរស់នៅប្រចាំថ្ងៃ
- មានបំណិនបង្ការ និងថែទាំសុខភាពបឋម
- មានសមត្ថភាពស្គាល់ខុស ស្គាល់ត្រូវ។

**ចរិយាសម្បទា៖**

- ស្រឡាញ់ និងផ្ដល់តម្លៃដល់ការសិក្សាទាំងក្នុង និងក្រៅប្រព័ន្ធ
- ស្គាល់ និងឱ្យតម្លៃសន្ដានចិត្តមេត្តា និងករុណាចំពោះគ្រួសារ មិត្តភក្តិ និងអ្នកដទៃ
- ស្គាល់ ស្រឡាញ់ ថែរក្សា និងការពារវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ និងសិល្បៈជាតិតំបន់ និងអន្តរជាតិ
- ស្រឡាញ់ និងឱ្យតម្លៃបរិស្ថាន វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
- ស្រឡាញ់ភាពស្អាតបាត ទាំងខ្លួនប្រាសាលារៀន ផ្ទះសម្បែង និងទីសាធារណៈ
- មានទម្លាប់ និងអនុវត្តការរស់នៅប្រកបដោយសុខភាពតាមរយៈការធ្វើពលកម្ម និងហាត់កីឡា
- ទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួនឯងនិងរបស់ក្រុមទាំងក្នុងការសិក្សានិងការរស់នៅប្រចាំថ្ងៃ។

### គ.២. មុខវិជ្ជា

ភាសាខ្មែរ (សរសេរតាមអាន តែងសេចក្តី វេយ្យាករណ៍ មេសូត្រ សិក្សាអត្ថបទ) គណិតវិទ្យា វិទ្យាសាស្ត្រ (រូបវិទ្យា ផែនដីបរិស្ថានវិទ្យា គីមីវិទ្យា ជីវវិទ្យា) សិក្សាសង្គម (ប្រវត្តិវិទ្យា ភូមិវិទ្យា សីលធម៌ ពលរដ្ឋវិជ្ជា គេហសេដ្ឋកិច្ចវិទ្យា) បច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍ (ICT) ភាសាបរទេស អប់រំសិល្បៈ អប់រំកាយ និងកីឡា អប់រំសុខភាព បំណិនជីវិតតាមមូលដ្ឋាន។

### គ.២. ម៉ោងសិក្សា

របាយមុខវិជ្ជា និងម៉ោងសិក្សាពីថ្នាក់ទី៧ដល់ថ្នាក់ទី៩៖

| **ល.រ** | **មុខវិជ្ជា** | **ថ្នាក់** | | |
|---|---|---|---|---|
| | | ៧ | ៨ | ៩ |
| ១ | ភាសាខ្មែរ | ៧ | ៧ | ៧ |
| ២ | ភាសាបរទេស | ៦ | ៦ | ៦ |
| ៣ | គណិតវិទ្យា | ៧ | ៧ | ៧ |
| ៤ | វិទ្យាសាស្ត្រ | ៦ | ៦ | ៦ |
| ៥ | សិក្សាសង្គម | ៧ | ៧ | ៧ |
| ៦ | បច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ (ICT) | ២ | ២ | ២ |
| ៧ | អប់រំកាយនិងកីឡា | ២ | ២ | ២ |
| ៨ | អប់រំសិល្បៈ | ១ | ១ | ១ |
| ៩ | អប់រំសុខភាព | ១ | ១ | ១ |
| ១០ | បំណិនជីវិតតាមមូលដ្ឋាន | ១ | ១ | ១ |
| សរុបម៉ោងសិក្សាប្រចាំសប្តាហ៍ | | ៤០ | ៤០ | ៤០ |

សម្គាល់ ៖

- ៦ថ្ងៃក្នុងមួយសប្តាហ៍ ៤ម៉ោងទៅ៧ម៉ោងសិក្សាក្នុងមួយថ្ងៃ និង១ម៉ោងសិក្សាមានរយៈពេល៥០នាទី។
- ជីវភាសាទី១ ៤ម៉ោងសិក្សា និង២ម៉ោងសិក្សាសម្រាប់ជីវភាសាទី២។

## ២.៦. ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន

ទាក់ទងជាមួយនឹងគុណភាព និងប្រសិទ្ធភាពនៃការបង្រៀន ឯកសារស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន របស់ក្រសួងអប់រំ យុវជន និងកីឡាឆ្នាំ២០០៩ ក៏បានលើកឡើងផងដែរថា ការបង្រៀនមួយដែលមាន គុណភាព និងប្រសិទ្ធភាពល្អគឺទាមទារឱ្យគ្រូមានលំនាំសកម្មភាពនៃការបង្រៀន ដែលជានាបាននូវកម្រិត ស្តង់ដាក្នុងវិជ្ជាជីវៈជាគ្រូបង្រៀន។

ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀនគឺជា ការបញ្ជាក់ប្រាប់ពីអំពើ ឬសកម្មភាពរបស់គ្រូបង្រៀន ដែលអាច អនុវត្តបានហើយមានឥទ្ធិពលទៅលើសិស្ស។ គឺជាឧបករណ៍សម្រាប់វាស់សមត្ថភាពដែលស្តែងចេញរបស់ គ្រូបង្រៀន ហើយក៏ជាខ្នាតគំរូសម្រាប់អ្នកអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលគ្រូ និងសម្រាប់ការធ្វើផែនការក សាងសមត្ថភាពគ្រូបង្រៀន។ ស្តង់ដារគ្រូបង្រៀនគឺ បានបញ្ជាក់អំពីការបង្រៀនដែលមានគុណភាព ដោយ អាចប្រាប់បានពីអ្វី ដែលគេបានឱ្យតម្លៃនៅក្នុងការបង្រៀន ដែលបញ្ជាក់ថា គ្រូបង្រៀនគួរយល់ដឹងអ្វីខ្លះ ហើយនិងអាចធ្វើអ្វីខ្លះបានប្រសើរជាងមុនក្នុងរយៈពេលវែង។

ដើម្បីដឹងថាគ្រូបង្រៀនបានអនុវត្តសម្រេចដល់ត្រឹមកម្រិតស្តង់ដារណានោះ យើងត្រូវធ្វើការសង្កេត ឬរកភស្តុតាង។ ភស្តុតាងដែលយើងអាចរកឃើញបានតាមរយៈ៖

- ការបង្ហាញ៖ សង្កេតសកម្មភាពបង្រៀន
- ឯកសារកំណត់ត្រា៖ ពិនិត្យកំណត់ត្រា ឯកសារយោង កិច្ចតែការបង្រៀន គំរូកិច្ចការសិស្ស...។
- សម្ភាសន៍៖ ស្តាប់របាយការណ៍ជាភស្តុតាង និងធ្វើការសម្ភាសន៍ជាមួយគ្រូបង្រៀន។

សកម្មភាពបង្រៀនដែលមានគុណភាព និងប្រសិទ្ធភាពនោះ គឺជាការបង្រៀនមួយដែលមាន លក្ខណៈ ស្តង់ដារ។

**ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនមាន៖**

**១. ចំណេះដឹងវិជ្ជាជីវៈ**

គ្រូបង្រៀនមានចំណេះដឹងវិជ្ជាជីវៈសម្បូរបែប។ គាត់ត្រូវតែដឹងច្បាស់អំពីតម្រូវការសិក្សា សមត្ថភាព ប្រវត្តិ ការសិក្សាច្បាស់លាស់ នងឥរិយាបថរបស់សិស្សម្នាក់ៗ ហើយក៏យល់ដឹងផងដែរពីប្រភេទគ្រួសារ និងកត្តា

ផ្សេងៗដែលមានឥទ្ធិពលដល់ការសិក្សារបស់សិស្ស (យេនឌ័រ ពិការភាព និងក្រុមជនជាតិភាគតិច...) ព្រមទាំងយល់ដឹងអំពីវិធីដោះស្រាយកត្តាទាំងនេះ។ គ្រូបង្រៀនត្រូវមានការយល់ដឹងពីវិធីដោះស្រាយកត្តាទាំងនេះ និងត្រូវមានការយល់ដឹងពីគោលនយោបាយអប់រំ ជាពិសេសគោលដៅអប់រំជាតិ និងគោលបំណងអប់រំចំណេះទូទៅ ហើយពេញចិត្តក្នុងការអនុវត្តនៅសាលារៀន។

គ្រូបង្រៀនយល់អំពីទ្រឹស្តីនៃកិច្ចតែងការបង្រៀនដូចជា វត្ថុបំណង និងវិធីសាស្ត្របង្រៀន និងអាចជ្រើសរើសវិធីវាយតម្លៃលើលទ្ធផលសិក្សាបានសមស្រប។ គ្រូបង្រៀនអាចយល់អំពីខ្លឹមសារកម្មវិធីសិក្សា ហើយមានសមត្ថភាពពន្យល់មេរៀនបានច្បាស់លាស់ និងយល់អំពីរបៀបបញ្ជ្រាបខ្លឹមសារពីមុខវិជ្ជារបស់ខ្លួនទៅមុខវិជ្ជាមួយផ្សេងទៀតក្នុងន័យឱ្យសិស្សទទួលបាននូវបំណិនជាច្រើននិងមានចិត្តកាន់តែចង់រៀន។ គ្រូបង្រៀនត្រូវយល់ដឹងអំពីបរិស្ថានក្នុងថ្នាក់រៀន និងក្នុងសហគមន៍ ជាពិសេសយល់ពីរបៀបរៀនរបស់សិស្ស ភាពខុសគ្នារវាងទេពកោសល្យ ល្បឿន និងរបៀបសិក្សាដែលមានឥទ្ធិពលដល់ការសិក្សារបស់សិស្ស។

**២. ការប្រតិបត្តិវិជ្ជាជីវៈ**

គ្រូបង្រៀនត្រូវរៀបចំកិច្ចតែងការបង្រៀនឱបានច្បាស់លាស់ និងប្រកបដោយប្រសិទ្ធភាពតាមកម្មវិធីសិក្សា ដោយផ្អែកលើសៀវភៅសិស្ស សៀវភៅគ្រូ និងសម្ភារសិក្សាផ្សេងៗទៀតដែលអាចរកបាន។ ដើម្បីគាំទ្រដល់កិច្ចតែងការបង្រៀន គ្រូបង្រៀនគួរគប្បីរៀបចំសម្ភារបង្រៀន និងរៀន ដើម្បីរិះរកមធ្យោបាយសម្រេចការសិក្សារបស់សិស្សប្រកបទៅដោយប្រសិទ្ធភាព។

គ្រូបង្រៀនក៏ប្រើប្រាស់វិធីវាយតម្លៃលទ្ធផលសិក្សាផ្សេងៗពីគ្នា ដែលសមស្របទៅតាមតម្រូវការ និងទេពកោសល្យរបស់សិស្ស។ គ្រូបង្រៀនត្រូវបញ្ជូនព័ត៌មានត្រឡប់ទៅសិស្ស ឪពុកម្តាយ ឬអាណាព្យាបាលអំពីការអភិវឌ្ឍចំណេះដឹង បំណិន និងឥរិយាបថរបស់សិស្ស។

គ្រូបង្រៀនត្រូវផ្តល់ឱ្យសិស្សគ្រប់រូបនូវបរិស្ថានសិក្សាប្រកបដោយសុវត្ថិភាព និងធ្វើឱ្យមានការប្រឹងប្រែងអស់ពីសមត្ថភាព ហើយលើកទឹកចិត្តសិស្សឱ្យកាន់តែមានការទទួលខុសត្រូវខ្ពស់លើការសិក្សារបស់ខ្លួន។ គ្រូបង្រៀនត្រូវចេះប្រើវិធីសាស្ត្របង្រៀនឱ្យបានសម្បូរបែបដើម្បីសម្រួលដល់ការសិក្សារបស់សិស្ស និងសម្រេចបាននូវវត្ថុបំណងមេរៀន។ ម្យ៉ាងទៀតគ្រូបង្រៀនគួរមានសមត្ថភាពផ្តល់មធ្យោបាយឱ្យស្រប

ទៅតាមរបៀបសិក្សារួមនឹងតម្រូវការផ្សេងៗគ្នារបស់សិស្ស តាមរយៈការអនុវត្តវិធីបង្រៀនសមស្របសម្បូរបែប ដោយបង្កឱកាសឱ្យសិស្សចូលរួមគិតឱ្យបានល្អិតល្អន់ និងច្នៃប្រឌិត។ លើសពីនេះទៀត គឺគ្រូបង្រៀនត្រូវចេះប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានសារគមនាគមន៍ និងធនធាននៅក្នុងបណ្ណាល័យបើមានលទ្ធភាព ដើម្បីធ្វើឱ្យកិច្ចការងារបង្រៀន និងរៀនកាន់តែមានប្រសិទ្ធភាពឡើងថែមទៀត។

**៣.ការសិក្សាវិជ្ជាជីវៈ**

យើងបានដឹងហើយថាគ្រូបង្រៀន គឺជាអ្នកលើកទឹកចិត្ត និងជាអ្នកធានាឱ្យសិស្សទទួលបានជោគជ័យក្នុងការសិក្សា ដូច្នេះគាត់ត្រូវតែស្វ័យសិក្សាវាយតម្លៃការបង្រៀន ដើម្បីអភិវឌ្ឍខ្លួនឯង និងប្រើប្រាស់ផែនការសម្រាប់ដឹកនាំស្វ័យសិក្សាស្របតាមជីវភាពរស់នៅជាក់ស្តែង។ គ្រូបង្រៀនត្រូវអភិវឌ្ឍផ្នែកបច្ចេកវិទ្យាព័ត៌មានសារគមនាគមន៍ និងបំណិនផ្សេងៗសម្រាប់អនុវត្តក្នុងការបង្រៀន ហើយធ្វើឱ្យប្រសើរឡើងនូវបំណិនទំនាក់ទំនងជាមួយសិស្ស ឪពុកម្តាយសិស្ស មិត្តរួមអាជីព និងជាមួយអ្នកផ្សេងៗទៀតនៅក្នុងសហគមន៍។

គ្រូបង្រៀនត្រូវលើកកម្ពស់សមត្ថភាពវិជ្ជាជីវៈរបស់ខ្លួនតាមរយៈការអាន និងស្រាវជ្រាវប្រែកពឯកសារផ្សេងៗ ដើម្បីពង្រីកចំណេះដឹងឱ្យបានទូលំទូលាយក្នុងន័យកែលម្អការបង្រៀន និងរៀន ហើយក៏ត្រូវមានទំនាក់ទំនងល្អជាមួយគ្រូដទៃទៀតក្នុងការសិក្សាវជ្ជាជីវៈ។

**៤.សីលធម៌វិជ្ជាជីវៈ**

សីលធម៌វិជ្ជាជីវៈ គឺទាក់ទងទៅនឹងគ្រប់ទិដ្ឋភាពទាំងអស់ក្នុងវិជ្ជាជីវៈជាគ្រូបង្រៀនដែលជារួមមានការប្តេជ្ញាចិត្តបង្រៀនសិស្សប្រើប្រាស់មនសិការវិជ្ជាជីវៈប្រកបទៅដោយគតិបណ្ឌិត និងមានចំណេះដឹងគ្រប់គ្រាន់តាមក្រមសីលធម៌របស់ក្រសួងអប់រំ យុវជន និងកីឡា និងច្បាប់ស្តីពីការអប់រំ។ គ្រូបង្រៀនត្រូវគោរពពេលវេលាតាមភារកិច្ច មានវត្តមានជាប្រចាំនៅក្នុងសាលារៀន មានការស្លៀកពាក់សមរម្យ និងមានឥរិយាបថថ្លៃថ្នូរ។ គ្រូបង្រៀនគួរតែចូលរួមគ្រប់សកម្មភាពទាំងក្នុង និងក្រៅម៉ោងទាំងអស់របស់សាលារៀនឱ្យបានសមស្របតាមករណីដែលអាចធ្វើទៅបាន។

គ្រូបង្រៀនដែលមានប្រសិទ្ធភាព គឺមិនរើសអើងសិស្សទោះនៅក្នុងកាលៈទេសៈណាក៏ដោយ ដូចជា

បញ្ហាយែនឌ័រ ជនជាតិភាគតិច ពិការភាព ក្រីក្រ និងត្រូវចេះថែទាំសិស្ស ផ្តល់លទ្ធភាពឱ្យសិស្សប្រើប្រាស់ធនធានឱ្យអស់ពីលទ្ធភាព ហើយយកចិត្តទុកដាក់ដល់សិស្សឱ្យបានស្មើៗគ្នា រួចបង្ហាញពីភាពយុត្តិធម៌ក្នុងការត្រួតពិនិត្យលទ្ធផលសិក្សា។

នៅពេលទាក់ទងជាមួយសិស្ស គ្រូបង្រៀនត្រូវមានការគោរពសិទ្ធិសិស្ស ដោយមិននិយាយមើលងាយ ឬដាក់ទណ្ឌកម្មដល់ពួកគេតាមរបៀបហិង្សានោះឡើយ។ គ្រូបង្រៀនត្រូវមានចិរយាសម្បត្តិមានសុជីវធម៌ និងអាកប្បកិរិយាថ្លៃថ្នូរសម្រាប់ធ្វើការសហការជាមួយសហការី និងមាតាបិតាសិស្សដើម្បីផលប្រយោជន៍សិស្សធ្វើជាគំរូដល់សិស្សក្នុងការរស់នៅ និងរៀនសូត្រល្អ ពិសេសចេះលើកកម្ពស់ស្មារតីឱ្យសិស្សរឹងប៉ឹង និងវិជ្ជមាន ហើយបង្កើតស្មារតីលះបង់ និងរួមចំណែកក្នុងសហគមន៍ទាំងមូល។

## ២.៧. ក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន

គន្លងអាជីពគ្រូបង្រៀន ត្រូវបានរៀបចំឡើងដោយក្រសួងអប់រំ យុវជន និងកីឡាផ្អែកតាមនិន្នាការនៃការអនុវត្តគន្លងអាជីពនៅប្រទេសអភិវឌ្ឍ និងក្នុងតំបន់ក្នុងគោលដៅពង្រឹងគុណភាពបុគ្គលិកអប់រំ ជាពិសេសគ្រូបង្រៀន គណៈគ្រប់គ្រងសាលារៀន និងអ្នកឯកទេសអប់រំ ដើម្បីឆ្លើយតបនឹងការប្រែប្រួលសង្គម និងសេដ្ឋកិច្ចជាតិ និងអន្តរជាតិ និងដោះស្រាយក្នុងវិស័យអប់រំ (ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន, ២០១០)។ ក្របខណ្ឌគន្លងអាជីពគ្រូបង្រៀនមានចក្ខុវិស័យកសាងគ្រូបង្រៀន អ្នកគ្រប់គ្រងសាលារៀន និងអ្នកឯកទេសអប់រំ ឱ្យមានចំណេះដឹង ជំនាញ សីលធម៌ និងមានសមត្ថភាពវិជ្ជាជីវៈដោយមានការទទួលស្គាល់ពីសង្គម។ នៅកម្ពុជា គ្រូបង្រៀនភាគច្រើនមិនទាន់មានបរិញ្ញាបត្រនៅឡើយ ទោះបីជាការបណ្តុះបណ្តាលគ្រូបង្រៀនមានការវិវត្តន៍ជាច្រើនក៏ដោយ។ ក្នុងឆ្នាំ២០១៦-២០១៧ ការបណ្តុះបណ្តាលគ្រូបង្រៀនអនុវត្តប្រព័ន្ធ ១២+២ ទាំងអស់សម្រាប់គ្រប់កម្រិតសិក្សា លើកលែងតែកម្រិតមធ្យមសិក្សាទុតិយភូមិដែលអនុវត្តប្រព័ន្ធបរិញ្ញាបត្រ+១។ ដើម្បីឆ្លើយតបនឹងការរៀន និងបង្រៀន ក្នុងសម័យបច្ចេកវិទ្យាទំនើប កម្ពុជាត្រូវការគ្រូបង្រៀនគ្រប់កម្រិតមានសញ្ញាបត្រយ៉ាងហោចណាស់បរិញ្ញាបត្រ ដើម្បីបង្រៀនចាប់ពីមត្តេយ្យរហូតដល់មធ្យមសិក្សាទុតិយភូមិ។ ថ្វីបើមានការផ្តួចផ្តើមគោលនយោបាយ និងមានកម្មវិធីដំឡើងថ្នាក់គ្រូបង្រៀន ដែលគ្មានគុណភាពទាំងអស់ទៅជាគ្រូបង្រៀនដែលមានគុណភាព តាមរយៈការប្រើប្រាស់

លក្ខខណ្ឌវិនិច្ឆ័យការជ្រើសរើសសម្រាប់គ្រូបង្រៀនថ្មី និងការដាក់បញ្ចូលកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈ រយៈពេលខ្លីក៏ដោយគ្រូបង្រៀនភាគច្រើននៅមិនទាន់មានសញ្ញាបត្របរិញ្ញាបត្រ ដែលតម្រូវដោយផែនការសកម្មភាពគោលនយោបាយគ្រូថាត្រឹមឆ្នាំ២០២០ គ្រូទាំងអស់ត្រូវតែមានសញ្ញាបត្រយ៉ាងហោចណាស់ក៏ត្រឹមកម្រិតបរិញ្ញាបត្រដែរ។

គន្លងគ្រូបង្រៀនត្រូវបានរៀបចំសម្រាប់គ្រូបង្រៀនដែលមានឧបនិស្ស័យបង្រៀនសិស្សក្នុងថ្នាក់រៀន និងចែកចេញជា ៣ កម្រិតគឺ៖

១) **គ្រូឈានមុខ** មានគុណផលការងារធ្វើឱ្យប្រសើរឡើងនូវការអនុវត្តកម្មវិធីសិក្សា ការបង្រៀន ការវាយតម្លៃ និងគុណផលសិក្សារបស់សិស្សនៅកម្រិតសាលារៀន។

២) **គ្រូគំរូ** មានគុណផលការងារធ្វើឱ្យប្រសើរឡើងនូវការអនុវត្តកម្មវិធី ការបង្រៀន ការវាយតម្លៃ និងគុណផលសិក្សារបស់សិស្ស នៅតាមសាលារៀន កម្រិតស្រុក ឬខេត្ត។

៣) **គ្រូឆ្នើម** មានគុណផលការងារធ្វើប្រសើរឡើងដល់គោលនយោបាយ និងអន្តរាគមន៍ពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីសិក្សា ការបង្រៀន ការវាយតម្លៃ គុណផលសិក្សារបស់សិស្ស និងគុណផលសាលារៀននៅកម្រិតជាតិ។

គន្លងគណៈគ្រប់គ្រងសាលារៀនត្រូវបានរៀបចំសម្រាប់នាយក និងនាយករងដែលមានឧបនិស្ស័យដឹកនាំ និងគ្រប់សាលារៀន និងចែកចេញជាបីកម្រិត៖

១) **នាយកឈានមុខ** មានគុណផលដឹកនាំ និងគ្រប់គ្រងសាលារៀនធ្វើឱ្យប្រសើរឡើងនូវគុណផលសិក្សារបស់សិស្ស តាមរយៈការគ្រប់គ្រងលើការអនុវត្តកម្មវិធីសិក្សា ការបង្រៀន ការវាយតម្លៃលទ្ធផលសិក្សា និងការអភិវឌ្ឍវិជ្ជាជីវៈបង្រៀនជាប្រចាំ នៅកម្រិតសាលារៀន។

២) **នាយកគំរូ** មានគុណផលដឹកនាំ និងគ្រប់គ្រងសាលារៀនធ្វើឱ្យប្រសើរឡើងនូវការអនុវត្តកម្មវិធីសិក្សា ការបង្រៀន ការវាយតម្លៃលទ្ធផលសិក្សា និងការអភិវឌ្ឍវិជ្ជាជីវៈបង្រៀនជាប្រចាំ នៅកម្រិតស្រុក ឬ ខេត្ត។

៣) **នាយកឆ្នើម** មានគុណផលដឹកនាំ និងគ្រប់គ្រងសាលារៀន ធ្វើឱ្យប្រសើរឡើងដល់គោលនយោបាយ និងការអនុវត្តពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីសិក្សា ការបង្រៀន ការវាយតម្លៃលទ្ធផលសិក្សា និងការអភិវឌ្ឍ

វិជ្ជាជីវៈបង្រៀនជាប្រចាំ នៅកម្រិតជាតិ។

គន្លងអ្នកឯកទេសត្រូវបានរៀបចំសម្រាប់អ្នកជំនាញបម្រើការក្នុងប្រព័ន្ធអប់រំ ដែលមានឧប-និស្ស័យស្រាវជ្រាវ សរសេរសៀវភៅ និងតាក់តែងគោលនយោបាយ ហើយចែកចេញជាបីកម្រិតៈ

១) **អ្នកឯកទេសឈានមុខ** មានគុណផលការងារធ្វើឱ្យប្រសើរឡើងនូវគុណផលសិក្សារបស់សិស្ស តាមរយៈការស្រាវជ្រាវ និងការផ្តល់យោបល់ជាសំណេរ លើការអនុវត្តកម្ម វិធីសិក្សា វិធីសាស្ត្រគរុកោសល្យ ការវាយតម្លៃ ប្រឹក្សាយោបល់ អធិការកិច្ច ធានាគុណភាព និងការអភិវឌ្ឍវិជ្ជាជីវៈបង្រៀន នៅកម្រិតសាលារៀន។

២) **អ្នកឯកទេសគំរូ** មានគុណផលការងារធ្វើឱ្យប្រសើរឡើងនូវគផលសិក្សារបស់សិស្សតាមរយៈការស្រាវជ្រាវ និងការផ្តល់យោបល់ជាសំណេរ លើការអនុវត្តកម្មវិធីសិក្សា វិធីសាស្ត្រគរុកោសល្យ ការវាយតម្លៃ ប្រឹក្សាយោបល់ អធិការកិច្ច ធានាគុណភាព និងការអភិវឌ្ឍវិជ្ជាជីវៈបង្រៀន នៅកម្រិតស្រុក ឬខេត្ត

៣) **អ្នកឯកទេសឆ្នើម** មានគុណផលការងារធ្វើឱ្យប្រសើរឡើងដល់គោលនយោបាយ និងការអនុវត្ត ពាក់ព័ន្ធនឹងការស្រាវជ្រាវ និងការផ្តល់យោបល់ជាសំណេរ លើការអនុវត្តកម្ម វិធីសិក្សា វិធីសាស្ត្រគរុកោសល្យ ការវាយតម្លៃ ប្រឹក្សាយោបល់ អធិការកិច្ច ធានាគុណភាព និងការអភិវឌ្ឍវិជ្ជាជីវៈ បង្រៀន នៅកម្រិតជាតិ។

ការរៀនវិជ្ជាជីវៈបង្រៀនឱ្យមានប្រសិទ្ធភាពត្រូវផ្សារភ្ជាប់ជាមួយប្រព័ន្ធលាភការ ឬប្រព័ន្ធរង្វាន់ ដើម្បីលើកតម្កើងការបង្រៀន និងការរៀនរបស់គ្រូ។ គន្លងអាជីពគ្រូបង្រៀនជាប្រព័ន្ធតម្រង់ទិសវិជ្ជាជីវៈសម្រាប់គ្រូបង្រៀន អ្នកដឹកនាំសាលារៀន និងអ្នករដ្ឋបាល ឬជាប្រព័ន្ធនាំគ្រូបង្រៀន នាយក និងអ្នករដ្ឋ-បាលអប់រំ ឱ្យជ្រើសរើសគន្លងអាជីព និងអភិវឌ្ឍអាជីព។ គន្លងអាជីពគ្រូបង្រៀន ជួយដំឡើងបៀវត្សរបស់បុគ្គលិកអប់រំ តាមវិជ្ជាជីវៈ ដើម្បីធានាសម្រេចគោលដៅនៃការអភិវឌ្ឍបំណិនវិជ្ជាជីវៈ។ ក្រៅពីខ្វះគ្រូដែលមានគុណសម្បទា សាលរៀនមួយចំនួនមានខ្វះ ឬលើសគ្រូបង្រៀន ឬយ៉ាងហោចណាស់មានបញ្ហាលើស ឬខ្វះគ្រូបង្រៀនតាមមុខវិជ្ជា មានចំនួនសិស្សច្រើនពេកក្នុងមួយថ្នាក់ៗ។ កត្តាមួយក្នុងចំណោមកត្តាលើស ឬខ្វះគ្រូបង្រៀន គឺកង្វះការលើកទឹកចិត្តឱ្យគ្រូបង្រៀនទៅបំពេញភារកិច្ចនៅកន្លែងដែលខ្វះខាត។

គ្រូបង្រៀនជាមូលដ្ឋានគ្រឹះក្នុងការលើកកម្ពស់គុណភាពអប់រំ។ គុណសម្បទារបស់គ្រូបង្រៀន

ដើម្បីជានាប្រសិទ្ធភាពការងារ ដែលមានចែងក្នុងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន រួមបញ្ចូលទាំងចំណេះដឹងវិជ្ជាជីវៈ ការប្រតិបត្តិវិជ្ជាជីវៈ ការសិក្សាវិជ្ជាជីវៈ និងសីលធម៌វិជ្ជាជីវៈ។ ក្នុងដំណើរឆ្ពោះទៅសង្គមពុទ្ធិ បដិវត្តន៍ឧស្សាហកម្មទី៤ និងពលរដ្ឋសកល កម្ពុជាត្រូវពង្រឹងវិស័យអប់រំដើម្បីឱ្យពលរដ្ឋដែលឆ្លងកាត់ប្រព័ន្ធអប់រំមានកញ្ចប់សមត្ថភាពនៃសតវត្សរ៍ទី២១ ដូច្នេះគ្រូបង្រៀនត្រូវត្រៀមខ្លួនដើម្បីឆ្លើយតបនឹងតម្រូវការរបស់សិស្ស។

## ២.៨. គោលនយោបាយស្តីពីគ្រូបង្រៀន

ផ្អែកតាមគោលនយោបាយគ្រូបង្រៀនឆ្នាំ២០១៣ ផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀនឆ្នាំ ២០១៥ និងទទួលបានការយល់ព្រមពីក្រសួងអប់រំ យុវជន និងកីឡា ដែលលើកឡើងពីការលើកកម្ពស់គុណភាពគ្រូបង្រៀន ដោយផ្សារភ្ជាប់ទៅនឹងការបង្កើនប្រាក់ចំណូល និងឋានៈក្នុងសង្គមរបស់គ្រូបង្រៀន (បណ្ឌិត ហង់ ជួន ណារ៉ុន, ២០១៥)៖

- ទី១- ទាក់ទាញអ្នកមានសមត្ថភាពឲ្យចូលធ្វើគ្រូបង្រៀនដោយ៖
  - ផ្តល់ផលប្រយោជន៍សង្គម និងហិរញ្ញវត្ថុដោយតម្លើងប្រាក់បៀវត្ស និងប្រយោជន៍ផ្សេងទៀត
  - បើកទូលាយការជ្រើសរើសគ្រូ (អនុញ្ញាតឲ្យអ្នកមានបរិញ្ញាបត្រពីគ្រឹះស្ថានរដ្ឋ និងឯកជនបានអាជ្ញាប័ណ្ណអប់រំ)
  - ផ្តល់ការបំប៉នគ្រូបង្រៀន ១២+២ ដើម្បីក្លាយជាបរិញ្ញាបត្រ
  - រឹតបណ្តឹងការជ្រើសរើសចូលបណ្តុះបណ្តាល (ប្រកួតប្រជែងចំណាត់ថ្នាក់ជាតិ លែងធ្វើចំណាត់តាមខេត្ត)
  - របេក្ខជនទទួលបាននិទ្ទេស A B C ប្រឡងថ្នាក់ទី១២ ជាប់ជាស្វ័យប្រវត្តិ
  - កែលម្អការប្រឡងចូល (i) ការប្រឡងគោរពគោលការណ៍ច្បាប់ តម្លាភាពយុត្តិធម៌(ii) ប្រឡងសរសេរ ( iii) សម្ភាសផ្ទាល់មាត់ (iv) កែប្រែគោលការណ៍កំណត់អាយុ (v) តាមដានការបណ្តុះបណ្តាល
- ទី២- បណ្តុះបណ្តាលគ្រូបង្រៀនដោយ៖

- កែទម្រង់កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនគ្រប់កម្រិត រៀបចំកម្មវិធីបណ្តុះ បណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋានតាមរូបមន្ត12+4 (បរិញ្ញាបត្រអប់រំ) សម្រាប់សិស្សថ្នាក់ទី១២ ដែលជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ដោយផ្តោតលើចិត្តគរុកោសល្យ ICT វិធីសាស្ត្របង្រៀន ភាសាបរទេស គណិតវិទ្យា នឹងវិទ្យាសាស្ត្រ
- រៀបចំកម្មវិធីបណ្តុះបណ្តាលបរិញ្ញាបត្រជាន់ខ្ពស់បូក១ ចំពោះអ្នកមានបរិញ្ញាបត្រជាន់ខ្ពស់ឲ្យក្លាយគ្រូបង្រៀនវិទ្យាល័យនៅវិទ្យាស្ថានជាតិអប់រំ
- អនុវត្តកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនផ្អែកតាមស្តង់ដារដោយសាកល្បងតាមរូបមន្ត 12+4 បរិញ្ញាបត្រអប់រំនៅ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគចំនួនពីរ
- បង្កើនប្រសិទ្ធភាពកម្មសិក្សាមុនពេលតាំងស៊ប់ក្នុងក្របខ័ណ្ឌ
- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន
- ប្រែក្លាយសាលាគរុកោសល្យឱ្យទៅជាមជ្ឈមណ្ឌលអភិវឌ្ឍគ្របង្រៀន
- បង្កើនគុណវឌ្ឍ និងបទពិសោធន៍បុគ្គលិកអប់រំនៅមជ្ឈមណ្ឌលអភិវឌ្ឍគ្រូបង្រៀន ឱ្យមាន
- សមត្ថភាពយ៉ាងទាបបរិញ្ញាបត្រជាន់ខ្ពស់

❖ ទី២- ការគ្រប់គ្រងគ្រូបង្រៀន

- ធ្វើទំនើបកម្មផែន ការតម្រូវការនិងផ្គត់ផ្គង់គ្របង្រៀន ដោយបញ្ចូលទិន្នន័យពីគ្រប់ប្រព័ន្ធ (EMS ,HRMIS. HEMIS, NFEMIS, FMIS)
- ពង្រឹងការប្រើប្រាស់គ្រូបង្រៀន ផ្អែកតាមនិយាម និងគោលការណ៍ប្រើប្រាស់បុគ្គលិក ដើម្បីកែលម្អការអនុវត្តការពង្រាយ គ្រូបង្រៀន
- លើកកម្ពស់ដំណើរការនិងនីតិវិធីនៃការជ្រើសរើស និងរក្សាទុកគ្រូបង្រៀនមានស្នាដៃល្អសម្រាប់ធានានិរន្តរភាពគ្រឹះស្ថានសិក្សា
- ធ្វើប្រតិភូកម្មការជ្រើសរើស និងការគ្រប់គ្រងគ្រូបង្រៀនទៅថ្នាក់ក្រោមជាតិតាមគោលការណ៍កំណត់

- ការចូលរួមរបស់គណៈកម្មការទ្រទ្រង់សាលារៀន និងអ្នកពាក់ព័ន្ធក្នុងការធ្វើសេចក្ដីសម្រេចចិត្ត (ការជ្រើសរើស ការផ្ដល់រង្វាន់ ការពិន័យ ការផ្ទេរ ការវាយតម្លៃ វេទិការសាធារណៈ ប្រជុំសំឡេងសិស្ស ការវាយតម្លៃសេវាមូលដ្ឋាន ការបង្រៀនបំណិនជីវិត។ល។

❖ ទី៤ ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀនៈ

- បណ្ដុះវប្បធម៌រៀនពេញមួយជីវិត ដោយចែករំលែកបទពិសោធន៍ជាមួយបណ្ដាញក្រុម អ្នកអប់រំ និងបង្កើនគុណវុឌ្ឍគ្រូបង្រៀនឲ្យទទួលបានសញ្ញាបត្រតាមរយៈពេល ១ខែកន្លះ ៣ដង
- អភិវឌ្ឍ និងអនុវត្តការងារវិក្រិតការគ្រូបង្រៀន(ពង្រឹងចំណេះដឹង ភាសាខ្មែរ គណិតវិទ្យា និង វិទ្យាសាស្ត្រសម្រាប់គ្រូបង្រៀនថ្នាក់ទី ៩ និងថ្នាក់ទី១២)
- បង្កើតប្រព័ន្ធវិក្រិតការរៀបរយដោយអនុវត្តការងារវិក្រឹតការៈ ១) នៅនឹងកន្លែង ២)មិនរៀបរយតាមការចាំបាច់នៃវិស័យអប់រំ ៣) រៀបរយដែលមានប្រព័ន្ធកម្មវិធីត្រឹមត្រូវ
- អនុវត្តអាហារូបករណ៍និងកម្មវិធីវិក្រឹតការពនឿន សម្រាប់ឱ្យគ្រូបង្រៀនទទួល បានបរិញ្ញាបត្រ/ ឬបរិញ្ញាបត្រជាន់ខ្ពស់ ចំនួន១០០០ កន្លែងក្នុងមួយឆ្នាំ
- បង្កើតប្រព័ន្ធក្រេឌីត ដើម្បីរៀបចំឱ្យមានការឯកភាពគ្នាមួយលើរាល់ប្រភេទ វគ្គវិក្រឹតការសម្រាប់ទទួលបាននូវការលើកកម្ពស់គុណវុឌ្ឍ និងផលប្រយោជន៍បន្ថែម (បៀវត្ស ដំឡើងឋានៈ)
- ពង្រឹងប្រព័ន្ធគាំទ្រគ្រូបង្រៀននៅនឹងកន្លែង ដើម្បីគាំទ្រគ្រូនៅតាមសាលារៀន ក្នុងគោលដៅពង្រឹងចំណេះដឹង មុខវិជ្ជាឯកទេស និងគរុកោសល្យ
- បង្កើតកម្មវិធីសម្រាប់គ្រូឧទ្ទេសវគ្គវិក្រឹតការនៃស្តង់ដាសម្រាប់សាលា គរុកោសល្យ ក្នុងការចុះជួយបំប៉នសមត្ថភាពគ្រូបង្រៀននៅនឹងកន្លែង

❖ ទី៥- ការលើកទឹកចិត្ត និងរក្សាទុកគ្រូបង្រៀន

- លើកកម្ពស់លក្ខខណ្ឌធ្វើការងារ និងរស់នៅរបស់គ្រូបង្រៀន តាមរយៈការផ្តល់បៀវត្ស លាភការ សុខុមាលភាពសង្គម អត្ថប្រយោជន៍ទូទៅ អត្ថប្រយោជន៍ពេលចូលនិវត្តន៍ ជាពិសេសអ្នកគ្រូ និងគ្រូបង្រៀនបម្រើការងារនៅតំបន់ដាច់ស្រយាលនិងជួបការលំបាក (បៀវត្ស ប្រាក់វិភាជន៍គ្រួសារ សិក្សា និងធានារ៉ាប់រងសុខភាព អាយុជីវិត កម្មវិធីកម្ចី/ឥណទាន ឧបត្ថម្ភធនសម្រាប់សង់ផ្ទះ ប្រាក់ម៉ោងបន្ថែម ប្រាក់ឧបត្ថម្ភគ្រូបង្រៀន រួមទាំងរបបសោធននិវត្តន៍ ។ល។)
- ផ្តល់ឯកសារ និងសម្ភារបរិក្ខារសម្រាប់បង្រៀន និងរៀន និងឯកសារសម្រាប់ស្រាវជ្រាវបន្ថែមជូនគ្រូបង្រៀន
- ផ្តល់សម្ភាររូបវ័ន្តបន្ថែម កែលម្អលក្ខខណ្ឌធ្វើការងារនៅសាលារៀនដាច់ស្រយាល និងសាលារៀនជួបការលំបាក (បង្គន់អនាម័យ ផ្ទះគ្រូបង្រៀន)
- ទទួលស្គាល់ និងជូនរង្វាន់ដល់គ្រូបង្រៀនដែលមានស្នាដៃល្អ (រក្សាគ្រូក្នុងប្រព័ន្ធ)
- ពានរង្វាន់គ្រូឆ្នើម (ស្នាដៃនិងបទពិសោធន៍ល្អ ដើម្បីចែករំលែកនូវបទពិសោធន៍ល្អ តាមមុខវិជ្ជាគោលនានា) រួមទាំងគ្រូបង្រៀនដែលចូលនិវត្តន៍
- រៀបចំគន្លងអាជីពគ្របង្រៀន
- រៀបចំបណ្តាញគាំទ្រ ជាប្រចាំជាក្លឹបសិក្សា/សមាគមវិជ្ជាជីវៈ តាមមុខវិជ្ជាឯកទេស សម្រាប់ជួយផ្នែកបច្ចេកទេសតាមមុខវិជ្ជា ធ្វើការស្រាវជ្រាវ ដឹកនាំ សន្និសីទវិជ្ជាជីវៈ ជួយបោះពុម្ពស្នាដៃ មេរៀនបទពិសោធន៍ល្អៗ។ល។
- បង្កើតក្រុមបច្ចេកទេសក្នុងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ដែលបានទទួលស្គាល់សម្រាប់ចុះជួយតាមមុខវិជ្ជានិងប្រជុំបច្ចេកទេសតាមមុខវិជ្ជាឯកទេសឱ្យបានទៀងទាត់

❖ ទី៦- ពង្រឹងភាពជាអ្នកដឹកនាំសាលារៀន

- រៀបចំស្តង់ដានាយក និងសៀវភៅណែនាំការគ្រប់គ្រងសាលារៀន
- បណ្តុះបណ្តាលនាយកសាលា តាមស្តង់ដារនាយកសាលាដោយផ្តល់អាទិភាពដល់នារី

- បង្កើតក្រុមប្រឹក្សា/សហគមន៍ នាយកសាលា និងបង្កើតយន្តការពង្រឹងការគាំទ្រនាយកសាលាជាដើម
- ការពារ និងលើកកម្ពស់សិទ្ធិគ្រូបង្រៀនដោយធានាថាគ្រូបង្រៀនទាំងអស់ទទួលបាននូវភាពយុត្តិធម៌ដូចគ្នាតាមរយៈការគ្រប់គ្រងសាលារៀនដែលមានតម្លាភាព
- កែលម្អលក្ខខណ្ឌជ្រើសរើស ការបណ្តុះបណ្តាល ការបំពេញការងារ និងផលប្រយោជន៍គ្រូឧទ្ទេស និងគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា។

❖ ទី៧- ពង្រឹងប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ៖

- កែលម្អទិន្នន័យក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានគ្រូបង្រៀន
- រៀបចំយន្តការពិនិត្យតាមដាន និងវាយតម្លៃការងារគ្រូបង្រៀនដោយផ្តោតលើស្តង់ដាវិជ្ជាជីវៈ
- និយាមប្រើប្រាស់ លក្ខណៈសម្បត្តិ និងគន្លងអាជីពគ្រូបង្រៀន
- ពង្រឹងការពិនិត្យតាមដាននៅនឹងកន្លែង តាមរយៈអធិការកិច្ច ការផ្តល់សិទ្ធិពេញលេញ ដល់នាយកសាលាក្នុងការផ្តល់មតិត្រលប់ដល់គ្រូបង្រៀន
- ពង្រីកវិសាលភាពនិង សមត្ថភាពនៃការងារអធិការកិច្ច និងយកព័ត៌មានត្រឡប់ពីគ្រូបង្រៀន ដើម្បីកែលម្អគោលនយោបាយពាក់ព័ន្ធនឹងវិស័យអប់រំ (រៀបចំការអង្កេតជារៀងរាល់ឆ្នាំដើម្បីតាមដានទស្សនៈរបស់គ្រូ លក្ខខណ្ឌធ្វើ ការងារ កម្មវិធីលើកទឹកចិត្ត)
- កំណត់សិទ្ធិគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈ ក្នុងការធ្វើសេចក្តីសម្រេចលើការគ្រប់គ្រងនិងអភិវឌ្ឍអង្គភាព។

# ជំពូកទី៣៖ វិធីសាស្ត្រស្រាវជ្រាវ

## ៣.១. គម្រោងវិភាគ

អ្នកស្រាវជ្រាវប្រើប្រាស់វិធីសាស្ត្របែបបរិមាណវិស័យ ដើម្បីឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវដែលបានកំណត់រួចនៅក្នុងជំពូកទី១។ ការស្រាវជ្រាវត្រូវបានធ្វើឡើងដោយប្រើកម្រងសំណួរដែលមានសំណួរបែបទម្រង់បិទ និងទម្រង់បើកដើម្បីប្រមូល ទិន្នន័យពីគណៈគ្រប់គ្រងនៅតាមអនុវិទ្យាល័យចំនួន ១០២ និងវិទ្យាល័យចំនួន ៣៦ ក្នុងខេត្តកណ្ដាល។ កម្រងសំណួរដែលត្រូវយកមកប្រើប្រាស់ក្នុងការប្រមូលទិន្នន័យនេះ គឺសម្រាប់បំពេញដោយនាយក នាយិការបស់សាលា។

## ៣.២. ការប្រមូលទិន្នន័យ

មុននឹងឈានដល់ដំណាក់កាលប្រមូលទិន្នន័យ អ្នកស្រាវជ្រាវបានយកលិខិតឧទ្ទេសនាមដែលចេញដោយវិទ្យាស្ថានជាតិអប់រំ ទៅជូននៅមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត ដើម្បីស្នើសុំការសហការ និងសម្របសម្រួលដល់អ្នកស្រាវជ្រាវមានលទ្ធភាពពេញលេញក្នុងការចុះប្រមូលទិន្ន័យ នៅតាមសាលារៀនគោលដៅ។ បន្ទាប់មកទៀត អ្នកស្រាវជ្រាវបានទាក់ទងទៅនាយកសាលានីមួយៗ ដោយជូនដំណឹងដល់ពួកគាត់មុន៣ថ្ងៃ ដើម្បីផ្ដល់ព័ត៌មានដល់គ្រូបង្រៀនពាក់ព័ន្ធ និងការសុំណាត់ជួបពួកគាត់នៅពេលវេលាណាមួយទុកជាមុន។ ពេលទៅដល់សាលារៀន អ្នកស្រាវជ្រាវ បានបង្ហាញលិខិតឧទ្ទេសនាមបេសកកម្មចុះប្រមូលទិន្នន័យនោះទៅនាយកសាលា និងសុំការអនុញ្ញាតពីគាត់ដើម្បីធ្វើការប្រមូលទិន្នន័យ និងធ្វើការបំពេញកម្រងសំណួរនោះដោយគោរពតាមក្រមសីលធម៌អ្នកស្រាវជ្រាវតាមការស្ម័គ្រចិត្ត និងគ្មានការបង្ខិតបង្ខំឡើយ។ ក្នុងការបំពេញកម្រងសំណួរនេះ ប្រើប្រាស់ពេលវេលាប្រហែល ៣០នាទី។

## ៣.៣. ឧបករណ៍ស្រាវជ្រាវ

អ្នកស្រាវជ្រាវប្រើប្រាស់កម្រងសំណួរក្នុងការប្រមូលទិន្នន័យតាមបែបបរិមាណវិស័យ ។ កម្រងសំណួរនេះគឺសម្រាប់នាយក/នាយិកា។ កម្រងសំណួរត្រូវបានបង្កើតឡើង ដោយផ្អែកលើទ្រឹស្ដីនានាទាក់ទងនឹងនិយាមប្រើប្រាស់គ្រូបង្រៀន ការប្រើប្រាស់គ្រូបង្រៀន មានដូចជាសេចក្ដីណែនាំស្ដីពីនិយាមប្រើប្រាស់បុគ្គលិក ក្របខណ្ឌកម្មវិធីសិក្សា និងអប់រំបច្ចេកទេសឆ្នាំ២០១៦ និងសំណួរមួយចំនួនទៀត។

## ៣.៤. ការជ្រើសរើសគំរូសំណាក

អ្នកស្រាវជ្រាវជ្រើសរើសយកវិទ្យាល័យចំនួន ៣៦ និង អនុវិទ្យាល័យចំនួន ១០២ ដើម្បីប្រមូលទិន្នន័យសម្រាប់ការសិក្សាស្រាវជ្រាវ ។

អ្នកស្រាវជ្រាវកំណត់យកនាយក នាយិកាសាលាមកធ្វើការសម្ភាសន៍ និងបំពេញកម្រងសំណួរ ព្រោះនាយកជាអ្នកដែលអនុវត្តផ្ទាល់លើការងារគ្រប់គ្រង ប្រើប្រាស់គ្រូបង្រៀននៅក្នុងសាលា។

## ៣.៥. ការវិភាគទិន្នន័យ

អ្នកស្រាវជ្រាវបានប្រើវិធីសាស្ត្រតាមបែបបរិមាណវិស័យ។ វិធីសាស្ត្របរិមាណវិស័យរួមមាន តារាងលេខ ចំនួន ភាគរយ ដោយការវិភាគទិន្នន័យពឹងផ្អែកពី ការពិពណ៌នា និងគណនាយ៉ាងប្រុងប្រយ័ត្នពីអ្នកចូលរួម ហើយការសិក្សាស្រាវជ្រាវនេះសំអាងលើការរកឃើញពីការសម្ភាសន៍ និងបញ្ជីសំណួរ។ អ្នកស្រាវជ្រាវបានអានចម្លើយ តារាងទិន្នន័យដើម្បីជៀសវាងបាត់ព័ត៌មាន ឬចំណុចសំខាន់ៗ។ បន្ទាប់មកអ្នកស្រាវជ្រាវរៀបចំចម្លើយស្រដៀងៗគ្នា ដាក់តាមក្រុមតូចៗ រួចចាត់ថ្នាក់តាមដំណើររឿងដែលបានកើតឡើងតាមលំដាប់លំដោយ និងរៀបចំដាក់ជាផ្នែកៗតាមជំពូកនីមួយៗឱ្យស្របតាមប្រធានបទ។

ការសិក្សាស្រាវជ្រាវនេះត្រូវបានសម្រេចតាមវិធីសាស្ត្រ បរិមាណវិស័យ ព្រោះអ្នកចូលរួមបានយល់ដឹងយ៉ាងជ្រាលជ្រៅនៃបាតុភូតដ៏ជាក់លាក់ ហើយមានការសហការជាមួយអ្នកចូលរួមក្នុងការសិក្សានេះ អ្នកស្រាវជ្រាវថែមទាំងមានកម្រងសំណួរ ដើម្បីឱ្យ នាយក នាយិកាបំពេញសម្រាប់សារណានេះ។

ទិន្នន័យត្រូវបានរៀបចំជា ២ ផ្នែករួមជាមួយនឹងសំណួរស្រាវជ្រាវ ដើម្បីឆ្លើយតបទៅនឹងប្រធានបទដូចខាងក្រោម៖

១) ការសិក្សា និងកំណត់ពីតម្រូវការនូវទិន្នន័យដែលសាលានីមួយៗ (អនុវិទ្យាល័យនិងវិទ្យាល័យដែលមានថ្នាក់ទី ៧ ដល់ថ្នាក់ទី ៩) មាន ទិន្នន័យ ចំនួនម៉ោងសរុប មុខវិជ្ជាឯកទេសនីមួយៗដែលសាលាកំពុងអនុវត្តជាក់ស្តែង ជាការសិក្សាដើម្បីចង់ដឹងការអនុវត្តកម្មវិធី បំណែងចែកសិស្ស ថ្នាក់រៀន និងគ្រូបង្រៀនត្រឹមត្រូវតាមនិយាមគរុកោសល្យឬទេ។

២) ការសិក្សាស្វែងយល់អំពីទស្សនៈរបស់នាយកសាលា លើការជ្រើសរើសគ្រូថ្មីដើម្បីឱ្យឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង។

# ជំពូកទី៤៖ លទ្ធផល និងការបកស្រាយ

## ៤.១. ការកំណត់ពីតម្រូវការ

### ៤.១.១. ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងបច្ចេកទេសឆ្នាំ២០១៦ និងតាមជាក់ស្តែង ក្នុងខេត្តកណ្តាល

លទ្ធផលនៃការស្រាវជ្រាវដូចមានក្នុងតារាងទី១ខាងក្រោម បានបង្ហាញថា ស្ថិតិសិស្សសរុបក្នុងសំណាកដែលជ្រើសរើសចេញពីស្រុក/ក្រុងទាំង ១១ ក្នុងខេត្តកណ្តាល មានចំនួន ៤៨៨៤៧ នាក់។ តាមនិយាមសិស្សអប្បបរមាក្នុងមួយថ្នាក់មានចំនួន ៤០ នាក់ ដែលកំណត់ដោយនិយាមនោះចំនួនថ្នាក់ នៅក្នុងស្រុកគោលដៅទាំង ១១ ត្រូវមានចំនួនសរុប ១២២១ ថ្នាក់ (៤៨៨៤៧ ចែកនឹង ៤០)។ តាមនិយាមសិស្សក្នុងមួយថ្នាក់ ត្រូវរៀន ៤០ ម៉ោងក្នុងមួយសប្តាហ៍ នាំឱ្យចំនួនម៉ោងសរុបគឺ ៤៨៨៤៧ ម៉ោង(១២២១គុណនឹង ៤០) ដែលត្រូវប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋានចំនួន ២៧១៤ នាក់ សម្រាប់គ្រប់មុខវិជ្ជាឯកទេសទាំងអស់ (និយាមគ្រូបង្រៀននៅអនុវិទ្យាល័យ ១៨ ម៉ោង ក្នុងមួយសប្តាហ៍)។ ប៉ុន្តែតាមទិន្នន័យជាក់ស្តែងដែលទទួលបានពីស្រុក/ក្រុងទាំង ១១ ខាងលើ ចំនួនថ្នាក់សរុបមានត្រឹមតែ ១១៤៨ ថ្នាក់ប៉ុណ្ណោះ តិចជាងចំនួនថ្នាក់ គិតតាមនិយាម ចំនួន ៧៣ ថ្នាក់ (១២២១ថ្នាក់ ដកនឹង១១៤៨ថ្នាក់)។ រីឯចំនួនគ្រូបង្រៀនដែលមានគុណវុឌ្ឍិកម្រិតមូលដ្ឋាន ហើយកំពុងបម្រើការងារនៅតាមអនុវិទ្យាល័យនានាក្នុងស្រុក/ក្រុងទាំង ១១ នោះវិញ មានចំនួនតែ ២៤១៧ នាក់ ប៉ុណ្ណោះតិចជាងតម្រូវការតាមនិយាមចំនួន ២៩៧ នាក់ (២៧១៤ នាក់ ដកនឹង ២៤១៧ នាក់) មានន័យថាខ្វះគ្រូបង្រៀនកម្រិតមូលដ្ឋាន ចំនួន ២៩៧ នាក់ បើអនុវត្តតាមនិយាមក្របខណ្ឌសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេសឆ្នាំ ២០១៦។

*តារាងទី១៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម ក្របខណ្ឌកម្មវិធីសិក្សាឆ្នាំ ២០១៦ និងតាមជាក់ស្តែង នៅមធ្យមសិក្សាបឋមភូមិ (ខេត្តកណ្តាល)*

| ចំនួន | តាមជាក់ស្តែង | តាមនិយាម |
|---|---|---|
| សិស្ស | ៤៨៨៤៧ នាក់ | |
| ថ្នាក់ | ១១៤៨ ថ្នាក់ | ១២២១ ថ្នាក់ |

| | | |
|---|---|---|
| ម៉ោង | ៤៥៩២០ ម៉ោង | ៤៨៨៤៧ ម៉ោង |
| គ្រូ | ២៥៥១ ថ្នាក់ | ២៧១៤ នាក់ |
| គ្រូមានគុណវុឌ្ឍិក្របខណ្ឌ (ខ) | ២៤១៧ នាក់ | |

**៤.១.២. ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែង ក្នុងខេត្តកណ្តាល**

លទ្ធផល នៃការស្រាវជ្រាវដូចមានក្នុងតារាងទី២ខាងក្រោម បានបង្ហាញថា ស្ថិតិសិស្សសរុបក្នុងសំណាកដែលជ្រើសរើសចេញពីស្រុក/ក្រុងទាំង ១១ ក្នុងខេត្តកណ្តាល មានចំនួន ៤៨៨៤៧ នាក់។ តាមនិយាមសិស្សអប្បបរមាក្នុងមួយថ្នាក់មានចំនួន ៤០ នាក់ ដែលកំណត់ដោយច្បាប់នោះចំនួនថ្នាក់ នៅក្នុងស្រុកគោលដៅទាំង ១១ ត្រូវមានចំនួនសរុប ១២២១ ថ្នាក់ (៤៨៨៤៧ ចែកនឹង ៤០)។ តាមនិយាមសិស្សក្នុងមួយថ្នាក់ត្រូវរៀន ៣២ ម៉ោងក្នុងមួយសប្តាហ៍ នាំឱ្យចំនួនម៉ោងសរុបគឺ ៣៩០៧៨ ម៉ោង (១២២១គុណនឹង ៣២) ដែលត្រូវប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋានចំនួន ២១៧១ នាក់ សម្រាប់គ្រប់មុខវិជ្ជាឯកទេសទាំងអស់ (និយាមគ្រូបង្រៀននៅអនុវិទ្យាល័យ ១៨ ម៉ោង ក្នុងមួយសប្តាហ៍)។ ប៉ុន្តែតាមទិន្នន័យជាក់ស្តែង ដែលទទួលបានពីស្រុក/ក្រុងទាំង ១១ ខាងលើ ចំនួនថ្នាក់សរុបមានត្រឹមតែ ១១៤៨ ថ្នាក់ប៉ុណ្ណោះ តិចជាងចំនួនថ្នាក់ គិតតាមនិយាម ៧៣ ថ្នាក់ (១២២១ថ្នាក់ ដកនឹង១១៤៨ថ្នាក់)។ នេះបញ្ជាក់ឱ្យឃើញថា ការប្រើប្រាស់និយាមសិស្សថ្នាក់របស់ស្រុក/ក្រុងទាំង ១១ មិនទាន់គោរពបាននូវនិយាម សិស្សថ្នាក់ ដែលកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡានៅឡើយ។ រីឯចំនួនគ្រូបង្រៀនដែលមានគុណវុឌ្ឍិកម្រិត មូលដ្ឋាន ហើយកំពុងបម្រើការងារនៅតាមអនុវិទ្យាល័យនានាក្នុងស្រុក/ក្រុងទាំង ១១ នោះវិញ មានចំនួន ២៤១៧ នាក់ លើសពីតម្រូវការតាមនិយាមចំនួន ២៤៦ នាក់ (២៤១៧នាក់ ដកនឹង ២១៧១) មានន័យថាលើសគ្រូបង្រៀនកម្រិតមូលដ្ឋាន ចំនួន ២៤៦ នាក់ បើអនុវត្តតាមនិយាមដែលកំណត់ដោយច្បាប់ និងលើសតម្រូវការដែលកំពុងអនុវត្តជាក់ស្តែងចំនួន ៣៧៦ នាក់ (១១៤៨គុណនឹង ៣២ ចែកនឹង១៨)។

*តារាងទី២៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែង នៅមធ្យមសិក្សាបឋមភូមិ (ខេត្តកណ្តាល)*

| ចំនួន | តាមជាក់ស្តែង | តាមនិយាម |
|---|---|---|
| សិស្ស | ៤៨៨៤៧ នាក់ | |
| ថ្នាក់ | ១១៤៨ ថ្នាក់ | ១២២១ ថ្នាក់ |
| ម៉ោង | ៣៦៧៣៦ ម៉ោង | ៣៩០៧៨ ម៉ោង |
| គ្រូ | ២០៤១ នាក់ | ២១៧១ នាក់ |
| គ្រូមានគុណវុឌ្ឍិក្របខណ្ឌ (ខ) | ២៤១៧ នាក់ | |

បើពិនិត្យឱ្យកាន់តែស៊ីជម្រៅតាមមុខវិជ្ជានីមួយៗ ក្នុងក្រាបទី១ខាងក្រោម ចំនួនគ្រូដែលគិតតាមនិយាម និងចំនួនគ្រូដែលកំពុងមានជាក់ស្តែង គឺមានមុខវិជ្ជាខ្លះខ្វះ និងមុខវិជ្ជាខ្លះលើសទៅវិញ។ តួយ៉ាងដូចមានបង្ហាញក្នុងក្រាបទី១ខាងក្រោម មុខវិជ្ជាគណិតវិទ្យាតាមនិយាមគឺត្រូវការចំនួន ៤០៧ នាក់ តែចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិតមូលដ្ឋានកំពុងបម្រើការក្នុងខេត្តសរុបគឺមានតែ ៣៤៣ នាក់ មុខវិជ្ជាសីលធម៌-ពលរដ្ឋ តាមនិយាមគឺត្រូវការចំនួន ១៣៦ នាក់ តែតាមចំនួនជាក់ ស្តែងគឺមានតែ ១១៤ នាក់ មុខវិជ្ជាបំណិនជីវិតមូលដ្ឋាន តាមនិយាមគឺត្រូវការចំនួន ១៣៦ នាក់ តែតាមចំនួនជាក់ ស្តែងគឺមានតែ ៥៩ នាក់ប៉ុណ្ណោះ។ ផ្ទុយទៅវិញចំពោះមុខវិជ្ជារូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ផែនដីវិទ្យា ភាសាបរទេស ភាសាខ្មែរ គេហវិទ្យា ប្រវត្តិវិទ្យា ភូមិវិទ្យា និងអប់រំកាយ-កីឡា ចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិតមូលដ្ឋានមានលើសពីតម្រូវការ។ ពោលតម្រូវការមានចំនួនតែ១៣៦, ៦៨, ១៣៦, ៦៨, ២៧១, ៤០៧, ៦៨, ៦៨, ១៣៦ និង១៣៦ តាមលំដាប់រៀងប៉ុណ្ណោះ ចំណែកឯគ្រូដែលមានគុណវុឌ្ឍិកម្រិតមូលដ្ឋានមានរហូតដល់១៨១, ៨៨, ១៨៦, ៨៧, ២៨៣, ៤៥២, ១១៩, ១៧៧, ១៤៣ និង ២១៧ តាមលំដាប់រៀងទៅវិញ។ នេះសបញ្ជាក់ថា ការផ្គត់ផ្គង់ និងការបែងចែកគ្រូបង្រៀនទៅតាមអនុវិទ្យាល័យក្នុងខេត្តកណ្តាល នៅមិនទាន់មានប្រសិទ្ធភាពនៅឡើយ ជាពិសេសមុខវិជ្ជា គេហវិទ្យា មុខវិជ្ជាប្រវត្តិវិទ្យា និងមុខវិជ្ជាអប់រំកាយ-កីឡា ចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិតមូលដ្ឋាន លើសពីតម្រូវការជាក់ស្តែងច្រើន។

*ក្រាបទី១៖ គុណវុឌ្ឍិគ្រូបង្រៀនកម្រិតមូលដ្ឋានតាមមុខវិជ្ជាគិតតាមនិយាម និងតាមតម្រូវការជាក់ស្តែង*




### ៤.១.៣. ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិ ក្នុងស្រុកទី១

ដូចមានបង្ហាញក្នុងតារាងទី៣ខាងក្រោម ស្រុកទី១ មានចំនួន ១៩សាលា មានស្ថិតិសិស្សសរុបចំនួន៤០៥១ នាក់។ តាមនិយាម ត្រូវមានថ្នាក់ចំនួន ១០១ ថ្នាក់ ស្មើនឹងម៉ោងបង្រៀនក្នុង១សប្តាហ៍ ៣២៤១ម៉ោង ដែលត្រូវប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋាន សម្រាប់គ្រប់មុខវិជ្ជាចំនួន ១៨០ នាក់។ ប៉ុន្តែតាមស្ថានភាពជាក់ស្តែង ស្រុកនេះមានគ្រូបង្រៀនដែលមានគុណវុឌ្ឍិកម្រិតនេះ ដល់ទៅចំនួន ៣០៦ នាក់ ដែលលើសពីតម្រូវការចំនួន ១២៦ នាក់ សម្រាប់សាលាទាំង១៩។ នេះបញ្ជាក់ឱ្យឃើញថា គ្រូបង្រៀនដែលមានគុណវុឌ្ឍិកម្រិតមូលដ្ឋាន នៅក្នុងស្រុកនេះ គឺមានចំនួនគ្រប់គ្រាន់។ បើពិនិត្យជាក់ស្តែងទៅលើអថេរទាំងបី៖ចំនួនថ្នាក់ ចំនួនម៉ោង និងចំនួនគ្រូបង្រៀនកម្រិតមូលដ្ឋាន ដែលស្រុកទី១ កំពុងអនុវត្ត និងប្រើប្រាស់ឃើញថា ថ្នាក់មានចំនួន ៩៦ ថ្នាក់ តិចជាងការគិតគួរតាមនិយាមចំនួន ៥ថ្នាក់ ម៉ោងមានចំនួន ៣០៧២ម៉ោង ក្នុង១សប្តាហ៍ តិចជាងចំនួនម៉ោងគិតតាមនិយាម ចំនួន ១៦៩ ម៉ោង។ រីឯគ្រូបង្រៀនកម្រិតមូលដ្ឋាន ដែលកំពុងបង្រៀន មានចំនួន ៣០៦នាក់ ពោលគឺនៅសល់ចំនួនប្រមាណ ១២៦ នាក់ និងលើសតម្រូវការដែលកំពុងអនុវត្តជាក់ស្តែងចំនួន ១៣៥ នាក់។ ស្ថានភាពនេះបង្ហាញឱ្យឃើញថា បើ

ទោះបីគ្រូបង្រៀនកម្រិតមូលដ្ឋាននៅក្នុងស្រុកទី១នេះ មានចំនួនគ្រប់គ្រាន់ក៏ដោយ ក៏ការប្រើប្រាស់និយាម សិស្សថ្នាក់លើសពីចំនួនកំណត់ នៅតែកំពុងអនុវត្ត ហើយការប្រើប្រាស់គ្រូបង្រៀននៅតែមិនទាន់មាន ប្រសិទ្ធភាពនៅឡើយ។

*តារាងទី៣៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែងក្នុងស្រុកទី១*

| ចំនួន | តាមជាក់ស្តែង | តាមនិយាម |
|---|---|---|
| សិស្ស | ៤០៥១ នាក់ | |
| ថ្នាក់ | ៩៦ ថ្នាក់ | ១០១ ថ្នាក់ |
| ម៉ោង | ៣០៧២ ម៉ោង | ៣២៤១ ម៉ោង |
| គ្រូ | ១៧១ នាក់ | ១៨០ នាក់ |
| គ្រូមានគុណវុឌ្ឍិក្របខណ្ឌ (ខ) | ៣០៦ នាក់ | |

ក្រាបទី២ខាងក្រោមបង្ហាញពី តម្រូវការគ្រូតាម និយាម និងចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិតមូលដ្ឋានលើមុខវិជ្ជាចំនួន ១៣ រួមមានគណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ផែនដីវិទ្យា ភាសាបរទេស ភាសាខ្មែរ សីលធម៌-ពលរដ្ឋ គេហវិទ្យា ប្រវត្តិវិទ្យា ភូមិវិទ្យា អប់រំកាយ-កីឡា និងបំណិនជីវិតមូលដ្ឋាន សម្រាប់ស្រុកទី១។ តាមរយៈក្រាបនេះបង្ហាញឱ្យឃើញថា មានតែមុខវិជ្ជាគណិតវិទ្យា ភូមិវិទ្យា និងបំណិនជីវិតមូលដ្ឋាន ចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិតមូលដ្ឋាន តិចជាងតម្រូវការតាមនិយាម។ ចំពោះមុខវិជ្ជារូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ផែនដីវិទ្យា ភាសាបរទេស ភាសាខ្មែរ សីលធម៌-ពលរដ្ឋ គេហវិទ្យា ប្រវត្តិវិទ្យា និងអប់រំកាយ-កីឡា ចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិតមូលដ្ឋានគឺលើសពីតម្រូវការ។ នេះស្តែងឱ្យឃើញថាប្រសិទ្ធភាពនៃការបែងចែក និងប្រើប្រាស់គ្រូនៅក្នុងស្រុកទី១នេះនៅមានកម្រិត។

*ក្រាបទី២៖ គុណវុឌ្ឍិគ្រូបង្រៀនកម្រិតមូលដ្ឋាននៃមុខវិជ្ជានីមួយៗគិតតាមនិយាម និងតាមតម្រូវការជាក់ស្តែងក្នុងស្រុកទី១*




ការសិក្សានេះក៏បានពិនិត្យសាលានីមួយៗផងដែរ នូវចំនួនគ្រូបង្រៀនតាមមុខវិជ្ជាទាំង១៣មុខវិជ្ជាខាងលើ ដើម្បីធ្វើការប្រៀបធៀបចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិតមូលដ្ឋានធៀបទៅនឹងចំនួនតម្រូវការគ្រូគិតតាមនិយាម។ ជាលទ្ធផលបានបង្ហាញឱ្យឃើញថា មានសាលាខ្លះលើសគ្រូបង្រៀនកម្រិតមូលដ្ឋានលើមុខវិជ្ជាខ្លះ រីឯសាលា ខ្លះទៀតខ្វះគ្រូបង្រៀនលើមុខវិជ្ជានោះ និងសាលាខ្លះមានគ្រូបង្រៀនគ្រប់ចំនួន។ តួយ៉ាងដូចជាមុខវិជ្ជាគណិតវិទ្យានៅក្នុងសាលាទី១នៃស្រុកនេះ តម្រូវការមាន០៣នាក់ ប៉ុន្តែគ្រូដែលមានគុណវុឌ្ឍិកម្រិតមូលដ្ឋានមាន១០នាក់។ សាលាទី២ តម្រូវការមាន០១នាក់ គ្រូមាន០៥នាក់ សាលាទី៥ តម្រូវការមាន០២នាក់ គ្រូមាន០៣នាក់ សាលាទី១១ តម្រូវការមាន០១នាក់ គ្រូមាន០២នាក់ សាលាទី១២ តម្រូវការមាន០១នាក់ គ្រូមាន០៣នាក់ និងសាលាទី១៥ តម្រូវការមាន០២នាក់ គ្រូមាន០៥នាក់។ ផ្ទុយទៅវិញ សម្រាប់មុខវិជ្ជាគណិតវិទ្យាដដែល សាលាទី៣មានតម្រូវការ០៣នាក់ ប៉ុន្តែគ្រូដែលមាន គុណវុឌ្ឍិកម្រិតមូលដ្ឋាននៅក្នុងសាលានេះគ្មានម្នាក់ទាល់តែសោះ។ ដូចគ្នាដែរ សាលាទី១០ ១៣ និង ១៩ គឺមិនទាន់មានគ្រូដែលមានគុណវុឌ្ឍិកម្រិតមូលដ្ឋានគណិតវិទ្យានៅឡើយទេ។ សាលាទី០៧ តម្រូវការមាន០៣នាក់ ប៉ុន្តែគ្រូមានតែ០២នាក់ សាលាទី០៩ តម្រូវការមាន០២នាក់ ប៉ុន្តែគ្រូមានតែ០១នាក់ និងសាលា

ទី១៧ តម្រូវការមាន០៣នាក់ ប៉ុន្តែគ្រូមានតែ០១នាក់ ដូចមានបង្ហាញក្នុងក្រាបទី៣។ រីឯសាលាក្រៅពីនេះ គឺមានគ្រូមុខវិជ្ជាគណិតវិទ្យាគ្រប់គ្រាន់។ លទ្ធផលនេះបានបង្ហាញឱ្យឃើញថាការបែងចែកគ្រូទៅតាមអនុវិទ្យាល័យនៅក្នុងស្រុកនេះ មិនទាន់គិតគូរបានត្រឹមត្រូវនោះទេ។ កត្តានេះបណ្តាលឱ្យការគ្រប់គ្រងរបស់នាយកសាលា អាចមិនមានប្រសិទ្ធភាព ឬអាចបណ្តាលឱ្យជះឥទ្ធិពលមិនល្អ ទៅដល់គុណភាពនៃការអប់រំ។

*ក្រាបទី៣៖ តម្រូវការគ្រូបង្រៀនមានគុណវុឌ្ឍិកម្រិតមូលដ្ឋានតាមមុខវិជ្ជានិងតាមអនុវិទ្យាល័យនីមួយៗក្នុងស្រុកទី១*




## ៤.១.៤. ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិ ក្នុងស្រុកទី២

តារាងទី៤ខាងក្រោម បង្ហាញពីសំណាកដែលត្រូវបានជ្រើសរើសក្នុងស្រុកទី២ មានចំនួន ៨ សាលា មានស្ថិតិសិស្សសរុបចំនួន៤៩៥៦ នាក់ តាមនិយាមត្រូវមានថ្នាក់ចំនួន ១២៤ ថ្នាក់ ស្មើនឹងម៉ោងបង្រៀនក្នុង១សប្តាហ៍ ចំនួន ៣៩៦៥ ម៉ោង ដែលត្រូវប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋានចំនួន ២២០ នាក់។ តាមស្ថិតិជាក់ស្តែងស្រុកនេះមានគ្រូបង្រៀនកម្រិតមូលដ្ឋានចំនួន ២៥១ នាក់ គឺលើសពីតម្រូវការចំនួន ៣១ នាក់។ នេះបញ្ជាក់ឱ្យឃើញថា ការបែងចែកគ្រូបង្រៀននៅក្នុងស្រុកទី២មិនទាន់មានប្រសិទ្ធភាពនៅឡើយ។ ប៉ុន្តែបើពិនិត្យជាក់ស្តែងទៅលើអថេរទាំងបី៖ចំនួនថ្នាក់ ចំនួនម៉ោង និងចំនួនគ្រូបង្រៀន

កម្រិតមូលដ្ឋានដែលស្រុកទី២ កំពុងអនុវត្ត និងប្រើប្រាស់ឃើញថា ថ្នាក់មានចំនួនតែ ១១៩ ថ្នាក់ តិចជាងការគិតគូរតាមនិយាមចំនួន៥ថ្នាក់ ម៉ោងមានចំនួន ៣៨០៨ ម៉ោង ក្នុង១សប្តាហ៍ តិចជាងចំនួនម៉ោងគិតតាមនិយាម ចំនួន ១៥៧ ម៉ោង។ ស្ថានភាពនេះបង្ហាញឱ្យឃើញថាបើទោះបីគ្រូបង្រៀនកម្រិតមូលដ្ឋាននៅក្នុងស្រុកទី២នេះ មានចំនួនលើសពីតម្រូវការក៏ដោយ ក៏ការប្រើប្រាស់និយាមសិស្សថ្នាក់លើសពីចំនួនកំណត់ នៅតែកំពុងអនុវត្ត ហើយការប្រើប្រាស់គ្រូបង្រៀននៅតែមិនទាន់មានប្រសិទ្ធភាពនៅឡើយ។

*តារាងទី៤៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែងក្នុងស្រុកទី២*

| ចំនួន | តាមជាក់ស្តែង | តាមនិយាម |
|---|---|---|
| សិស្ស | ៤៩៥៦ នាក់ | |
| ថ្នាក់ | ១១៩ ថ្នាក់ | ១២៤ ថ្នាក់ |
| ម៉ោង | ៣៨០៨ ម៉ោង | ៣៩៦៥ ម៉ោង |
| គ្រូ | ២១២ នាក់ | ២២០ នាក់ |
| គ្រូមានគុណវុឌ្ឍិក្របខណ្ឌ (ខ) | ២៥១ នាក់ | |

ក្រាបទី៤ខាងក្រោមបង្ហាញពី តម្រូវការគ្រូតាមនិយាម និងចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិតមូលដ្ឋានលើមុខវិជ្ជាចំនួនទាំង១៣ រួមមានគណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ផែនដីវិទ្យា ភាសាបរទេស ភាសាខ្មែរ សីលធម៌-ពលរដ្ឋ គេហវិទ្យា ប្រវត្តិវិទ្យា ភូមិវិទ្យា អប់រំកាយ-កីឡា និងបំណិនជីវិតមូលដ្ឋាន។ តាមរយៈក្រាបនេះបង្ហាញឱ្យឃើញថា មុខវិជ្ជារូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ផែនដីវិទ្យា ភាសាខ្មែរ សីលធម៌-ពលរដ្ឋ គេហវិទ្យា ប្រវត្តិវិទ្យា និងអប់រំកាយ-កីឡា ចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិតមូលដ្ឋានគឺលើសពីតម្រូវការ គណនាតាមនិយាម។ រីឯមុខវិជ្ជាគណិតវិទ្យា ភាសាបរទេស ភូមិវិទ្យា និងបំណិនជីវិតមូលដ្ឋានមានចំនួនគ្រូមានគុណវុឌ្ឍិកម្រិតមូលដ្ឋានតិចជាងតម្រូវការ។ នេះស្តែងឱ្យឃើញថា ប្រសិទ្ធភាពនៃការបែងចែក និងប្រើប្រាស់គ្រូនៅក្នុងស្រុកទី២នេះនៅមានកម្រិត។

*ក្រាបទី៤៖ គុណវុឌ្ឍិគ្រូបង្រៀនកម្រិតមូលដ្ឋាននៃមុខវិជ្ជានីមួយៗគិតតាមនិយាម និងតាមតម្រូវការជាក់ស្តែងក្នុងស្រុកទី២*




ការសិក្សាក៏បានពិនិត្យសាលានីមួយៗក្នុងស្រុកទី២នេះផងដែរពីចំនួនគ្រូបង្រៀនតាមមុខវិជ្ជាទាំង ១៣ ដូចក្នុងករណីនៃស្រុកទី១ដែរ។ ជាលទ្ធផលបានបង្ហាញឱ្យឃើញថា មានសាលាខ្លះលើសគ្រូបង្រៀនកម្រិតមូលដ្ឋាន រីឯសាលាខ្លះទៀតបែរជាខ្វះគ្រូទៅវិញ ហើយក៏មានសាលាខ្លះមានគ្រូបង្រៀនគ្រប់ចំនួន។ តួយ៉ាងដូចជាមុខវិជ្ជារូបវិទ្យា តម្រូវការសម្រាប់សាលាទី១មានចំនួន០៣នាក់ តែគ្រូបង្រៀនកម្រិតមូលដ្ឋានមានចំនួន៧នាក់ សាលាទី២មានតម្រូវការ០១នាក់គ្រូបង្រៀនកម្រិតមូលដ្ឋានមានចំនួន០៣នាក់ និងសាលាទី៥ មានតម្រូវការ០២នាក់ គ្រូបង្រៀនកម្រិតមូលដ្ឋានមានចំនួន០៤នាក់។ ផ្ទុយទៅវិញ ចំពោះមុខវិជ្ជារូបវិទ្យាដដែល សម្រាប់ សាលាទី៦ តម្រូវការគ្រូមាន២នាក់ ប៉ុន្តែគ្រូដែលមានកម្រិតមូលដ្ឋាន មានចំនួនតែ ១ នាក់ ប៉ុណ្ណោះ ដូចមានបង្ហាញក្នុងក្រាបទី៥ខាងក្រោម។ លទ្ធផលនេះបានបង្ហាញឱ្យឃើញថា ការបែងចែកគ្រូទៅតាមអនុវិទ្យាល័យនៅក្នុងស្រុកនេះ មិនទាន់គិតគូរបានត្រឹមត្រូវនោះទេ។ កត្តានេះបណ្តាលឱ្យការគ្រប់គ្រងរបស់នាយកសាលា អាចមិនមានប្រសិទ្ធភាព ឬអាចបណ្តាលឱ្យជះឥទ្ធិពលមិនល្អ ទៅដល់គុណភាពនៃការអប់រំ។

*ក្រាបទី៥៖ តម្រូវការគ្រូបង្រៀនមានគុណវុឌ្ឍិកម្រិតមូលដ្ឋានតាមមុខវិជ្ជានិងតាមអនុវិទ្យាល័យនីមួយៗ ក្នុងស្រុកទី២*




## ៤.១.៥. ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិ ក្នុងស្រុកទី៣

ចំនួនអនុវិទ្យាល័យដែលជាសំណាកក្នុងស្រុកទី៣ មានចំនួន ១៨ មានសិស្សសរុបចំនួន ៦៤៧០ នាក់ ត្រូវមានថ្នាក់សរុបគិតតាមនិយាមចំនួន ១៦២ ថ្នាក់ ស្មើនឹងម៉ោងបង្រៀនក្នុង១សប្តាហ៍ ៥១៧៦ ម៉ោង ដែលត្រូវប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋានចំនួន ២៨៨ នាក់ដូចមានបង្ហាញក្នុងតារាងទី៥។ ប៉ុន្តែតាមស្ថានភាពជាក់ស្តែង ស្រុកនេះមានថ្នាក់ចំនួន១៤៣ថ្នាក់ តិចជាងតាមនិយាមចំនួន១៩ថ្នាក់ មានម៉ោងសិស្សរៀនជាក់ស្តែងក្នុង១សប្តាហ៍ចំនួន ៤៥៧៦ម៉ោង តិចជាងម៉ោងដែលត្រូវប្រើតាមនិយាម៦០០ម៉ោង និងមានគ្រូបង្រៀនកម្រិតមូលដ្ឋាន ចំនួន២៥៥នាក់ តិចជាងគិតតាមនិយាមចំនួន៣៣នាក់។ លទ្ធផលនេះបង្ហាញឱ្យឃើញថា ការប្រើប្រាស់និយាមសិស្សថ្នាក់គឺលើសពីនិយាមកំណត់ដោយច្បាប់ ធ្វើឱ្យចំនួនថ្នាក់រៀន និងម៉ោងរៀនសរុបក្នុងមួយសប្តាហ៍ថយចុះ។ ចំណែកឯការប្រើប្រាស់គ្រូ បើពិនិត្យមើលជារួមវិញគឺមានលក្ខណៈសមស្រប ព្រោះគ្រូដែលកំពុងបង្រៀនជាក់ស្តែងមានចំនួន២៥៤នាក់ ធៀបទៅនឹងគ្រូបង្រៀនកម្រិតមូលដ្ឋាន ដែលស្រុកនេះមាន២៥៥នាក់ ដូចបង្ហាញក្នុងតារាងទី៥។ ប៉ុន្តែដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់ពីប្រសិទ្ធភាពនៃការប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋាននៅក្នុងស្រុកនេះ អ្នកស្រាវជ្រាវ

បានពិនិត្យទៅលើចំនួនគ្រូបង្រៀនកម្រិតមូលដ្ឋានលើមុខវិជ្ជាចំនួន១៣ ដូចក្នុងករណីនៃស្រុកទាំងបីខាងលើដែរហើយបានរកឃើញនូវលទ្ធផលដូចមានបង្ហាញ ក្នុងក្រាបទី៦។

*តារាងទី៥៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែងក្នុងស្រុកទី៣*

| ចំនួន | តាមជាក់ស្តែង | តាមនិយាម |
|---|---|---|
| សិស្ស | ៦៤៧០ នាក់ | |
| ថ្នាក់ | ១៤៣ ថ្នាក់ | ១៦២ ថ្នាក់ |
| ម៉ោង | ៤៥៧៦ ម៉ោង | ៥១៧៦ ម៉ោង |
| គ្រូ | ២៥៤ នាក់ | ២៨៨ នាក់ |
| គ្រូមានគុណវុឌ្ឍិក្របខណ្ឌ (ខ) | ២៥៥ នាក់ | |

*ក្រាបទី៦៖ គុណវុឌ្ឍិគ្រូបង្រៀនកម្រិតមូលដ្ឋាននៃមុខវិជ្ជានីមួយៗគិតតាមនិយាម និងតាមតម្រូវការជាក់ស្តែងក្នុងស្រុកទី៣*




តាមរយៈក្រាបទី៦ខាងលើនេះបង្ហាញថា មុខវិជ្ជាគីមីវិទ្យា ជីវវិទ្យា ភាសាខ្មែរ គេហវិទ្យា ប្រវត្តិវិទ្យា និងភូមិវិទ្យា តម្រូវការមានតែ៩នាក់, ១៨នាក់, ៥៤នាក់, ៩នាក់, ៩នាក់, និង១៨នាក់តែប៉ុណ្ណោះ ប៉ុន្តែគ្រូបង្រៀនដែលមានគុណវុឌ្ឍិកម្រិតមូលដ្ឋានលើមុខវិជ្ជាទាំងនេះមានរហូតដល់១២នាក់, ១៨នាក់, ៥៧នាក់

, ១៦នាក់, ៣២នាក់, និង២៤នាក់តាមលំដាប់រៀងទៅវិញ។ ផ្ទុយទៅវិញមុខវិជ្ជាគណិតវិទ្យា រូបវិទ្យា ភាសាបរទេស សីលធម៌-ពលរដ្ឋ អប់រំកាយ-កីឡា និងបំណិនជីវិតមូលដ្ឋាន គ្រូបង្រៀនដែលមានគុណវុឌ្ឍិកម្រិតមូលដ្ឋានមានតែ ២៩នាក់, ១៤នាក់, ១៤នាក់, ១០នាក់, ១៤នាក់, និង ២នាក់ តែតម្រូវការមានរហូតដល់ ៥៤នាក់, ១៨នាក់, ៣៦នាក់, ១៨នាក់, ១៨នាក់, និង១៨នាក់ តាមលំដាប់រៀង។ ចំពោះមុខវិជ្ជាផែនដីវិទ្យាមានចំនួនគ្រូមានគុណវុឌ្ឍិកម្រិតមូលដ្ឋានគ្រប់គ្រាន់តាមតម្រូវការ។ នេះស្តែងឱ្យឃើញថា ប្រសិទ្ធភាពនៃការបែងចែក និងប្រើប្រាស់គ្រូនៅក្នុងស្រុកទី៣នេះនៅមានកម្រិត។ នេះស្តែងឱ្យឃើញថា ប្រសិទ្ធភាពនៃការបែងចែក និងប្រើប្រាស់គ្រូនៅក្នុងស្រុកទី៣នេះបើទោះបីគិតជារួមមានគ្រូបង្រៀនកម្រិតមូលដ្ឋានគ្រប់គ្រាន់ក៏ដោយ ក៏នៅមានតែមានបញ្ហាខ្លាំងដែរ ព្រោះមុខវិជ្ជាខ្លះគឺនៅមានតម្រូវការច្រើន ដូចជាគណិតវិទ្យាជាដើម និងមុខវិជ្ជាខ្លះទៀតគឺលើសតម្រូវការច្រើន តួយ៉ាងមានមុខវិជ្ជាប្រវត្តិវិទ្យាជាដើម។

ដើម្បីស្វែងយល់ឱ្យកាន់តែស៊ីជម្រៅជាងនេះទៅទៀត អ្នកស្រាវជ្រាវក៏បានធ្វើការប្រៀបធៀបផងដែរទៅលើចំនួនគ្រូតាមឯកទេសទាំង ១៣ ខាងលើដែលសាលានីមួយៗមាន ធៀបទៅនឹងតម្រូវការជាក់ស្តែង ហើយបានរកឃើញដូចមានបង្ហាញក្នុងក្រាបទី៧។

*ក្រាបទី៧៖ តម្រូវការគ្រូបង្រៀនមានគុណវុឌ្ឍិកម្រិតមូលដ្ឋានតាមមុខវិជ្ជានិងតាមអនុវិទ្យាល័យនីមួយៗក្នុងស្រុកទី៣*



តាមរយៈលទ្ធផលដែលបង្ហាញក្នុងក្រាបទី៧ ក៏ដូចជាក្នុងករណីនៃខេត្តទាំងបីខាងលើដែរ របាយគ្រូបង្រៀនកម្រិតមូលដ្ឋាននៅតាមសាលានីមួយៗក្នុងស្រុកទី៣នេះ មិនទាន់មានភាពត្រឹមត្រូវនៅឡើយទេ ពោលសាលាខ្លះខ្វះគ្រូច្រើន តែក៏មានសាលាខ្លះលើសគ្រូដែលមានឯកទេសដូចគ្នានេះច្រើនផងដែរ។ តួយ៉ាងដូចជាមុខវិជ្ជាគណិតវិទ្យានៅក្នុងសាលាទី២ សាលាទី៣ សាលាទី៤ សាលាទី៥ សាលាទី៦ សាលាទី៨ សាលាទី១០ សាលាទី១២ សាលាទី១៣ សាលាទី១៤ សាលាទី១៥ សាលាទី១៧ និងសាលាទី១៨ មានចំនួនគ្រូកម្រិតមូលដ្ឋាន លើសពីតម្រូវការជាក់ស្តែង។ ផ្ទុយទៅវិញ សាលាទី១១ បែជាខ្វះគ្រូឯកទេសនេះទៅវិញ។ រីឯសាសាផ្សេងៗទៀតគឺមានគ្រូកម្រិតមូលដ្ឋានមុខវិជ្ជាគណិតវិទ្យាគ្រប់គ្រាន់ ។ ចំពោះមុខវិជ្ជាភាសាខ្មែរ សាលាទី១ សាលាទី៥ សាលាទី៦ សាលាទី៩ សាលាទី១០ និងសាលាទី១៤ លើសគ្រូបង្រៀនកម្រិតគ្រូកម្រិតមូលដ្ឋាន រីឯសាលាទី៣ ទី៧ ទី៨ ទី១២ និងទី១៧ គឺនៅតែខ្វះគ្រូឯកទេសនេះ ។

### ៤.១.៦. ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិ ក្នុងស្រុកទី៤

ក្នុងស្រុកទី៤ មានចំនួន ១២សាលា មានស្ថិតិសិស្សសរុបចំនួន ៥០៤៩ នាក់។ តាមនិយាម ត្រូវមានថ្នាក់ចំនួន ១២៦ ថ្នាក់ ស្មើនឹងម៉ោងបង្រៀនក្នុង១សប្តាហ៍ ៤០៣៩ ម៉ោង ដែលត្រូវប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋាន សម្រាប់គ្រប់មុខវិជ្ជាចំនួន ២២៤ នាក់ដូចមានបង្ហាញក្នុងតារាងទី៦។ ប៉ុន្តែតាមស្ថានភាពជាក់ស្តែង ស្រុកនេះមានគ្រូបង្រៀនដែលមានគុណវុឌ្ឍិកម្រិតនេះ ត្រឹមតែ ១៦៤ នាក់ ដែលតិចជាងតម្រូវការចំនួន ៦០ នាក់ សម្រាប់សាលាទាំង ១២។ បើពិនិត្យជាក់ស្តែងទៅលើអថេរទាំងបី៖ ចំនួនថ្នាក់ ចំនួនម៉ោង និងចំនួនគ្រូបង្រៀនកម្រិតមូលដ្ឋាន ដែលស្រុកទី៤ កំពុងអនុវត្ត និងប្រើប្រាស់ឃើញថា ថ្នាក់មានចំនួន ១០៩ ថ្នាក់ តិចជាងការគិតគូរតាមនិយាមចំនួន ១៧ថ្នាក់ ម៉ោងមានចំនួន ៣៤៨៨ម៉ោងក្នុង១សប្តាហ៍ តិចជាងចំនួនម៉ោងគិតតាមនិយាម ចំនួន ៥៥១ ម៉ោង។ រីឯគ្រូបង្រៀនកម្រិតមូលដ្ឋានដែលកំពុងបង្រៀនមានចំនួន ១៦៤នាក់ ពោលគឺនៅខ្វះចំនួនប្រមាណ ៦០ នាក់ និងតិចជាងតម្រូវការដែលកំពុងអនុវត្តជាក់ស្តែងចំនួន ៣០ នាក់ ។ លទ្ធផលនេះបង្ហាញឱ្យឃើញថា ការប្រើប្រាស់និយាមសិស្សថ្នាក់គឺលើសពីនិយាមកំណត់ដោយច្បាប់ ធ្វើឱ្យចំនួនថ្នាក់រៀនថយចុះ និងចំនួនម៉ោងដែលត្រូវបង្រៀន

និងរៀនជាក់ស្តែងក៏ថយចុះដែរ។ ចំណែកឯការប្រើប្រាស់គ្រូបង្រៀនវិញនៅតែមានការប្រើប្រាស់គ្រូបង្រៀន ដែលមានកម្រិតគុណវុឌ្ឍិទាបជាងកម្រិតមូលដ្ឋានរហូតទៅដល់ ៣០នាក់។

*តារាងទី៦៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែងក្នុងស្រុកទី៤*

| ចំនួន | តាមជាក់ស្តែង | តាមនិយាម |
|---|---|---|
| សិស្ស | ៥០៤៩ នាក់ | |
| ថ្នាក់ | ១០៩ ថ្នាក់ | ១២៦ ថ្នាក់ |
| ម៉ោង | ៣៤៨៨ ម៉ោង | ៤០៣៩ ម៉ោង |
| គ្រូ | ១៩៤នាក់ | ២២៤ នាក់ |
| គ្រូមានគុណវុឌ្ឍិក្របខណ្ឌ (ខ) | ១៦៤ នាក់ | |

តាមរយៈក្រាបទី៩ខាងក្រោមនេះបង្ហាញឱ្យឃើញថា មុខវិជ្ជារូបវិទ្យា ប្រវត្តិវិទ្យា និងភូមិវិទ្យា តម្រូវការមានតែ៩នាក់, ១៤នាក់, ៧នាក់ និង១៤នាក់តែប៉ុណ្ណោះ ប៉ុន្តែគ្រូបង្រៀនដែលមានគុណវុឌ្ឍិកម្រិតមូលដ្ឋានលើមុខវិជ្ជាទាំងនេះមានរហូតដល់១៨នាក់, ១៣នាក់, និង១៦នាក់តាមលំដាប់រៀងទៅវិញ។ ផ្ទុយទៅវិញមុខវិជ្ជាគណិតវិទ្យា គីមីវិទ្យា ជីវវិទ្យា ផែនដីវិទ្យា ភាសាបរទេស ភាសខ្មែរ អប់រំកាយ-កីឡា និងបំណិនជីវិតមូលដ្ឋាន គ្រូបង្រៀនដែលមានគុណវុឌ្ឍិកម្រិតមូលដ្ឋានមានតែ ៣៦នាក់, ០៤នាក់, ១០នាក់, ០៤នាក់, ១២នាក់, ៣០នាក់, ០៧នាក់, ០៦នាក់ និង ០១នាក់ តែតម្រូវការមានរហូតដល់ ៤២នាក់, ០៧នាក់, ១៤នាក់, ០៧នាក់, ២៨នាក់, ៤២នាក់, ១៤នាក់, ១៤នាក់, និង១៤នាក់ តាមលំដាប់រៀង ។ ចំពោះមុខវិជ្ជាគេហវិទ្យាមានចំនួនគ្រូមានគុណវុឌ្ឍិកម្រិតមូលដ្ឋានគ្រប់គ្រាន់តាមតម្រូវការ។ នេះស្តែងឱ្យឃើញថា ប្រសិទ្ធភាពនៃការបែងចែក និងប្រើប្រាស់គ្រូគុណវុឌ្ឍិកម្រិតមូលដ្ឋាននៅក្នុងស្រុកទី៤នេះ មិនទាន់បានគ្រប់គ្រាន់ទេ ដែលធ្វើឱ្យសាលាភាគច្រើនជួបប្រទះនូវការខ្វះគ្រូជាមិនខាន ។

*ក្រាបទី៨៖ គុណវុឌ្ឍិគ្រូបង្រៀនកម្រិតមូលដ្ឋាននៃមុខវិជ្ជានីមួយៗគិតតាមនិយាម និងតាមតម្រូវការជាក់ស្តែងក្នុងស្រុកទី៤*




តាមរយៈលទ្ធផលដែលបង្ហាញក្នុងក្រាបទី៨ខាងក្រោម ក៏ដូចជាក្នុងករណីនៃស្រុកទាំងបីខាងលើដែរ របាយគ្រូបង្រៀនកម្រិតមូលដ្ឋាននៅតាមសាលានីមួយៗក្នុងស្រុកទី៤នេះមិនទាន់មានភាពត្រឹមត្រូវទេ ពេលសាលាខ្លះខ្វះគ្រូច្រើនតែក៏មានសាលាខ្លះលើសគ្រូដែលមានឯកទេសដូចគ្នានេះផងដែរ។ តួយ៉ាងដូចជាមុខវិជ្ជាគណិតវិទ្យានៅក្នុងសាលាទី១នៃស្រុកនេះ តម្រូវការមាន០៤នាក់ ប៉ុន្តែគ្រូដែលមានគុណវុឌ្ឍិកម្រិតមូលដ្ឋានមាន០៧នាក់។ សាលាទី២ តម្រូវការមាន០៣នាក់ គ្រូមាន០៤នាក់ សាលាទី៩ តម្រូវការមាន០៣នាក់ គ្រូមាន០៤នាក់ និងសាលាទី១០ តម្រូវការមាន០២នាក់ គ្រូមាន០៤នាក់។ ផ្ទុយទៅវិញសម្រាប់មុខវិជ្ជាគណិតវិទ្យាដដែល សាលាទី៣មានតម្រូវការ០៣នាក់ ប៉ុន្តែគ្រូដែលមាន គុណវុឌ្ឍិកម្រិតមូលដ្ឋាននៅក្នុងសាលានេះមានតែ០២នាក់ សាលាទី០៤ តម្រូវការមាន០៩នាក់ ប៉ុន្តែគ្រូមានតែ០៣នាក់ សាលាទី០៥ តម្រូវការមាន០៦នាក់ ប៉ុន្តែគ្រូមានតែ០៤នាក់ សាលាទី០៧ តម្រូវការមាន០២នាក់ ប៉ុន្តែគ្រូមានតែ០១នាក់ និងសាលាទី១១ តម្រូវការមាន០៣នាក់ ប៉ុន្តែគ្រូមានតែ០២នាក់ ។រីឯសាលាក្រៅពីនេះគឺមានគ្រូមុខវិជ្ជាគណិតវិទ្យាគ្រប់គ្រាន់។ លទ្ធផលនេះបានបង្ហាញថាការបែងចែកគ្រូទៅតាម អនុវិទ្យាល័យ

នៅក្នុងស្រុកនេះមិនទាន់គិតគូរបានត្រឹមត្រូវនោះទេ។ កត្តានេះបណ្តាលឱ្យការគ្រប់គ្រងរបស់នាយកសាលាអាចមិនមានប្រសិទ្ធភាព ឬអាចបណ្តាលឱ្យជះឥទ្ធិពលមិនល្អទៅដល់គុណភាពនៃការអប់រំ។

*ក្រាបទី៩៖ តម្រូវការគ្រូបង្រៀនមានគុណវុឌ្ឍិកម្រិតមូលដ្ឋានតាមមុខវិជ្ជានិងតាមអនុវិទ្យាល័យនីមួយៗក្នុងស្រុកទី៤*




## ៤.១.៧. ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិ ក្នុងស្រុកទី៥

សំណាកដែលត្រូវបានជ្រើសរើសក្នុងស្រុកទី៥ មានចំនួន៧អនុវិទ្យាល័យ មានស្ថិតិសិស្សសរុបចំនួន ១៩៩១នាក់ តាមនិយាមត្រូវមានថ្នាក់ចំនួន ៥០ថ្នាក់ ស្មើនឹងម៉ោងបង្រៀន ១៥៩៣ ម៉ោងក្នុង ១ សប្តាហ៍ ដែលត្រូវប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋានចំនួន ៨៨នាក់។ ប៉ុន្តែតាមស្ថានភាពជាក់ស្តែងស្រុកនេះមានថ្នាក់ចំនួន ៤៨ ថ្នាក់ តិចជាងនិយាមចំនួន ២ ថ្នាក់ មានម៉ោងសិស្សរៀនជាក់ស្តែងក្នុង ១ សប្តាហ៍ចំនួន ១៥៣៦ ម៉ោង តិចជាងម៉ោងដែលត្រូវប្រើតាមនិយាមចំនួន ៥៧ម៉ោង និងមានគ្រូបង្រៀនកម្រិតមូលដ្ឋានចំនួន ៩១នាក់ លើសនិយាមចំនួន ០៣នាក់។ រីឯការប្រើប្រាស់គ្រូបង្រៀនជាក់ស្តែង ដែលកំពុងអនុវត្តនៅក្នុងស្រុកនេះ គឺមាន ៨៥នាក់ តិចជាងគ្រូបង្រៀនកម្រិតមូលដ្ឋាន ចំនួន ០៦នាក់។ ចំណែកឯការប្រើប្រាស់គ្រូ បើពិនិត្យមើលជារួមវិញគឺមានលក្ខណៈសមស្រប ព្រោះគ្រូដែលកំពុងបង្រៀន

ជាក់ស្តែងមានចំនួន៨៥នាក់ ធៀបទៅនឹងគ្រូបង្រៀនកម្រិតមូលដ្ឋាន ដែលស្រុកនេះមាន៩១នាក់ ដូចបង្ហាញក្នុងតារាងទី៧។

*តារាងទី៧៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែងក្នុងស្រុកទី៥*

| ចំនួន | តាមជាក់ស្តែង | តាមនិយាម |
|---|---|---|
| សិស្ស | ១៩៩១ នាក់ | |
| ថ្នាក់ | ៤៨ ថ្នាក់ | ៥០ ថ្នាក់ |
| ម៉ោង | ១៥៣៦ ម៉ោង | ១៥៩៣ ម៉ោង |
| គ្រូ | ៨៥ នាក់ | ៨៨ នាក់ |
| គ្រូមានគុណវុឌ្ឍិក្របខណ្ឌ (ខ) | ៩១ នាក់ | |

ក្រាបទី១០ខាងក្រោមបង្ហាញពី តម្រូវការគ្រូតាមនិយាម និង ចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិតមូលដ្ឋាន លើមុខវិជ្ជាចំនួន១៣ រួមមានគណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ផែនដីវិទ្យា ភាសាបរទេស ភាសាខ្មែរ សីលធម៌-ពលរដ្ឋ គេហវិទ្យា ប្រវត្តិវិទ្យា ភូមិវិទ្យា អប់រំកាយ-កីឡា និងបំណិនជីវិតមូលដ្ឋាន សម្រាប់ស្រុកទី៥ ដូចក្នុងករណីនៃស្រុកទី១ ទី២ ទី៣ និងទី៤ដែរ។ តាមរយៈក្រាបនេះ បង្ហាញឱ្យឃើញថាមុខវិជ្ជាគីមីវិទ្យា ជីវវិទ្យា ផែនដីវិទ្យា ភាសាខ្មែរ ប្រវត្តិវិទ្យា អប់រំកាយ-កីឡា និងបំណិនជីវិតមូលដ្ឋាន ដែលមានចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិតមូលដ្ឋាន លើសពីតម្រូវការតាមនិយាម ពោលគឺ តម្រូវការមាន ០៣នាក់, ០៦នាក់, ០៣នាក់, ១៧នាក់, ០៣នាក់, ០៦នាក់, និង០៦នាក់ តាមលំដាប់រៀង តែគ្រូបង្រៀនជាក់ស្តែងមាន០៤នាក់, ០៨នាក់, ០៤នាក់, ១៩នាក់, ០៥នាក់, ១៣នាក់ និង ០៧នាក់។ ផ្ទុយទៅវិញមុខវិជ្ជាគណិតវិទ្យា រូបវិទ្យា ភាសាបរទេស សីលធម៌-ពលរដ្ឋ គេហវិទ្យា និងភូមិវិទ្យា ចំនួនគ្រូបង្រៀនដែលមានគុណវុឌ្ឍិកម្រិតមូលដ្ឋានមាន ១៣, ០៥, ០៧, ០១, ០០, និង ០៥ តាមលំដាប់រៀង ប៉ុន្តែតម្រូវការមាន ១៧, ០៦, ១១, ០៦, ០៣, និង ០៦។ នេះស្តែងឱ្យឃើញថា ប្រសិទ្ធភាពនៃការបែងចែក និងប្រើប្រាស់គ្រូបង្រៀននៅក្នុងស្រុកទី៥នេះ មិនទាន់មានលក្ខណៈសមស្របនៅឡើយ។

*ក្រាបទី១០៖ គុណវុឌ្ឍិគ្រូបង្រៀនកម្រិតមូលដ្ឋាននៃមុខវិជ្ជានីមួយៗគិតតាមនិយាម និងតាមតម្រូវការជាក់ស្តែងក្នុងស្រុកទី៥*




តាមរយៈលទ្ធផលដែលបង្ហាញក្នុងក្រាបទី១១ របាយគ្រូបង្រៀនកម្រិតមូលដ្ឋាននៅតាមសាលានីមួយៗក្នុងស្រុកទី៥នេះ មិនទាន់ ត្រឹមត្រូវនៅឡើយទេ ពោលសាលាខ្លះខ្វះគ្រូច្រើន តែក៏មានសាលាខ្លះលើសគ្រូដែលមានឯកទេសដូចគ្នានេះផងដែរ។ តួយ៉ាងដូចជាមុខវិជ្ជាគណិតវិទ្យានៅក្នុងសាលាទី១នៃស្រុកនេះ តម្រូវការមាន០៣នាក់ ប៉ុន្តែគ្រូដែលមានគុណវុឌ្ឍិកម្រិតមូលដ្ឋានមាន០៥នាក់។ ផ្ទុយទៅវិញសម្រាប់មុខវិជ្ជាគណិតវិទ្យាដដែល សាលាទី៣មានតម្រូវការ០៣នាក់ ប៉ុន្តែគ្រូដែលមានគុណវុឌ្ឍិកម្រិតមូលដ្ឋាននៅក្នុងសាលានេះមានតែ០១នាក់ សាលាទី០៤ តម្រូវការមាន០៣នាក់ ប៉ុន្តែគ្រូមានតែ០១នាក់ សាលាទី០៥ តម្រូវការមាន០២នាក់ ប៉ុន្តែគ្រូមានតែ០១នាក់ និងសាលាទី០៧ តម្រូវការមាន០២នាក់ ប៉ុន្តែគ្រូដែលមានគុណវុឌ្ឍិកម្រិតមូលដ្ឋានមិនទាន់មានទេ។ រីឯសាលាក្រៅពីនេះគឺមានគ្រូមុខវិជ្ជាគណិតវិទ្យាគ្រប់គ្រាន់។ លទ្ធផលនេះបានបង្ហាញ ថាការបែងចែកគ្រូទៅតាម អនុវិទ្យាល័យនៅក្នុងស្រុកនេះ មិនទាន់គិតគូរបានត្រឹមត្រូវ និងមិនទាន់មានប្រសិទ្ធភាពនៅឡើយនោះទេ។

*ក្រាបទី១១៖ តម្រូវការគ្រូបង្រៀនមានគុណវុឌ្ឍិកម្រិតមូលដ្ឋានតាមមុខវិជ្ជានិងតាមអនុវិទ្យាល័យនីមួយៗក្នុងស្រុកទី៥*




## ៤.១.៨. ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិ ក្នុងស្រុកទី៦

ចំនួនអនុវិទ្យាល័យដែលមាននៅក្នុងស្រុកទី៦ មានចំនួន ១៤ មានសិស្សសរុបចំនួន ៣១៦៥ នាក់ត្រូវមានថ្នាក់សរុបគិតតាមនិយាមចំនួន ៧៩ ថ្នាក់ ស្មើនឹងម៉ោងបង្រៀនក្នុង១សប្តាហ៍ ២៥៣២ ម៉ោងដែលត្រូវប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋានចំនួន ១៤១ នាក់ដូចមានបង្ហាញក្នុងតារាងទី៨។ ប៉ុន្តែតាមស្ថានភាពជាក់ស្តែង ស្រុកនេះមានថ្នាក់ចំនួន ៨១ ថ្នាក់ លើសតាមនិយាមចំនួន០២ថ្នាក់ មានម៉ោងសិស្សរៀនជាក់ស្តែងក្នុង១សប្តាហ៍ចំនួន ២៥៩២ ម៉ោង លើសម៉ោងដែលត្រូវប្រើតាមនិយាម៦០ម៉ោង និងមានគ្រូបង្រៀនកម្រិតមូលដ្ឋាន ចំនួន១៣៩នាក់ តិចជាងគិតតាមនិយាមចំនួន០២នាក់។ លទ្ធផលនេះបង្ហាញឱ្យឃើញថា ការប្រើប្រាស់និយាមសិស្សថ្នាក់ និងការប្រើប្រាស់គ្រូ បើពិនិត្យមើលជារួមវិញគឺមានលក្ខណៈសមស្រប។ ប៉ុន្តែដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់ពីប្រសិទ្ធភាពនៃការប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋាននៅក្នុងស្រុកនេះ អ្នកស្រាវជ្រាវបានពិនិត្យទៅលើចំនួនគ្រូបង្រៀនកម្រិតមូលដ្ឋានលើមុខវិជ្ជាចំនួន១៣ ដូចក្នុងករណីនៃស្រុកខាងលើដែរហើយបានរកឃើញនូវលទ្ធផលដូចមានបង្ហាញ ក្នុងក្រាបទី១២។

*តារាងទី៨៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែងក្នុងស្រុកទី៦*

| ចំនួន | តាមជាក់ស្តែង | តាមនិយាម |
|---|---|---|
| សិស្ស | ៣១៦៥ នាក់ | |
| ថ្នាក់ | ៨១ ថ្នាក់ | ៧៩ ថ្នាក់ |
| ម៉ោង | ២៥៩២ ម៉ោង | ២៥៣២ ម៉ោង |
| គ្រូ | ១៤៤ នាក់ | ១៤១ នាក់ |
| គ្រូមានគុណវុឌ្ឍិក្របខណ្ឌ (ខ) | ១៣៩ នាក់ | |

ក្រាបទី១២ខាងក្រោមបង្ហាញពីតម្រូវការគ្រូ ដែលមានគុណវុឌ្ឍិកម្រិតមូលដ្ឋានគិតតាមនិយាម និងចំនួនគ្រូ ដែលមានជាក់ស្តែងលើមុខវិជ្ជាចំនួន ១៣ រួមមាន គណិតវិទ្យា ផែនដីវិទ្យា ភាសាបរទេស ភាសាខ្មែរ សីលធម៌-ពលរដ្ឋ គេហវិទ្យា ប្រវត្តិវិទ្យា ភូមិវិទ្យា អប់រំកាយ-កីឡា និងបំណិនជីវិតមូលដ្ឋាន។ តាមរយៈក្រាបនេះបង្ហាញឱ្យឃើញថា មុខវិជ្ជារូបវិទ្យា គីមីវិទ្យា ជីវវិទ្យា សីលធម៌-ពលរដ្ឋ គេហវិទ្យា និង ប្រវត្តិវិទ្យា គ្រូមានគុណវុឌ្ឍិកម្រិតមូលដ្ឋានលើសពីតម្រូវការ។ ចំណែកឯមុខវិជ្ជាគណិវិទ្យា ភាសាបរទេស ភាសាខ្មែរ ភូមិវិទ្យា អប់រំកាយ-កីឡា និងបំណិនជីវិតមូលដ្ឋាន មានគុណវុឌ្ឍិកម្រិតមូលដ្ឋានតិចជាងតម្រូវការទៅវិញ។ នេះស្តែងឱ្យឃើញថាប្រសិទ្ធភាពនៃការបែងចែក និងប្រើប្រាស់គ្រូនៅក្នុងស្រុកទី៦នៅតែមានបញ្ហា និងខ្វះខាតច្រើន។

*ក្រាបទី១២៖ គុណវុឌ្ឍិគ្រូបង្រៀនកម្រិតមូលដ្ឋាននៃមុខវិជ្ជានីមួយៗគិតតាមនិយាម និងតាមតម្រូវការជាក់ស្តែងក្នុងស្រុកទី៦*



ក្រាបទី១៣ខាងក្រោម តាមរយៈការពិនិត្យសាលានីមួយៗពីចំនួនគ្រូបង្រៀនតាមមុខវិជ្ជាទាំង ១៣ ក្នុងស្រុកទី៦ បានបង្ហាញឱ្យឃើញថា ការចាត់តាំងគ្រូបង្រៀនកម្រិតមូលដ្ឋានឱ្យទៅបម្រើការងារតាមសាលានីមួយៗ មិនទាន់មានលក្ខណៈល្អត្រឹមត្រូវនៅឡើយ ព្រោះមុខវិជ្ជាមួយចំនួន សាលាខ្លះមានគ្រូលើសចំនួន សាលាខ្លះមានគ្រូគ្រប់ចំនួន រីឯសាលាខ្លះទៀតបែរជាខ្វះគ្រូទៅវិញ។ តួយ៉ាងដូចជាមុខវិជ្ជាភាសាខ្មែរ តម្រូវការសម្រាប់សាលាទី៤ មានចំនួន០២នាក់ តែគ្រូបង្រៀនកម្រិតមូលដ្ឋានមានចំនួន ០៣នាក់ សាលាទី៦ តម្រូវការមានចំនួន០២នាក់ តែគ្រូបង្រៀនកម្រិតមូលដ្ឋានមានចំនួន ០៥នាក់ សាលាទី៨ និងទី៩ តម្រូវការមានចំនួន០២នាក់ តែគ្រូបង្រៀនកម្រិតមូលដ្ឋានមានចំនួន ០៣នាក់ ដូចគ្នា និងសាលាទី១០ តម្រូវការមានចំនួន០១នាក់ តែគ្រូបង្រៀនកម្រិតមូលដ្ឋានមានចំនួន ០២នាក់។ ផ្ទុយទៅវិញមុខវិជ្ជាភាសាខ្មែរដដែល សាលាទី២ តម្រូវការមាន០៤នាក់ ប៉ុន្តែគ្រូជាក់ស្តែងមិនទាន់មាន សាលាទី៥ តម្រូវការគ្រូមាន ០៣ នាក់ ប៉ុន្តែគ្រូបង្រៀនជាក់ស្តែងមានតែ០១នាក់ សាលាទី៧ តម្រូវការមាន ០២ នាក់ ប៉ុន្តែគ្រូមានតែ ០១ នាក់ សាលាទី១១ និងទី១៤ មានតម្រូវការគ្រូចំនួន ០១នាក់ ដូចគ្នា តែគ្រូបង្រៀន ជាក់ស្តែងដែលមានគុណវុឌ្ឍិកម្រិតមូលដ្ឋានឯកទេសនេះមិនទាន់មានទេ។ រីឯសាលាទី១ និងទី៣ គឺមានគ្រូបង្រៀនដែលមានគុណវុឌ្ឍិកម្រិតមូលដ្ឋានគ្រប់ចំនួន។ លទ្ធផលនេះបង្ហាញឱ្យឃើញថា ការបែងចែក និងការប្រើប្រាស់គ្រូបង្រៀន នៅតាមអនុវិទ្យាល័យនានានៅក្នុងស្រុកទី៦ នៅមិនទាន់មានលក្ខណៈល្អប្រសើរ ចំពោះមុខវិជ្ជាខ្លះ។

*ក្រាបទី១៣៖ តម្រូវការគ្រូបង្រៀនមានគុណវុឌ្ឍិកម្រិតមូលដ្ឋានតាមមុខវិជ្ជានិងតាមអនុវិទ្យាល័យនីមួយៗក្នុងស្រុកទី៦*



## ៤.១.៩. ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិ ក្នុងស្រុកទី៧

ចំនួនអនុវិទ្យាល័យដែលមាននៅក្នុងស្រុកទី៧ មានចំនួន ០៩ មានសិស្សសរុបចំនួន ៣២៦៤នាក់ ត្រូវមានថ្នាក់សរុបគិតតាមនិយាមចំនួន ៨២ ថ្នាក់ ស្មើនឹងម៉ោងបង្រៀនក្នុង១សប្តាហ៍ ២៦១១ ម៉ោង ដែលត្រូវប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋាន ចំនួន ១៥៤ នាក់ដូចមានបង្ហាញក្នុងតារាងទី៩។ តាមស្ថានភាពជាក់ ស្រុកនេះមានថ្នាក់ចំនួន ៨៣ថ្នាក់ លើសពីតាមនិយាមចំនួន០១ថ្នាក់ មានម៉ោងសិស្សរៀនជាក់ស្តែងក្នុង១សប្តាហ៍ចំនួន ២៦៥៦ ម៉ោង តិចជាងម៉ោងដែលត្រូវប្រើតាមនិយាម៤៥ម៉ោង និងមានគ្រូបង្រៀនកម្រិតមូលដ្ឋាន ចំនួន២៤៣នាក់ ច្រើនជាងគិតតាមនិយាមចំនួន ៩៨នាក់។ លទ្ធផលនេះបង្ហាញឱ្យឃើញថា ការប្រើប្រាស់និយាមសិស្សថ្នាក់ និងការប្រើប្រាស់គ្រូ បើពិនិត្យមើលជារួមវិញគឺមានលក្ខណៈសមស្រប ព្រោះគ្រូដែលកំពុងបង្រៀនជាក់ស្តែងមានចំនួន១៤៨ នាក់ ធៀបទៅនឹងគ្រូបង្រៀនកម្រិតមូលដ្ឋានតាមនិយាម ១៤៥ នាក់ ។

*តារាងទី៩៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែងក្នុងស្រុកទី៧*

| ចំនួន | តាមជាក់ស្តែង | តាមនិយាម |
|---|---|---|
| សិស្ស | ៣២៦៤ នាក់ | |
| ថ្នាក់ | ៨៣ ថ្នាក់ | ៨២ ថ្នាក់ |
| ម៉ោង | ២៦៥៦ ម៉ោង | ២៦១១ ម៉ោង |
| គ្រូ | ១៤៨ នាក់ | ១៤៥ នាក់ |
| គ្រូមានគុណវុឌ្ឍិក្របខណ្ឌ (ខ) | ២៤៣ នាក់ | |

ក្រាបទី១៤ខាងក្រោមបង្ហាញពី តម្រូវការគ្រូតាមនិយាម និងចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិតមូលដ្ឋានលើមុខវិជ្ជាចំនួនទាំង១៣ រួមមានគណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ផែនដីវិទ្យា ភាសាបរទេស ភាសាខ្មែរ សីលធម៌-ពលរដ្ឋ គេហវិទ្យា ប្រវត្តិវិទ្យា ភូមិវិទ្យា អប់រំកាយ-កីឡា និងបំណិនជីវិតមូលដ្ឋាន។ តាមរយៈក្រាបនេះបង្ហាញឱ្យឃើញថា មុខវិជ្ជាគណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ផែនដីវិទ្យា ភាសាបរទេស ភាសាខ្មែរ សីលធម៌-ពលរដ្ឋ គេហវិទ្យា ប្រវត្តិវិទ្យា ភូមិវិទ្យា អប់រំកាយ-កីឡា ចំនួនគ្រូដែលមានគុណវុឌ្ឍិ

កម្រិតមូលដ្ឋានលើសពីតម្រូវការ គណនាតាមនិយាម។ ដោយឡែកមានតែមុខវិជ្ជាបំណិនជីវិតមូលដ្ឋានមួយទេដែលមានគ្រូបង្រៀនមានគុណវុឌ្ឍិកម្រិតមូលដ្ឋានតិចជាងតម្រូវការ។ នេះស្តែងឱ្យឃើញថា ប្រសិទ្ធភាពនៃការបែងចែក និងប្រើប្រាស់គ្រូនៅក្នុងស្រុកទី៧នេះនៅមានកម្រិត។

*ក្រាបទី១៤៖ គុណវុឌ្ឍិគ្រូបង្រៀនកម្រិតមូលដ្ឋាននៃមុខវិជ្ជានីមួយៗគិតតាមនិយាម និងតាមតម្រូវការជាក់ស្តែងក្នុងស្រុកទី៧*




ការសិក្សានេះក៏បានពិនិត្យសាលានីមួយៗផងដែរ នូវចំនួនគ្រូបង្រៀនតាមមុខវិជ្ជាទាំង ១៣ មុខវិជ្ជាខាងលើ ដើម្បីធ្វើការប្រៀបធៀបចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិតមូលដ្ឋានធៀបទៅនឹងចំនួនតម្រូវការគ្រូគិតតាមនិយាម។ ជាលទ្ធផលបានបង្ហាញឱ្យឃើញថា មានសាលាខ្លះលើសគ្រូបង្រៀនកម្រិតមូលដ្ឋានលើមុខវិជ្ជាខ្លះ រីឯសាលាខ្លះទៀតខ្វះគ្រូបង្រៀនលើមុខវិជ្ជានោះ និងសាលាខ្លះមានគ្រូបង្រៀនគ្រប់ ចំនួន។ តួយ៉ាងដូចជាមុខវិជ្ជាគណិតវិទ្យានៅក្នុងសាលាទី១នៃស្រុកនេះ តម្រូវការមាន០៥នាក់ ប៉ុន្តែគ្រូដែលមានគុណវុឌ្ឍិកម្រិតមូលដ្ឋានមាន០៦នាក់។ សាលាទី២ តម្រូវការមាន០៥នាក់ គ្រូមាន១០នាក់ សាលាទី៤ តម្រូវការមាន០២នាក់ គ្រូមាន០៤នាក់ និងសាលាទី៥ តម្រូវការមាន០២នាក់ គ្រូមាន០៣នាក់ ។ ផ្ទុយទៅវិញ សម្រាប់មុខវិជ្ជាគណិតវិទ្យាដដែល សាលាទី៦មានតម្រូវការ០៣នាក់ ប៉ុន្តែគ្រូដែលមានគុណវុឌ្ឍិកម្រិតមូលដ្ឋាននៅក្នុងសាលានេះមានតែ ០២។ សាលាទី៦ តម្រូវការមាន០៣នាក់ គ្រូ

មានតែ០២នាក់ សាលាទី៧ តម្រូវការមាន០៣នាក់ គ្រូមានតែ០២នាក់ សាលាទី០៨ តម្រូវការមាន០៣ នាក់ប៉ុន្តែគ្រូមានតែ០១នាក់ និងសាលាទី៩តម្រូវការមាន០៣នាក់ គ្រូមានតែ០២នាក់ ដូចមានបង្ហាញក្នុង ក្រាបទី១៥។ លទ្ធផលនេះបានបង្ហាញឱ្យឃើញថាការបែងចែកគ្រូទៅតាមអនុវិទ្យាល័យនៅក្នុងស្រុកនេះ មិនទាន់គិតគូរបានត្រឹមត្រូវនោះទេ។ កត្តានេះបណ្តាលឱ្យការគ្រប់គ្រងរបស់នាយកសាលា អាចមិនមាន ប្រសិទ្ធភាព ឬអាចបណ្តាលឱ្យជះឥទ្ធិពលមិនល្អ ទៅដល់គុណភាពនៃការអប់រំ។

*ក្រាបទី១៥៖ តម្រូវការគ្រូបង្រៀនមានគុណវុឌ្ឍិកម្រិតមូលដ្ឋានតាមមុខវិជ្ជានិងតាមអនុវិទ្យាល័យ នីមួយៗក្នុងស្រុកទី៧*




### ៤.១.១០. ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិ ក្នុងស្រុកទី៨

ស្រុកទី៨ មានចំនួន ១១សាលា មានស្ថិតិសិស្សសរុបចំនួន ៤៧១៨នាក់។ តាមនិយាម ត្រូវមាន ថ្នាក់ចំនួន ១១៨ ថ្នាក់ ស្មើនឹងម៉ោងបង្រៀនក្នុង១សប្តាហ៍ ៣៧៧៤ ម៉ោង ដែលត្រូវប្រើប្រាស់គ្រូបង្រៀន កម្រិតមូលដ្ឋាន សម្រាប់គ្រប់មុខវិជ្ជាចំនួន ២១០ នាក់ដូចបង្ហាញក្នុងតារាងទី១០ខាងក្រោម។ ប៉ុន្តែតាម ស្ថានភាពជាក់ស្តែង ស្រុកនេះមានគ្រូបង្រៀនដែលមានគុណវុឌ្ឍិកម្រិតនេះ ត្រឹមតែ ១៨០ នាក់ ដែលតិច ជាងតម្រូវការចំនួន ៣០ នាក់ សម្រាប់ ទាំង១១សាលា។ បើពិនិត្យជាក់ស្តែងទៅលើអថេរទាំងបី៖ ចំនួន ថ្នាក់ ចំនួនម៉ោង និងចំនួនគ្រូបង្រៀនកម្រិតមូលដ្ឋាន ដែលស្រុកទី៨ កំពុងអនុវត្ត និងប្រើប្រាស់ឃើញថា

ថ្នាក់មានចំនួន ១១៣ ថ្នាក់ តិចជាងការគិតគួរតាមនិយាមចំនួន ០៥ថ្នាក់ ម៉ោងមានចំនួន ៣៦១៦ ម៉ោង ក្នុង១សប្តាហ៍ តិចជាងចំនួនម៉ោងគិតតាមនិយាម ចំនួន ១៥៨ ម៉ោង។ រីឯគ្រូបង្រៀនកម្រិតមូលដ្ឋាន ដែលកំពុងបង្រៀនមានចំនួន ១៨០នាក់ ពោលគឺនៅខ្វះចំនួនប្រមាណ ៣០ នាក់ និងតិចជាងតម្រូវការ ដែលកំពុងអនុវត្តជាក់ស្តែងចំនួន ២១ នាក់។ លទ្ធផលនេះបង្ហាញឱ្យឃើញថា ការប្រើប្រាស់និយាមសិស្ស ថ្នាក់គឺលើសពីនិយាមកំណត់ដោយច្បាប់ ធ្វើឱ្យចំនួនថ្នាក់រៀនថយចុះ និងចំនួនម៉ោងដែលត្រូវបង្រៀន និងរៀនជាក់ស្តែងក៏ថយចុះដែរ។ ចំណែកឯការប្រើប្រាស់គ្រូបង្រៀនវិញ នៅតែមានការប្រើប្រាស់គ្រូ បង្រៀន ដែលមានកម្រិតគុណវុឌ្ឍិទាបជាងកម្រិតមូលដ្ឋានរហូតទៅដល់ ២១នាក់។

*តារាងទី១០៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែងក្នុងស្រុកទី៨*

| ចំនួន | តាមជាក់ស្តែង | តាមនិយាម |
|---|---|---|
| សិស្ស | ៤៧១៨ នាក់ | |
| ថ្នាក់ | ១១៣ ថ្នាក់ | ១១៨ ថ្នាក់ |
| ម៉ោង | ៣៦១៦ ម៉ោង | ៣៧៧៤ ម៉ោង |
| គ្រូ | ២០១ នាក់ | ២១០ នាក់ |
| គ្រូមានគុណវុឌ្ឍិក្របខណ្ឌ (ខ) | ១៨០ នាក់ | |

ក្រាបទី១៦ខាងក្រោមបង្ហាញពី តម្រូវការគ្រូតាម និយាមនិងចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិត មូលដ្ឋានលើមុខវិជ្ជាចំនួន ១៣ រួមមានគណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ផែនដីវិទ្យា ភាសាបរទេស ភាសាខ្មែរ សីលធម៌-ពលរដ្ឋ គេហវិទ្យា ប្រវត្តិវិទ្យា ភូមិវិទ្យា អប់រំកាយ-កីឡា និងបំណិនជីវិតមូលដ្ឋាន សម្រាប់ស្រុកទី៨។ តាមរយៈក្រាបនេះបង្ហាញឱ្យឃើញថា មុខវិជ្ជារូបវិទ្យា ផែនដីវិទ្យា ប្រវត្តិវិទ្យា ចំនួនគ្រូ ដែលមានគុណវុឌ្ឍិកម្រិតមូលដ្ឋាន លើសពីតម្រូវការតាមនិយាម។ ផ្ទុយទៅវិញ មុខវិជ្ជាគណិតវិទ្យា ជីវវិទ្យា ភាសាបរទេស ភាសាខ្មែរ សីលធម៌-ពលរដ្ឋ គេហវិទ្យា ភូមិវិទ្យា អប់រំកាយ-កីឡា និងបំណិនជីវិតមូលដ្ឋាន ចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិតមូលដ្ឋាន តិចជាងតម្រូវការតាមនិយាម។ ដោយឡែកមុខវិជ្ជាគីមីវិទ្យា

មានគ្រូបង្រៀនកម្រិតនេះគ្រប់គ្រាន់តាមតម្រូវការ។ នេះស្តែងឱ្យឃើញថាប្រសិទ្ធភាពនៃការបែងចែក និងប្រើប្រាស់គ្រូនៅក្នុងស្រុកទី៨ នេះនៅមានកម្រិត ដែលបណ្តាលឱ្យការគ្រប់គ្រងរបស់នាយកសាលា អាចមិនមានប្រសិទ្ធភាព ឬអាចបណ្តាលឱ្យជះឥទ្ធិពលមិនល្អ ទៅដល់គុណភាពនៃការអប់រំ។

*ក្រាបទី១៦៖ គុណវុឌ្ឍិគ្រូបង្រៀនកម្រិតមូលដ្ឋាននៃមុខវិជ្ជានីមួយៗគិតតាមនិយាម និងតាមតម្រូវការជាក់ស្តែងក្នុងស្រុកទី៨*




ការសិក្សានេះក៏បានពិនិត្យសាលានីមួយៗផងដែរ នូវចំនួនគ្រូបង្រៀនតាមមុខវិជ្ជាទាំង ១៣មុខវិជ្ជាខាងលើ ដើម្បីធ្វើការប្រៀបធៀបចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិតមូលដ្ឋានធៀបទៅនឹងចំនួនតម្រូវការគ្រូគិតតាមនិយាមដូចមានបង្ហាញក្នុងក្រាបទី១៧។ ជាលទ្ធផលបានបង្ហាញឱ្យឃើញថា របាយគ្រូបង្រៀនកម្រិតមូលដ្ឋាននៅតាមសាលានីមួយៗក្នុងស្រុកទី៨នេះ មិនទាន់មានភាពត្រឹមត្រូវនៅឡើយទេ ពោលសាលាខ្លះខ្វះគ្រូច្រើន តែក៏មានសាលាខ្លះលើសគ្រូដែលមានឯកទេសដូចគ្នានេះផងដែរ។ តួយ៉ាងដូចជាមុខវិជ្ជាគណិតវិទ្យានៅក្នុងសាលាទី១នៃស្រុកនេះ តម្រូវការមាន០៦នាក់ ប៉ុន្តែគ្រូដែលមានគុណវុឌ្ឍិកម្រិតមូលដ្ឋានមាន០៧នាក់។ សាលាទី៦ តម្រូវការមាន០២នាក់ គ្រូមាន០៣នាក់។ ផ្ទុយទៅវិញ សម្រាប់មុខវិជ្ជាគណិតវិទ្យាដដែល សាលាទី២ មានតម្រូវការ០៤នាក់ ប៉ុន្តែគ្រូដែលមានគុណវុឌ្ឍិកម្រិតមូលដ្ឋាននៅក្នុងសាលានេះមានតែ០២នាក់ សាលាទី៣ តម្រូវការមាន០២នាក់ ប៉ុន្តែគ្រូមានតែ០១នាក់ សាលាទី៤

តម្រូវការមាន០៣នាក់ ប៉ុន្តែគ្រូមានពុំទាន់មានឯកទេសនេះនៅឡើយ សាលាទី៥ តម្រូវការមាន១០នាក់ ប៉ុន្តែគ្រូមានតែ០៩នាក់ សាលាទី៨ តម្រូវការមាន០៤នាក់ ប៉ុន្តែគ្រូមានតែ០២នាក់ សាលាទី៩ តម្រូវការមាន០២នាក់ ប៉ុន្តែគ្រូមានតែ០១នាក់ សាលាទី១០ តម្រូវការមាន០៣នាក់ ប៉ុន្តែគ្រូមានតែ០១នាក់ និង សាលាទី១១៨ តម្រូវការមាន០២នាក់ ប៉ុន្តែគ្រូមានតែ០១នាក់។ ដោយឡែកសាលាទី៧គឺមានគ្រូមុខវិជ្ជាគណិតវិទ្យាគ្រប់គ្រាន់។ លទ្ធផលនេះបានបង្ហាញ ថាការបែងចែកគ្រូទៅតាម អនុវិទ្យាល័យនៅក្នុងស្រុកនេះ មិនទាន់គិតគូរបានត្រឹមត្រូវនៅឡើយទេ។ កត្តានេះបណ្តាលឱ្យការគ្រប់គ្រងរបស់នាយកសាលាអាចមិនមានប្រសិទ្ធភាព ឬ អាច បណ្តាលឱ្យជះឥទ្ធិពលមិនល្អទៅដល់គុណភាពនៃការអប់រំ។

*ក្រាបទី១៧៖ តម្រូវការគ្រូបង្រៀនមានគុណវុឌ្ឍិកម្រិតមូលដ្ឋានតាមមុខវិជ្ជានិងតាមអនុវិទ្យាល័យនីមួយៗក្នុងស្រុកទី៨*




## ៤.១.១១. ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិ ក្នុងស្រុកទី៩

សំណាកដែលត្រូវបានជ្រើសរើសក្នុងស្រុកទី៩ មានចំនួន ១៦ សាលា មានស្ថិតិសិស្សសរុបចំនួន ៤៤១៥ នាក់ តាមនិយាមត្រូវមានថ្នាក់ចំនួន ១១០ ថ្នាក់ ស្មើនឹងម៉ោងបង្រៀនក្នុង១សប្តាហ៍ ៣៥៣២ ម៉ោង ដែលត្រូវប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋានចំនួន ១៩៦នាក់ដូចមានបង្ហាញក្នុងតារាងទី១១ខាង

ក្រោម។ ប៉ុន្តែតាមស្ថានភាពជាក់ស្តែង ស្រុកនេះមានថ្នាក់ចំនួន ៩៥ ថ្នាក់ តិចជាងនិយាមចំនួន ១៥ថ្នាក់ មានម៉ោងសិស្សរៀនជាក់ស្តែងក្នុង ១សប្តាហ៍ចំនួន ៣០៤០ ម៉ោង តិចជាងម៉ោងដែលត្រូវប្រើតាមនិយាម ចំនួន ៤៩២ ម៉ោង និងមានគ្រូបង្រៀនកម្រិតមូលដ្ឋានចំនួន ១៩០នាក់ តិចជាងនិយាមចំនួន ០៦នាក់។ រីឯការប្រើប្រាស់គ្រូបង្រៀនជាក់ស្តែង ដែលកំពុងអនុវត្តនៅក្នុងស្រុកនេះ គឺមាន ១៦៩នាក់ តិចជាងគ្រូបង្រៀនកម្រិតមូលដ្ឋាន ចំនួន ២១នាក់។ លទ្ធផលនេះបង្ហាញឱ្យឃើញថា ការប្រើប្រាស់និយាមសិស្សថ្នាក់ គឺលើសពីនិយាមកំណត់ដោយច្បាប់ ធ្វើឱ្យចំនួនថ្នាក់រៀន និងម៉ោងរៀនសរុបក្នុងមួយសប្តាហ៍ថយចុះ។ ចំណែកឯការប្រើប្រាស់គ្រូ បើពិនិត្យមើលជារួមវិញគឺមានលក្ខណៈសមស្រប ព្រោះគ្រូដែលកំពុងបង្រៀនជាក់ស្តែងមានចំនួន១៦៩នាក់ ធៀបទៅនឹងគ្រូបង្រៀនកម្រិតមូលដ្ឋាន ដែលស្រុកនេះមាន១៩០នាក់។

*តារាងទី១១៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែងក្នុងស្រុកទី៩*

| ចំនួន | តាមជាក់ស្តែង | តាមនិយាម |
|---|---|---|
| សិស្ស | ៤៤១៥ នាក់ | |
| ថ្នាក់ | ៩៥ ថ្នាក់ | ១១០ ថ្នាក់ |
| ម៉ោង | ៣០៤០ ម៉ោង | ៣៥៣២ ម៉ោង |
| គ្រូ | ១៦៩ នាក់ | ១៩៦ នាក់ |
| គ្រូមានគុណវុឌ្ឍិក្របខណ្ឌ (ខ) | ១៩០ នាក់ | |

ក្រាបទី១៨ ខាងក្រោមបង្ហាញពី តម្រូវការគ្រូតាមនិយាម និងចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិតមូលដ្ឋានលើមុខវិជ្ជាចំនួន ១៣ រួមមានគណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ផែនដីវិទ្យា ភាសាបរទេស ភាសាខ្មែរ សីលធម៌-ពលរដ្ឋ គេហវិទ្យា ប្រវត្តិវិទ្យា ភូមិវិទ្យា អប់រំកាយ-កីឡា និងបំណិនជីវិតមូលដ្ឋាន សម្រាប់ស្រុកទី៩។ តាមរយៈក្រាបនេះបង្ហាញឱ្យឃើញថា មុខវិជ្ជាគណិតវិទ្យា រូបវិទ្យា គីមីវិទ្យា សីលធម៌-ពលរដ្ឋ ភូមិវិទ្យា និងបំណិនជីវិតមូលដ្ឋាន ចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិតមូលដ្ឋាន តិចជាងតម្រូវការតាមនិយាម។ រីឯមុខវិជ្ជាជីវវិទ្យា ផែនដីវិទ្យា ភាសាបរទេស ភាសាខ្មែរ គេហវិទ្យា ប្រវត្តិវិទ្យា អប់រំកាយ-

កីឡា ចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិតមូលដ្ឋានលើសពីតម្រូវការតាមនិយាម។ នេះស្តែងឱ្យឃើញថា ប្រសិទ្ធភាពនៃការបែងចែក និងប្រើប្រាស់គ្រូនៅក្នុងស្រុកទី៩នេះនៅមានកម្រិត ដែលបណ្តាលឱ្យការគ្រប់គ្រងរបស់នាយកសាលា អាចមិនមានប្រសិទ្ធភាព ឬអាចបណ្តាលឱ្យជះឥទ្ធិពលមិនល្អ ទៅដល់គុណភាពនៃការអប់រំ។

*ក្រាបទី១៨៖ គុណវុឌ្ឍិគ្រូបង្រៀនកម្រិតមូលដ្ឋាននៃមុខវិជ្ជានីមួយៗគិតតាមនិយាម និងតាមតម្រូវការជាក់ស្តែងក្នុងស្រុកទី៩*




ការសិក្សានេះក៏បានពិនិត្យសាលានីមួយៗផងដែរ នូវចំនួនគ្រូបង្រៀនតាមមុខវិជ្ជាទាំង ១៣ មុខវិជ្ជាខាងលើ ដើម្បីធ្វើការប្រៀបធៀបចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិតមូលដ្ឋានធៀបទៅនឹងចំនួនតម្រូវការគ្រូគិតតាមនិយាមដូចបង្ហាញក្នុងក្រាបទី១៩។ ជាលទ្ធផលបានបង្ហាញឱ្យឃើញថា មានសាលាខ្លះលើសគ្រូបង្រៀនកម្រិតមូលដ្ឋានលើមុខវិជ្ជាខ្លះ រីឯសាលា ខ្លះទៀតខ្វះគ្រូបង្រៀនលើមុខវិជ្ជានោះ និងសាលាខ្លះមានគ្រូបង្រៀនគ្រប់ចំនួន។ តួយ៉ាងដូចជាមុខវិជ្ជាភាសាខ្មែរនៅក្នុងសាលាទី១នៃស្រុកនេះ តម្រូវការមាន០៥នាក់ ប៉ុន្តែគ្រូដែលមានគុណវុឌ្ឍិកម្រិតមូលដ្ឋានមាន០៨នាក់ សាលាទី៣ តម្រូវការមាន០៣នាក់ គ្រូមាន០៤នាក់ សាលាទី៤ តម្រូវការមាន០៤នាក់ គ្រូមាន០៩នាក់ សាលាទី៥ តម្រូវការមាន០៤នាក់ គ្រូមាន០៥នាក់ សាលាទី៧ តម្រូវការមាន០១នាក់ គ្រូមាន០២នាក់ និងសាលាទី១១ តម្រូវការមាន០២នាក់ គ្រូមាន០៣នាក់។ ផ្ទុយទៅវិញ សម្រាប់មុខវិជ្ជាភាសាខ្មែរដដែល សាលាទី២មានតម្រូវការ០៤

នាក់ ប៉ុន្តែគ្រូដែលមាន គុណវុឌ្ឍិកម្រិតមូលដ្ឋាននៅក្នុងសាលានេះមានតែ០៣នាក់ សាលាទី៦តម្រូវការមាន០២នាក់ គ្រូមាន០១នាក់ សាលាទី៨ តម្រូវការមាន០២នាក់ គ្រូមាន០១នាក់ សាលាទី១០ តម្រូវការមាន០១នាក់ គ្រូមានគុណវុឌ្ឍិកម្រិតមូលដ្ឋានមិនទាន់មាននៅឡើយ សាលាទី១២តម្រូវការមាន០២នាក់ គ្រូមាន០១នាក់ សាលាទី១៤ តម្រូវការមាន០១នាក់ គ្រូមានគុណវុឌ្ឍិកម្រិតមូលដ្ឋានមិនទាន់មាននៅឡើយ និងសាលាទី១៦ តម្រូវការមាន ០២ នាក់ តែគ្រូមានតែ ០១ នាក់។ ដោយឡែកចំពោះសាលាទី៩ ទី១៣ និងទី១៥ មានគ្រូបង្រៀនដែលមានគុណវុឌ្ឍិកម្រិតមូលដ្ឋានគ្រប់គ្រាន់។ លទ្ធផលនេះបានបង្ហាញឱ្យឃើញថា ការបែងចែកគ្រូទៅតាមអនុវិទ្យាល័យនៅក្នុងស្រុកនេះ មិនទាន់គិតគូរបានត្រឹមត្រូវនោះទេ។ កត្តានេះបណ្តាលឱ្យការគ្រប់គ្រងរបស់នាយកសាលា អាចមិនមានប្រសិទ្ធភាព ឬអាចបណ្តាលឱ្យជះឥទ្ធិពលមិនល្អ ទៅដល់គុណភាពនៃការអប់រំ។

*ក្រាបទី១៩៖ តម្រូវការគ្រូបង្រៀនមានគុណវុឌ្ឍិកម្រិតមូលដ្ឋានតាមមុខវិជ្ជានិងតាមអនុវិទ្យាល័យនីមួយៗក្នុងស្រុកទី៩*




### ៤.១.១២. ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិ ក្នុងស្រុកទី១០

ក្នុងស្រុកទី១០ មានចំនួន ១៤សាលា មានស្ថិតិសិស្សសរុបចំនួន ៥៩៩២ នាក់។ តាមនិយាម ត្រូវមានថ្នាក់ចំនួន ១៥០ ថ្នាក់ ស្មើនឹងម៉ោងបង្រៀនក្នុង១សប្តាហ៍ ៤៧៩៤ ម៉ោង ដែលត្រូវប្រើប្រាស់គ្រូ

បង្រៀនកម្រិតមូលដ្ឋាន សម្រាប់គ្រប់មុខវិជ្ជាចំនួន ២៦៦ នាក់ ដូចក្នុងតារាងទី១២ខាងក្រោម។ ប៉ុន្តែតាមស្ថានភាពជាក់ស្តែង ស្រុកនេះមានគ្រូបង្រៀនដែលមានគុណវុឌ្ឍិកម្រិតនេះ ត្រឹមតែចំនួន ២២៥ នាក់ ប៉ុណ្ណោះនៅខ្វះចំនួន ៤១នាក់សម្រាប់ទាំង ១៤សាលា។ បើពិនិត្យជាក់ស្តែងទៅលើអថេរទាំងបីៈ ចំនួនថ្នាក់ ចំនួនម៉ោង និងចំនួនគ្រូបង្រៀនកម្រិតមូលដ្ឋាន ដែលស្រុកទី១០ កំពុងអនុវត្ត និងប្រើប្រាស់ឃើញថា ថ្នាក់មានចំនួន ១៤៦ ថ្នាក់ តិចជាងការគិតគួរតាមនិយាមចំនួន ០៤ថ្នាក់ ម៉ោងមានចំនួន ៤៦៧២ ម៉ោង ក្នុង១សប្តាហ៍ តិចជាងចំនួនម៉ោងគិតតាមនិយាម ចំនួន ១២២ ម៉ោង។ រីឯគ្រូបង្រៀនកម្រិតមូលដ្ឋាន ដែលកំពុងបង្រៀនមានចំនួន ២២៥នាក់ ពោលគឺនៅខ្វះចំនួនប្រមាណ ៤១នាក់ និងតិចជាងតម្រូវការ ដែលកំពុងអនុវត្តជាក់ស្តែងចំនួន ៣៥ នាក់។ លទ្ធផលនេះបង្ហាញឱ្យឃើញថា ការប្រើប្រាស់និយាមសិស្សថ្នាក់គឺលើសពីនិយាមកំណត់ដោយច្បាប់ ធ្វើឱ្យចំនួនថ្នាក់រៀនថយចុះ និងចំនួនម៉ោងដែលត្រូវបង្រៀន និងរៀនជាក់ស្តែងក៏ថយចុះដែរ។ ចំណែកឯការប្រើប្រាស់គ្រូបង្រៀនវិញ នៅតែមានការប្រើប្រាស់គ្រូបង្រៀន ដែលខុសកម្រិតគុណវុឌ្ឍិកម្រិតមូលដ្ឋានរហូតទៅដល់ ៣៥នាក់មកបន្ថែម។

*តារាងទី១២៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែងក្នុងស្រុកទី១០*

| ចំនួន | តាមជាក់ស្តែង | តាមនិយាម |
|---|---|---|
| សិស្ស | ៥៩៩២ នាក់ | |
| ថ្នាក់ | ១៤៦ ថ្នាក់ | ១៥០ ថ្នាក់ |
| ម៉ោង | ៤៦៧២ ម៉ោង | ៤៧៩៤ ម៉ោង |
| គ្រូ | ២៦០ នាក់ | ២៦៦ នាក់ |
| គ្រូមានគុណវុឌ្ឍិក្របខណ្ឌ (ខ) | ២២៥ នាក់ | |

ក្រាបទី២០ខាងក្រោមបង្ហាញពី តម្រូវការគ្រូតាមនិយាមនិងចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិតមូលដ្ឋានលើមុខវិជ្ជាចំនួន ១៣ រួមមានគណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ផែនដីវិទ្យា ភាសាបរទេស ភាសាខ្មែរ សីលធម៌-ពលរដ្ឋ គេហវិទ្យា ប្រវត្តិវិទ្យា ភូមិវិទ្យា អប់រំកាយ-កីឡា និងបំណិនជីវិតមូលដ្ឋាន

សម្រាប់ស្រុកទី១០។ តាមរយៈក្រាបនេះបង្ហាញឱ្យឃើញថា មុខវិជ្ជាគណិតវិទ្យា ជីវវិទ្យា ភាសាបរទេស ភាសាខ្មែរ សីលធម៌-ពលរដ្ឋ អប់រំកាយ-កីឡា និងបំណិនជីវិតមូលដ្ឋាន ចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិតមូលដ្ឋាន តិចជាងតម្រូវការតាមនិយាម។ រីឯមុខវិជ្ជារូបវិទ្យា គីមីវិទ្យា ផែនដីវិទ្យា ភាសាបរទេស ភាសាខ្មែរ សីលធម៌-ពលរដ្ឋ គេហវិទ្យា ប្រវត្តិវិទ្យា ភូមិវិទ្យា ចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិតមូលដ្ឋាន លើសពីតម្រូវការតាមនិយាម។ នេះស្ដែងឱ្យឃើញថាប្រសិទ្ធភាពនៃការបែងចែក និងប្រើប្រាស់គ្រូនៅក្នុងស្រុកទី១០នេះនៅមានកម្រិត ដែលបណ្ដាលឱ្យការគ្រប់គ្រងរបស់នាយកសាលាអាចមិនមានប្រសិទ្ធភាព ឬអាចបណ្ដាលឱ្យជះឥទ្ធិពលមិនល្អ ទៅដល់គុណភាពនៃការអប់រំ។

*ក្រាបទី២០៖ គុណវុឌ្ឍិគ្រូបង្រៀនកម្រិតមូលដ្ឋាននៃមុខវិជ្ជានីមួយៗគិតតាមនិយាម និងតាមតម្រូវការជាក់ស្ដែងក្នុងស្រុកទី១០*




ការសិក្សានេះក៏បានពិនិត្យសាលានីមួយៗផងដែរ នូវចំនួនគ្រូបង្រៀនតាមមុខវិជ្ជាទាំង ១៣ មុខវិជ្ជាខាងលើ ដើម្បីធ្វើការប្រៀបធៀបចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិតមូលដ្ឋានធៀបទៅនឹងចំនួនតម្រូវការគ្រូគិតតាមនិយាម។ ជាលទ្ធផលបានបង្ហាញឱ្យឃើញថា មានសាលាខ្លះលើសគ្រូបង្រៀនកម្រិតមូលដ្ឋាន រីឯសាលាខ្លះទៀតបែរជាខ្វះគ្រូទៅវិញ ហើយក៏មានសាលាខ្លះមានគ្រូបង្រៀនគ្រប់ចំនួន។ តួយ៉ាងដូចជាមុខវិជ្ជាភាសាខ្មែរ សាលាទី៣ តម្រូវការគ្រូមានគុណវុឌ្ឍិកម្រិតមូលដ្ឋានមាន ០៦នាក់ ប៉ុន្តែ

គ្រូមានចំនួន ០៨នាក់ សាលាទី១២ តម្រូវការមានចំនួន ០១នាក់ តែគ្រូមានចំនួន ០២នាក់។ ផ្ទុយទៅវិញ សាលាទី១ ទី៦ ទី៧ ទី៩ ទី១៣ និងទី១៤ តម្រូវការគ្រូមាន០៩នាក់, ០៤នាក់, ០២នាក់, ០២នាក់, និង ០១នាក់ តាមលំដាប់រៀងគ្នា ប៉ុន្តែគ្រូដែលមានគុណវុឌ្ឍិកម្រិតមូលដ្ឋាន មានចំនួនតែ០៨នាក់, ០៣នាក់, ០៣នាក់, ០១នាក់, ០១នាក់, និង០០នាក់ តែប៉ុណ្ណោះ ដូចមានបង្ហាញក្នុងក្រាបទី២១។ រីឯសាលាទី២ ទី៤ ទី៥ ទី៨ ទី១០ និងទី១១ គឺមានគ្រូដែលមានគុណវុឌ្ឍិកម្រិតមូលដ្ឋានគ្រប់គ្រាន់ តាមនិយាមកំណត់ ។ លទ្ធផលនេះបានបង្ហាញឱ្យឃើញថាការបែងចែកគ្រូទៅតាមអនុវិទ្យាល័យនៅក្នុងស្រុកនេះ មិនទាន់គិតគូរបានត្រឹមត្រូវនោះទេ។ កត្តានេះបណ្តាលឱ្យការគ្រប់គ្រងរបស់នាយកសាលា អាចមិនមានប្រសិទ្ធភាព ឬអាចបណ្តាលឱ្យជះឥទ្ធិពលមិនល្អ ទៅដល់គុណភាពនៃការអប់រំ។

*ក្រាបទី២១៖ តម្រូវការគ្រូបង្រៀនមានគុណវុឌ្ឍិកម្រិតមូលដ្ឋានតាមមុខវិជ្ជានិងតាមអនុវិទ្យាល័យនីមួយៗក្នុងស្រុកទី១០*




## ៤.១.១២. ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិ ក្នុងស្រុកទី១១

សំណាកដែលត្រូវបានជ្រើសរើសក្នុងស្រុកទី១១ មានចំនួន ១០សាលា មានស្ថិតិសិស្សសរុបចំនួន ៤៧៧៦ នាក់ តាមនិយាមត្រូវមានថ្នាក់ចំនួន ១១៩ ថ្នាក់ ស្មើនឹងម៉ោងបង្រៀន ៣៨២១ ម៉ោងក្នុង១សប្តាហ៍ ដែលត្រូវប្រើប្រាស់គ្រូបង្រៀន កម្រិតមូលដ្ឋានចំនួន ២១២ នាក់ ដូចមានបង្ហាញក្នុងតារាងទី១៣

ខាងក្រោម។ ប៉ុន្តែតាមស្ថានភាពជាក់ស្តែង ស្រុកនេះមានថ្នាក់ចំនួន១១៥ថ្នាក់ តិចជាងតាមនិយាមចំនួន ០៤ថ្នាក់ មានម៉ោងសិស្សរៀនជាក់ស្តែងក្នុង១សប្តាហ៍ចំនួន ៣៦៨០ ម៉ោង តិចជាងម៉ោងដែលត្រូវប្រើតាមនិយាម ១៤១ម៉ោង និងមានគ្រូបង្រៀនកម្រិតមូលដ្ឋានចំនួន ៣៧៣ នាក់ លើសពីគិតតាមនិយាមចំនួន ១៦១នាក់។ លទ្ធផលនេះបង្ហាញឱ្យឃើញថា ការប្រើប្រាស់និយាមសិស្សថ្នាក់គឺលើសពីនិយាមកំណត់ដោយច្បាប់ ធ្វើឱ្យចំនួនថ្នាក់រៀន និងម៉ោងរៀនសរុបក្នុងមួយសប្តាហ៍ថយចុះ។ ចំណែកឯការប្រើប្រាស់គ្រូ បើពិនិត្យមើលជារួមវិញ គឺលើសពីតម្រូវការ ព្រោះគ្រូដែលកំពុងបង្រៀនជាក់ស្តែងគឺមានតម្រូវការតែ ២០២ នាក់ ធៀបទៅនឹងគ្រូបង្រៀនកម្រិតមូលដ្ឋាន ដែលស្រុកនេះមាន ៣៧៣ នាក់ ដូចបង្ហាញក្នុងតារាងទី១៣។ ប៉ុន្តែដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់ពីប្រសិទ្ធភាពនៃការប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋាន នៅក្នុងស្រុកនេះ អ្នកស្រាវជ្រាវបានពិនិត្យទៅលើចំនួនគ្រូបង្រៀនកម្រិតមូលដ្ឋានលើមុខវិជ្ជាចំនួន១៣ ដូចក្នុងករណីនៃស្រុកទាំងដប់ខាងលើដែរហើយបានរកឃើញនូវលទ្ធផលដូចមានបង្ហាញ ក្នុងក្រាបទី២២។

*តារាងទី១៣៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែងក្នុងស្រុកទី១១*

| ចំនួន | តាមជាក់ស្តែង | តាមនិយាម |
|---|---|---|
| សិស្ស | ៤៧៧៦ នាក់ | |
| ថ្នាក់ | ១១៥ ថ្នាក់ | ១១៩ ថ្នាក់ |
| ម៉ោង | ៣៦៨០ ម៉ោង | ៣៨២១ ម៉ោង |
| គ្រូ | ២០២ នាក់ | ២១២ នាក់ |
| គ្រូមានគុណវុឌ្ឍិក្របខណ្ឌ (ខ) | ៣៧៣ នាក់ | |

ក្រាបទី២២ខាងក្រោមបង្ហាញពី តម្រូវការគ្រូតាមនិយាម និងចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិតមូលដ្ឋានលើមុខវិជ្ជាចំនួនទាំង១៣ រួមមានគណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ផែនដីវិទ្យា ភាសាបរទេស ភាសាខ្មែរ សីលធម៌-ពលរដ្ឋ គេហវិទ្យា ប្រវត្តិវិទ្យា ភូមិវិទ្យា ព័ត៌មានវិទ្យា អប់រំកាយ-កីឡា អប់រំសិល្បៈ អប់រំសុខភាព និងបំណិនជីវិតមូលដ្ឋាន។ តាមរយៈក្រាបនេះបង្ហាញឱ្យឃើញថា គ្រប់មុខវិជ្ជាទាំងអស់ មានចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិតមូលដ្ឋានលើសពីតម្រូវការគណនាតាមនិយាម។ នេះស្តែងឱ្យឃើញថា គ្រូមិន

បានអនុវត្តម៉ោងបង្រៀនរបស់ខ្លួនបានគ្រប់តាមនិយាមកំណត់ដោយច្បាប់ ដែលនាំឱ្យប្រសិទ្ធភាពនៃការបែងចែក និងប្រើប្រាស់គ្រូនៅក្នុងស្រុកទី១១នេះនៅមានកម្រិត។

*ក្រាបទី២២៖ គុណវុឌ្ឍិគ្រូបង្រៀនកម្រិតមូលដ្ឋាននៃមុខវិជ្ជានីមួយៗគិតតាមនិយាម និងតាមតម្រូវការជាក់ស្តែងក្នុងស្រុកទី១១*




ការសិក្សាក៏បានពិនិត្យសាលានីមួយៗក្នុងស្រុកទី១១ នេះផងដែរ ពីចំនួនគ្រូបង្រៀនតាមមុខវិជ្ជាទាំង ១៣ ដូចក្នុងករណីនៃស្រុកទាំង១០ខាងលើ។ ជាលទ្ធផលបានបង្ហាញឱ្យឃើញថា ទោះបីជាមានការលើសគ្រូគ្រប់មុខវិជ្ជាយ៉ាងណាក៏ដោយ ក៏នៅតែមានសាលាខ្លះលើសគ្រូបង្រៀនកម្រិតមូលដ្ឋាន រីឯសាលាខ្លះទៀតបែរជាខ្វះគ្រូទៅវិញ ហើយក៏មានសាលាខ្លះមានគ្រូបង្រៀនគ្រប់ចំនួនដូចមានបង្ហាញក្នុងក្រាបទី២៣ខាងក្រោម។ តួយ៉ាងដូចជាមុខវិជ្ជាគណិតវិទ្យា តម្រូវការសម្រាប់សាលាទី១មានចំនួន០៤នាក់ តែគ្រូបង្រៀនកម្រិតមូលដ្ឋានមានចំនួន១៣នាក់ សាលាទី២មានតម្រូវការ១៥នាក់ គ្រូបង្រៀនកម្រិតមូលដ្ឋានមានចំនួន១៩នាក់ សាលាទី៧ មានតម្រូវការ០៣នាក់ គ្រូបង្រៀនកម្រិតមូលដ្ឋានមានចំនួន០៥នាក់ សាលាទី៨ មានតម្រូវការ០២នាក់ គ្រូបង្រៀនកម្រិតមូលដ្ឋានមានចំនួន០៦នាក់ និងសាលាទី៩ មានតម្រូវការ០១នាក់ គ្រូបង្រៀនកម្រិត មូលដ្ឋានមានចំនួន០២នាក់។ ផ្ទុយទៅវិញ ចំពោះមុខវិជ្ជាគណិតវិទ្យាដដែល សម្រាប់សាលាទី៣ តម្រូវការគ្រូមាន០៥ ប៉ុន្តែគ្រូដែលមានកម្រិតមូលដ្ឋាន មានចំនួនតែ០៣

សាលាទី៤ តម្រូវការគ្រូមាន០១ ប៉ុន្តែមិនមានគ្រូដែលមានកម្រិតមូលដ្ឋានទេ សាលាទី៥ តម្រូវការគ្រូមាន ០៣ ប៉ុន្តែគ្រូដែលមានកម្រិតមូលដ្ឋាន មានចំនួនតែ០២ និងសាលាទី៦ តម្រូវការគ្រូមាន០៣ ប៉ុន្តែគ្រូដែលមានកម្រិតមូលដ្ឋានមាន តែ០២។ ដោយឡែកសាលាទី១០ គឺមានគ្រូកម្រិតនេះគ្រប់ចំនួន ដូចមានបង្ហាញក្នុងក្រាបទី២៣។ លទ្ធផលនេះបានបង្ហាញឱ្យឃើញថាការបែងចែកគ្រូទៅតាមអនុវិទ្យាល័យនៅក្នុងស្រុកនេះ មិនទាន់គិតគូរបានត្រឹមត្រូវនោះទេ។ កត្តានេះបណ្តាលឱ្យការគ្រប់គ្រងរបស់នាយកសាលាអាចមិនមានប្រសិទ្ធភាព ឬអាចបណ្តាលឱ្យជះឥទ្ធិពលមិនល្អ ទៅដល់គុណភាពនៃការអប់រំ។

*ក្រាបទី២៣៖ តម្រូវការគ្រូបង្រៀនមានគុណវុឌ្ឍិកម្រិតមូលដ្ឋានតាមមុខវិជ្ជានិងតាមអនុវិទ្យាល័យនីមួយៗក្នុងស្រុកទី១១*




## ៤.២. ទស្សនៈរបស់នាយកលើការជ្រើសរើសគ្រូ

### ៤.២.១. ស្ថិតិចំនួនគ្រូទទួលបានតាមការស្នើសុំ ក្នុងរយៈពេល៥ឆ្នាំចុងក្រោយ

ក្រាបទី២៤ខាងក្រោមបង្ហាញពីស្ថិតិចំនួនគ្រូមធ្យមសិក្សាបឋមភូមិ ដែលទទួលបានតាមការស្នើសុំក្នុងរយៈពេល៥ឆ្នាំចុងក្រោយ។ គ្រូដែលទទួលបានតាមការស្នើសុំគ្រប់ចំនួនមានចំនួន ១០ភាគរយ គ្រូស្នើសុំហើយទទួលបានខ្លះមានចំនួន៦១ភាគរយ និងមិនទទួលបានតាមការស្នើសុំមានចំនួន ២៩ភាគរយ។

*ក្រាបទី២៤៖ ស្ថិតិចំនួនគ្រូទទួលបានតាមការស្នើសុំ ក្នុងរយៈពេល៥ឆ្នាំចុងក្រោយ*




**៤.២.២. បញ្ហាប្រឈម ក្នុងការកំណត់ពីចំនួនគ្រូបង្រៀននៅតាមអនុវិទ្យាល័យ**

បញ្ហាប្រឈមដែលបានជួបប្រទះក្នុងការកំណត់ពីចំនួនគ្រូនៅតាមអនុវិទ្យាល័យមានដូចជា៖

- ខ្វះគ្រូកម្រិតមូលដ្ឋាន
- ខ្វះគ្រូឯកទេសតាមមុខវិជ្ជា
- គ្រូបង្រៀនខុសឯកទេស និងខុសកម្រិត
- គ្រូមួយចំនួនគ្មានសមត្ថភាពបង្រៀន (គុណវុឌ្ឍិទាបជាង)

**៤.២.៣. ការផ្តល់សំណូមពរចំពោះក្រសួង ក្នុងករណីលើស និងខ្វះ គ្រូ**

ក្រាបទី២៥ខាងក្រោម បង្ហាញពីការផ្តល់សំណូមពររបស់នាយកសាលាទៅកាន់ក្រសួងអប់រំ យុវជន និងកីឡា ចំពោះករណីខ្វះគ្រូ។ តាមរយៈក្រាប បង្ហាញថាការសំណូមពរផ្តល់គ្រូថ្មីបន្ថែមមានចំនួនច្រើនជាងគេគឺ ៧៣ ភាគរយ ។ បន្ទាប់មកទៀតគឺ បង្កើនគុណវុឌ្ឍិគ្រូបង្រៀនបឋមសិក្សាទៅជាគ្រូអនុវិទ្យាល័យ មាន ៥៩ភាគរយ កែប្រែប្រព័ន្ធជ្រើសរើសគ្រូដោយយកចេញពីមូលដ្ឋាន ឬសហគមន៍ មាន៤០ ភាគរយ ផ្តល់ប្រាក់ម៉ោងបន្ថែមមាន ៣៦ ភាគរយ។ ចំណែកឯការបង្កើននិយាមបង្រៀនពី ១៨ ទៅ ២០ ម៉ោង និងផ្សេងៗ មានចំនួនប្រហាក់ប្រហែលគ្នាគឺ ៨ និង៧ ភាគរយ។

*ក្រាបទី២៥៖ ករណីខ្វះគ្រូ*




ក្រាបទី២៦ខាងក្រោម បង្ហាញពីការផ្តល់សំណូមពររបស់នាយកសាលាទៅកាន់ក្រសួងអប់រំ យុវជន និងកីឡា ចំពោះករណីលើសគ្រូ។ តាមរយៈក្រាបបង្ហាញថា ការផ្តល់លើកទឹកចិត្តបន្ថែមលើប្រាក់បៀវត្សន៍រៀងរាល់ខែ ចំពោះអ្នកស្ម័គ្រចិត្តពង្រាយមានចំនួនច្រើនជាងគេគឺ ៤៦ ភាគរយ។ បន្ទាប់មកទៀតគឺ ការលើកទឹកចិត្តដោយផ្តល់ឱកាសក្នុងការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈមាន ៤២ភាគរយ លើកទឹកចិត្តបង្កើនកាំប្រាក់មួយឆ្នាំម្តង ចំពោះអ្នកស្ម័គ្រចិត្តពង្រាយមាន ៣៤ ភាគរយ ប្រើគោលការណ៍ប្តូរវេនសាលាក្នុងស្រុករយៈពេល ៣ឆ្នាំម្តងមាន ២៥ ភាគរយ និងផ្សេងៗមានចំនួន ៥ភាគរយ។

*ក្រាបទី២៦៖ ករណីលើសគ្រូ*



# ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ

## ៥.១.សេចក្តីសន្និដ្ឋាន

យោងតាមលទ្ធផលស្រាវជ្រាវខាងលើ អ្នកស្រាវជ្រាវសូមសន្និដ្ឋានថាការប្រើប្រាស់គ្រូបង្រៀនក្នុងខេត្តកណ្តាលគឺមានលក្ខណៈសមស្របព្រោះគ្រូដែលកំពុងបង្រៀនជាក់ស្តែងមានចំនួន ២០៤១នាក់ ធៀបទៅនឹងគ្រូបង្រៀនកម្រិតមូលដ្ឋានដែលស្រុកនេះមាន ២៤១៧នាក់។ ប៉ុន្តែបើយើងពិនិត្យមើលទៅតាមសាលាវិញ មានមុខវិជ្ជាខ្លះលើស និងមុខវិជ្ជាផ្សេងទៀតខ្វះទៅវិញ ដែលជាហេតុធ្វើឱ្យការប្រើប្រាស់គ្រូបង្រៀនគឺមិនទាន់ស្របតាមនិយាមកំណត់នៅឡើយទេ។ ម្យ៉ាងវិញទៀត គ្រូកម្រិតមូលដ្ឋានដែលបង្រៀននៅវិទ្យាល័យ គឺមានចំនួនលើសពីតម្រូវការ ក្នុងកម្រិតបឋមភូមិ ខណៈពេលដែលអនុវិទ្យាល័យ ក្នុងស្រុកតែមួយកំពុងប្រឈមទៅនឹងការខ្វះគ្រូ។ កត្តាទាំងនេះអាស្រ័យមកពីបរិបទនៃសង្គមដែលអាចមានដូចជាទីតាំងរបស់សាលារៀន (ទីប្រជុំ តំបន់ជនបទ ឬតំបន់ដាច់ស្រយាល) ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ អគារសិក្សា បរិស្ថានសាលា ឬមកពីគុណភាពគ្រូបង្រៀន។ល។ ដែលនាំឲ្យមានការខ្វះ ឬលើសគ្រូសម្រាប់សាលាមួយចំនួន ការប្រើប្រាស់ធនធានគ្រូបង្រៀនមិនចំគោលដៅ ការបែងចែកធនធាន ឬការផ្តល់ឱ្យមិនមានតុល្យភាព រវាងសាលានៅទីប្រជុំជន និងជនបទ។

សរុបសេចក្តីមក ការបែងចែកភារកិច្ចរបស់គ្រូបង្រៀននៅតាមអនុវិទ្យាល័យនៅក្នុងខេត្តកណ្តាលមិនឆ្លើយតបតាមតម្រូការជាក់ស្តែង និងមិនទាន់មានភាពត្រឹមត្រូវតាមនិយាមទាំងស្រុងនៅឡើយទេ។ កត្តានេះធ្វើឱ្យកម្រិតទទួលបានការអប់រំរបស់សិស្សនៅមានកម្រិត ដែលជះឥទ្ធិពលអាក្រក់ដល់គុណភាពនៃការអប់រំនៅកម្ពុជា។

## ៥.២. សំណូមពរ

### ៥.២.១. ក្រសួងអប់រំ យុវជន និងកីឡា

- សូមជួយពង្រាយគ្រូកម្រិតមូលដ្ឋានឱ្យបានដល់កន្លែងខ្វះគ្រូជាពិសេសនៅតំបន់ជនបទដាច់ស្រយាល
- ប្រើគោលការណ៍ប្តូរវេននាយកសាលារៀងរាល់៥ឆ្នាំម្តងក្នុងក្របខណ្ឌថ្នាក់ស្រុក ឬខេត្ត

- គួរលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀនតាមរយៈការបើកវគ្គវិក្រិតការ ឬវគ្គបំប៉នសមត្ថភាពវិជ្ជាជីវៈដល់គ្រូខ្សោយ
- គួរបង្កើនកញ្ចប់ថវិកាដើម្បីឲ្យក្រុមអធិការកិច្ចខេត្តមានលទ្ធភាពចុះធ្វើអធិការកិច្ចឲ្យបានទៀងទាត់ និងដល់គ្រប់សាលារៀន។

**៥.២.២. មន្ទីរអប់រំ យុវជន និងកីឡាខេត្ត**

- សូមបន្តចាត់ចែង និងពង្រាយគ្រូឱ្យមានប្រសិទ្ធភាពតាមគោលការណ៍ស្ម័គ្រចិត្ត និងលើកទឹកចិត្តចំពោះគ្រូដែលស្ម័គ្រចិត្តទៅបម្រើការងារនៅតំបន់ឆ្ងាយពីលំនៅដ្ឋានខ្លួន ឬតំបន់ជួបការលំបាកដោយផ្តល់ប្រាក់ឧបត្ថម្ភបន្ថែម
- ប្តូរវេនគ្រូបង្រៀនក្នុងក្របខណ្ឌស្រុក ឬខេត្តរយៈពេល ៣ ឆ្នាំម្តង
- ពង្រាយគ្រូបង្រៀនទៅតាមគុណវុឌ្ឍិដើម្បីពង្រឹងគុណភាពអប់រំឱ្យកាន់តែប្រសើរឡើង។

**៥.២.៣. អ្នកសិក្សាស្រាវជ្រាវបន្ត**

ការសិក្សាស្រាវជ្រាវនេះ បានផ្តោតតែលើស្ថានភាពចំណុចខ្សោយ បញ្ហាប្រឈម ក្នុងការប្រើប្រាស់គ្រូបង្រៀននៅតាមអនុវិទ្យាល័យ ក្នុងខេត្តកណ្តាល និងផ្តោតតែនាយក/នាយិកាប៉ុណ្ណោះ ដែលធ្វើឱ្យព័ត៌មានដែលប្រមូលបានមិនទាន់ស៊ីជម្រៅនៅឡើយទេ។ អាស្រ័យហេតុនេះ ចំពោះអ្នកសិក្សាស្រាវជ្រាវបន្ត គួរផ្តោតលើស្ថានភាពក្នុងការគ្រប់គ្រងគ្រូបង្រៀនបន្ថែមទៀត និងជ្រើសរើសយកអ្នកចូលរួមច្រើនជាងនេះ មានដូចជា នាយករង នាយិការង ប្រធានក្រុមបច្ចេកទេស លោកគ្រូ អ្នកគ្រូ។

# ឯកសារយោង


ក្រសួងអប់រំ យុវជន និងកីឡា. (២០០៦). *កម្មវិធីសិក្សាគោលសម្រាប់អប់រំមូលដ្ឋានចំណេះទូទៅ1-12.* ភ្នំពេញ.

ក្រសួងអប់រំ យុវជន និងកីឡា. (២០១០). *ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន.* ភ្នំពេញ.

ក្រសួងអប់រំ យុវជន និងកីឡា. (២០១២). *គោលនយោបាយស្តីពីធនធានមនុស្សក្នុងវិស័យអប់រំ.* ភ្នំពេញ.

ក្រសួងអប់រំ យុវជន និងកីឡា. (២០១៥). *គោលនយោបាយស្តីពីគ្រូបង្រៀន-ផែនការសកម្មភាព.* ភ្នំពេញ.

ក្រសួងអប់រំ យុវជន និងកីឡា. (២០១៦). *ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេស.* ភ្នំពេញ.

ក្រសួងអប់រំ យុវជន និងកីឡា. (២០១៧). *ស្តង់ដានាយកសាលារៀន.* ភ្នំពេញ.

ក្រសួងអប់រំ យុវជន និងកីឡា. (២០១៨). *ក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន.* ភ្នំពេញ.

ក្រសួងអប់រំ យុវជន និងកីឡា. (២០១៨). *សេចក្តីណែនាំលេខ ២០ អយក.សណន.* ភ្នំពេញ.

ក្រសួងអប់រំ យុវជន និងកីឡា. (២០១៩). *ផែនទីបង្ហាញផ្លូវ ការអប់រំកម្ពុជា ឆ្នាំ២០៣០.* ភ្នំពេញ.

ក្រសួងអប់រំ យុវជន និងកីឡា. (២០១៩). *យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ២០១៩-២០២៣.* ភ្នំពេញ.

ក្រសួងអប់រំ យុវជន និងកីឡា. (២០១៩). *សេចក្តីណែនាំលេខ ៥៣ អយក.សណន.* ភ្នំពេញ.

បណ្ឌិត ហង់ ជួន ណារ៉ុន. (២០១៥). *សន្និបាតអប់រំ៖ចក្ខុវិស័យនាំកំណែទម្រង់វិស័យអប់រំនៅកម្ពុជា.* ភ្នំពេញ.

រាជរដ្ឋាភិបាល. (២០០៨). *អនុក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន.* ភ្នំពេញ.

វិទ្យាស្ថានជាតិអប់រំ. (២០១៩). *រដ្ឋបាលអប់រំ.* ភ្នំពេញ.

សម្តេចសង្ឃរាជ ជួន ណាត. (១៩៦៧). *វចនានុក្រមខ្មែរ.*

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ ក

### បញ្ជីឈ្មោះសាលាទាំង១៣៨ (ខេត្តកណ្តាល)

1- ស្រុកកណ្តាលស្ទឹង

| ឈ្មោះតំណាងក្នុងនិក្ខេបបទ | ឈ្មោះសាលាពិត |
|---|---|
| សាលាទី ១ | វិទ្យាល័យ ហស កំពង់កន្ទួត |
| សាលាទី ២ | វិទ្យាល័យ ព្រែកស្លែង |
| សាលាទី ៣ | វិទ្យាល័យ សកិបរហស ដើមឫស |
| សាលាទី ៤ | អនុវិ ថ្មី |
| សាលាទី ៥ | អនុវិ រលាំងកែន |
| សាលាទី ៦ | អនុវិ ទ្រា |
| សាលាទី ៧ | អនុវិ គោកត្រប់ |
| សាលាទី ៨ | អនុវិ គោករមៀត |
| សាលាទី ៩ | អនុវិ បឹងខ្យាង |
| សាលាទី ១០ | អនុវិ គោកចេះ |
| សាលាទី ១១ | អនុវិ សៀមរាប |
| សាលាទី ១២ | អនុវិ រកា |
| សាលាទី ១៣ | អនុវិ ព្រែករកា |
| សាលាទី ១៤ | អនុវិ ហស ដើមឫស |
| សាលាទី ១៥ | អនុវិ ត្បែង |
| សាលាទី ១៦ | អនុវិ ទួលសាលា |
| សាលាទី ១៧ | អនុវិ ព្រះពុទ្ធ |
| សាលាទី ១៨ | អនុវិ ត្រពាំងវែង |
| សាលាទី ១៩ | អនុវិ ជើងកើប |

2- ស្រុកកៀនស្វាយ

| ឈ្មោះតំណាងក្នុងនិក្ខេបបទ | ឈ្មោះសាលាពិត |
|---|---|
| សាលាទី ១ | វិទ្យាល័យ ជ័យវរ្ម័នទី៧ |

| | |
|---|---|
| សាលាទី ២ | វិទ្យាល័យ ហាស សិរីជីដុះ |
| សាលាទី ៣ | វិទ្យាល័យ សាន់នីវូ សំពោងធំ |
| សាលាទី ៤ | អនុវិ គគីរធំ |
| សាលាទី ៥ | អនុវិ គគីរ |
| សាលាទី ៦ | អនុវិ រទាំង |
| សាលាទី ៧ | អនុវិ បន្ទាយដែក |
| សាលាទី ៨ | អនុវិ ឬស្សីស្រុក |

3- ស្រុកខ្សាច់កណ្តាល

| ឈ្មោះតំណាងក្នុងនិក្ខេបបទ | ឈ្មោះសាលាពិត |
|---|---|
| សាលាទី ១ | វិទ្យាល័យ ហាស ខ្សាច់កណ្តាល |
| សាលាទី ២ | វិទ្យាល័យ ព្រែកលួង |
| សាលាទី ៣ | វិទ្យាល័យ ហាស បានដាវ |
| សាលាទី ៤ | អនុវិ បរហាស កោះចូរ៉ាម |
| សាលាទី ៥ | អនុវិ ព្រះសីហនុរាជ |
| សាលាទី ៦ | អនុវិ ពុកឬស្សី |
| សាលាទី ៧ | អនុវិ ហាស ជ័យធំ |
| សាលាទី ៨ | អនុវិ សន្លុង |
| សាលាទី ៩ | អនុវិ សាកាម៉ូតូទួលបាសាន |
| សាលាទី ១០ | អនុវិ វិហារសួគ៌ |
| សាលាទី ១១ | អនុវិ ព្រែកក្របៅ |
| សាលាទី ១២ | អនុវិ កោះឧកញ៉ាតី |
| សាលាទី ១៣ | អនុវិ ស្វាយជ្រុំ |
| សាលាទី ១៤ | អនុវិ ព្រែកតាកូវ |
| សាលាទី ១៥ | អនុវិ ស្វាយរមៀត |
| សាលាទី ១៦ | អនុវិ ហាស រកាជន្លឹង |
| សាលាទី ១៧ | អនុវិ តាឯក |
| សាលាទី ១៨ | អនុវិ ត្បូងដំរី |

4- ស្រុកកោះធំ

| ឈ្មោះតំណាងក្នុងនិក្ខេបបទ | ឈ្មោះសាលាពិត |
|---|---|
| សាលាទី ១ | វិទ្យាល័យ ហស កោះធំ |
| សាលាទី ២ | វិទ្យាល័យ បរហស ព្រែកតាដួង |
| សាលាទី ៣ | វិទ្យាល័យ ហស កំពង់កុង |
| សាលាទី ៤ | វិទ្យាល័យ ហស សំពៅពូន |
| សាលាទី ៥ | អនុវិ ហស ព្រែកស្ដី |
| សាលាទី ៦ | អនុវិ ឈើខ្មៅ |
| សាលាទី ៧ | អនុវិ វត្តជ្រោយ |
| សាលាទី ៨ | អនុវិ ពោធិបាន |
| សាលាទី ៩ | អនុវិ ជ្រោយតាកែវ |
| សាលាទី ១០ | អនុវិ សំប៉ាន |
| សាលាទី ១១ | អនុវិ ព្រែកជ្រៃ |
| សាលាទី ១២ | អនុវិ វត្តកោះធំ |

5- ស្រុកលើកដែក

| ឈ្មោះតំណាងក្នុងនិក្ខេបបទ | ឈ្មោះសាលាពិត |
|---|---|
| សាលាទី ១ | វិទ្យាល័យ ហស កំពង់ភ្នំ |
| សាលាទី ២ | វិទ្យាល័យ បរហស ពាមរាំង |
| សាលាទី ៣ | អនុវិ ហស សណ្ដារ |
| សាលាទី ៤ | អនុវិ ក្អមសំណ |
| សាលាទី ៥ | អនុវិ ព្រែកតូច |
| សាលាទី ៦ | អនុវិ ហស កំពង់ចំលង |
| សាលាទី ៧ | អនុវិ ខ្ពបអាទាវ |

6- ស្រុកល្វាឯម

| ឈ្មោះតំណាងក្នុងនិក្ខេបបទ | ឈ្មោះសាលាពិត |
|---|---|
| សាលាទី ១ | វិទ្យាល័យ ហស ទឹកឃ្លាំង |
| សាលាទី ២ | វិទ្យាល័យ ហស ពាមឧកញ៉ាអុង |
| សាលាទី ៣ | វិទ្យាល័យ ហស ល្វាស |

| | |
|---|---|
| សាលាទី ៤ | អនុវិ អរិយក្សត្រ |
| សាលាទី ៥ | អនុវិ កោះកែវ |
| សាលាទី ៦ | អនុវិ ព្រែកឬស្សីល្វាឯម |
| សាលាទី ៧ | អនុវិ ស្វាយអណ្តែត |
| សាលាទី ៨ | អនុវិ ព្រែកចារ |
| សាលាទី ៩ | អនុវិ ព្រែកគង់រាជ |
| សាលាទី ១០ | អនុវិ កោះរះ |
| សាលាទី ១១ | អនុវិ ផ្លូវត្រី |
| សាលាទី ១២ | អនុវិ បឹងគ្រំ |
| សាលាទី ១៣ | អនុវិ ភូមិធំ |
| សាលាទី ១៤ | អនុវិ ខ្នោការ |

7- ស្រុកមុខកំពូល

| ឈ្មោះតំណាងក្នុងនិក្ខេបបទ | ឈ្មោះសាលាពិត |
|---|---|
| សាលាទី ១ | វិទ្យាល័យ សធ.ជស ព្រែកអញ្ចាញ |
| សាលាទី ២ | វិទ្យាល័យ សិរីមង្គល |
| សាលាទី ៣ | អនុវិ ព្រែកដំបង |
| សាលាទី ៤ | អនុវិ ស្វាយអំពារ |
| សាលាទី ៥ | អនុវិ ហាស កំពង់ប្រាសាទ |
| សាលាទី ៦ | អនុវិ សអ.ហាស. ឬស្សីជ្រោយ |
| សាលាទី ៧ | អនុវិ មជ្ឈិមសរារាម |
| សាលាទី ៨ | អនុវិ ព្រែកឬស្ស |
| សាលាទី ៩ | អនុវិ វត្តចាស់ |

8- ស្រុកអង្គស្នួល

| ឈ្មោះតំណាងក្នុងនិក្ខេបបទ | ឈ្មោះសាលាពិត |
|---|---|
| សាលាទី ១ | វិទ្យាល័យ ហាស ត្រពាំងត្នោត |
| សាលាទី ២ | វិទ្យាល័យ ហាស ថ្នល់ទទឹង |
| សាលាទី ៣ | វិទ្យាល័យ ហាស អង្គពពាយ |

| | |
|---|---|
| សាលាទី ៤ | វិទ្យាល័យ ស.សង្ឃរាជ ប៊ួរ គ្រី |
| សាលាទី ៥ | អនុវិ បែកចាន |
| សាលាទី ៦ | អនុវិ ទាន់អរ |
| សាលាទី ៧ | អនុវិ ព្រៃពួច |
| សាលាទី ៨ | អនុវិ អង្គស្នួល |
| សាលាទី ៩ | អនុវិ ដំណាក់អំពិល |
| សាលាទី ១០ | អនុវិ សំរោងលើ |
| សាលាទី ១១ | អនុវិ ហាស ឆក់ឈើនាង |

9- ស្រុកពញាឮ

| ឈ្មោះតំណាងក្នុងនិក្ខេបបទ | ឈ្មោះសាលាពិត |
|---|---|
| សាលាទី ១ | វិទ្យាល័យ ទេពប្រណម្យ |
| សាលាទី ២ | វិទ្យាល័យ ហាស អូរកុង |
| សាលាទី ៣ | វិទ្យាល័យ ហាស ព្រះធម្មស្រះ |
| សាលាទី ៤ | វិទ្យាល័យ ហាស កោះចិន |
| សាលាទី ៥ | វិទ្យាល័យ សអ.ហាស ព្រែកតាទែន |
| សាលាទី ៦ | អនុវិ ហាស កំពង់ហ្លួង |
| សាលាទី ៧ | អនុវិ ទំនប់ធំ |
| សាលាទី ៨ | អនុវិ ហាន ភ្នំអដ្ឋវស្ស |
| សាលាទី ៩ | អនុវិ ពញាឮ |
| សាលាទី ១០ | អនុវិ សអ.ហាស ជ្រៃលាស់ |
| សាលាទី ១១ | អនុវិ ហាស កំពង់អុស |
| សាលាទី ១២ | អនុវិ ពាមល្វែក |
| សាលាទី ១៣ | អនុវិ ហាស តាពេទ្យ |
| សាលាទី ១៤ | អនុវិ ដំណាក់ត្រើង |
| សាលាទី ១៥ | អនុវិ ត្រពាំងរកា |
| សាលាទី ១៦ | អនុវិ ជ្រោយសំបួរ |

10-ស្រុកស្អាង

| ឈ្មោះតំណាងក្នុងនិក្ខេបបទ | ឈ្មោះសាលាពិត |
|---|---|
| សាលាទី ១ | វិទ្យាល័យ ហស ស្អាង |
| សាលាទី ២ | វិទ្យាល័យ សត.ហស ក្រាំងយ៉ូវ |
| សាលាទី ៣ | វិទ្យាល័យ សត.ហស ត្រើយស្លា |
| សាលាទី ៤ | វិទ្យាល័យ សត.ហស ព្រែកអំបិល |
| សាលាទី ៥ | អនុវិ ព្រះសីហនុវង្សេ |
| សាលាទី ៦ | អនុវិ ខ្ពប |
| សាលាទី ៧ | អនុវិ ស្អាងភ្នំ |
| សាលាទី ៨ | អនុវិ ឬស្សីជ្រើយ |
| សាលាទី ៩ | អនុវិ កោះខែល |
| សាលាទី ១០ | អនុវិ តាលន់ |
| សាលាទី ១១ | អនុវិ ហស ប្រាសាទ |
| សាលាទី ១២ | អនុវិ ហស វត្តពោធិ |
| សាលាទី ១៣ | អនុវិ អន្លង់តាសេក |
| សាលាទី ១៤ | អនុវិ កោះខ្សាច់ទន្លា |

11- ក្រុងតាខ្មៅ

| ឈ្មោះតំណាងក្នុងនិក្ខេបបទ | ឈ្មោះសាលាពិត |
|---|---|
| សាលាទី ១ | វិទ្យាល័យ ហស តាខ្មៅ |
| សាលាទី ២ | វិទ្យាល័យ ហស សេរីភាព |
| សាលាទី ៣ | វិទ្យាល័យ វឌ្ឍនៈឈូងលាភ |
| សាលាទី ៤ | អនុវិ កោះអន្លង់ចិន |
| សាលាទី ៥ | អនុវិ សិត្បូ |
| សាលាទី ៦ | អនុវិ ស្វាយរលំ |
| សាលាទី ៧ | អនុវិ.បរេន.ព្រែកហូរ |
| សាលាទី ៨ | អនុវិ ខ្ពបវែង |
| សាលាទី ៩ | អនុវិ ស្ទឹងជ្រៅ |
| សាលាទី ១០ | អនុវិ អនុវត្ត |

# ឧបសម្ព័ន្ធ ខ

## កម្រងសំណួរសម្រាប់សម្ភាសន៍នាយកសាលា

ប្រធានបទ៖ **ស្ថានភាព នៃការប្រើប្រាស់គ្រូបង្រៀននៅអនុវិទ្យាល័យក្នុងខេត្តកណ្ដាល**

**វត្ថុបំណងនៃការស្រាវជ្រាវ៖**

1. រកឱ្យឃើញពីស្ថានភាពចំណុចខ្សោយ បញ្ហាប្រឈម ក្នុងការប្រើប្រាស់គ្រូបង្រៀននៅតាមអនុវិទ្យាល័យ ក្នុងខេត្តកណ្ដាល។
2. រកឱ្យឃើញប្រសិទ្ធិភាពក្នុងការបែងចែកគ្រូបង្រៀន ។

*ការរក្សាការសម្ងាត់*

*ព័ត៌មានដែលទទួលបានពីលោក លោកស្រីសម្រាប់ការវិភាគពីការគ្រប់គ្រង និងប្រើប្រាស់គ្រូបង្រៀននៅកម្ពុជា នឹងត្រូវរក្សាការសម្ងាត់។ អត្តសញ្ញាណរបស់លោក លោកស្រីមិនត្រូវបានបង្ហាញក្នុងការស្រាវជ្រាវនេះទេ។*

- **ការកំណត់ពីតម្រូវការ**

1. តើសាលាបឋមសិក្សារបស់លោក~លោកស្រី មានទីតាំងស្ថិតក្នុងស្រុកណា ?
   - ក្នុងស្រុក.................................................
2. តើសាលាអនុវិទ្យាល័យ របស់លោក~លោកស្រី មានសិស្សចំនួនប៉ុន្មាននាក់ និងចំនួនថ្នាក់ប៉ុន្មាន ?
   - ថ្នាក់ទី៧៖ ចំនួនសិស្ស.......................នាក់ ចំនួនថ្នាក់៖..................ថ្នាក់
   - ថ្នាក់ទី៨៖ ចំនួនសិស្ស.......................នាក់ ចំនួនថ្នាក់៖..................ថ្នាក់
   - ថ្នាក់ទី៩៖ ចំនួនសិស្ស.......................នាក់ ចំនួនថ្នាក់៖..................ថ្នាក់
3. តើចំនួនបន្ទប់រៀនដែលសាលាមានជាក់ស្តែងចំនួនប៉ុន្មានបន្ទប់ ?
   - ចំនួនបន្ទប់រៀនសរុប..................បន្ទប់ ប្រើប្រាស់ជាក់ស្តែង..................បន្ទប់
4. តើគ្រូ ក្របខ័ណ្ឌដែលមានគុណវុឌ្ឍិ (ក្របខណ្ឌ ខ) បានបណ្តុះបណ្តាលចេញពី សាលាគរុកោសល្យ សរុបចំនួនប៉ុន្មាននាក់ ?

- ចំនួនសរុប.......................នាក់ ស្រី......................នាក់

5. តើគ្រូកំពុងបង្រៀនជាក់ស្តែង(មិនគិតមន្ត្រីការិយាល័យចំពោះរបបម៉ោងបន្ថែម)ចំនួនប៉ុន្មាននាក់ និងតាមមុខវិជ្ជានីមួយៗចំនួនប៉ុន្មាននាក់?(សូមជួយបំពេញតាមតារាងខាងក្រោមដែលផ្តល់ជូន)

   - ចំនួនគ្រូកំពុងបង្រៀនជាក់ស្តែង.....................នាក់ ស្រី.................នាក់

| ល.រ | មុខវិជ្ជាបង្រៀន | ចំនួនគ្រូកំពុងបង្រៀនជាក់ស្តែង | ស្រី |
|---|---|---|---|
| ១ | ភាសាខ្មែរ | | |
| ២ | ភាសាបរទេស | | |
| ៣ | គណិតវិទ្យា | | |
| ៤ | រូបវិទ្យា | | |
| ៥ | គីមីវិទ្យា | | |
| ៦ | ជីវវិទ្យា | | |
| ៧ | ផែនដីវិទ្យា | | |
| ៨ | ប្រវត្តិវិទ្យា | | |
| ៩ | ភូមិវិទ្យា | | |
| ១០ | សីលធម៌-ពលរដ្ឋ | | |
| ១១ | ICT | | |
| ១២ | អប់រំកាយនិងកីឡា | | |
| ១៣ | អប់រំសិល្បៈ | | |
| ១៤ | អប់រំសុខភាព | | |
| ១៥ | បំណិនជីវិតតាមមូលដ្ឋាន | | |
| សរុបចំនួន | | | |

6. តើក្នុងចំណោមមុខវិជ្ជាទាំងអស់ខាងលើ តើមុខវិជ្ជាណាខ្លះដែលមិនបានអនុវត្ត? បញ្ជាក់ពីមូលហេតុ។

..........................................................................................................................

..........................................................................................................................

.....................................................................................................................................

.....................................................................................................................................

7. បើមុខវិជ្ជាមិនបានអនុវត្ត តើម៉ោងមុខវិជ្ជាទាំងនោះយកទៅបញ្ចូលជាមួយមុខវិជ្ជាណា?

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

8. តើលោក លោកស្រី ដោះស្រាយបញ្ហាលើស ឬខ្វះគ្រូយ៉ាងដូចម្តេច?

- ករណីលើស.............................................................................................................

  .............................................................................................................................

- ករណីខ្វះ ...............................................................................................................

  .............................................................................................................................

- **ទស្សនៈរបស់នាយកលើការជ្រើសរើសគ្រូ**

1. តើអនុវិទ្យាល័យ របស់លោក~លោកស្រី បានទទួលចំនួនគ្រូតាមការស្នើសុំដែរ ឬទេរយៈពេល៥ ឆ្នាំចុងក្រោយនេះ?

ចំនួនគ្រូទទួលបានតាមការស្នើសុំគឺ៖

☐ គ្រប់ចំនួន ☐ ទទួលបានខ្លះ ☐ មិនទទួលបាន ☐ ផ្សេងៗ.................

2. តើលោក~លោកស្រី ជួបប្រទះបញ្ហាប្រឈមអ្វីខ្លះ ក្នុងការកំណត់ពីចំនួនគ្រូបង្រៀននៅតាមអនុវិទ្យាល័យ?

.............................................................................................................................

.............................................................................................................................

.............................................................................................................................

........................................................................................................................

3. តើលោក លោកស្រីផ្តល់សំណូមពរ ដូចម្តេចចំពោះក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណីលើស និងខ្វះគ្រូ?

**ករណីខ្វះ**

☐ ផ្តល់គ្រូថ្មីបន្ថែម

☐ ផ្តល់ប្រាក់ម៉ោងបន្ថែម

☐ បង្កើននិយាមម៉ោងបង្រៀន ពី១៨ ម៉ោង ទៅ ២០ម៉ោង

☐ កែប្រែប្រព័ន្ធជ្រើសរើសគ្រូដោយយកចេញពីមូលដ្ឋាន ឬសហគមន៍

☐ បង្កើនគុណវុឌ្ឍិគ្រូបង្រៀនកម្រិតបឋមសិក្សា ទៅជាគ្រូអនុវិទ្យាល័យ

☐ ផ្សេងៗ........................................................

**ករណីលើស**

☐ ប្រើគោលការណ៍ប្តូរវេនសាលា ក្នុងស្រុក រយៈពេល ៣ឆ្នាំម្តង

☐ ផ្តល់លើកទឹកចិត្តបន្ថែម លើប្រាក់បៀវត្សន៍រៀងរាល់ខែ ចំពោះអ្នកស្ម័គ្រចិត្តពង្រាយ

☐ លើកទឹកចិត្តបង្កើនកាំប្រាក់ មួយឆ្នាំម្តង ចំពោះអ្នកស្ម័គ្រចិត្តពង្រាយ

☐ លើកទឹកចិត្តដោយផ្តល់ឱកាសក្នុងការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ

☐ ផ្សេងៗ..................................................................

*សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោក លោកស្រី ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការចូលរួមឆ្លើយសំណួរទាំងនេះ។*

***សូមអរគុណ!***

# ឧបសម្ព័ន្ធ គ

# លិខិតជូនដំណឹង និងឧទ្ទេសនាម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ : ១៣៤ វជអ.ផក

ថ្ងៃ ពុធ ៩កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២០

**ជម្រាបជូន**
**លោក លោកស្រី ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត**

**កម្មវត្ថុ៖** ការចុះប្រមូលទិន្នន័យរបស់និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ ដើម្បីសរសេរនិក្ខេបបទបំពេញលក្ខខណ្ឌសិក្សាតាមមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត។

**យោង៖** ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ នៅវិទ្យាស្ថានជាតិអប់រំ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន លោក លោកស្រី ប្រធាន ជ្រាបថា៖ និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ សរុបចំនួន២៩នាក់ ស្រី០៧នាក់ ដែលកំពុងសិក្សានៅវិទ្យាស្ថានជាតិអប់រំត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យស្តីពី ការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិនៅតាមមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ចាប់ពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០តទៅ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម លោក លោកស្រី ប្រធាន ជួយសម្រួល និងសហការដល់ការចុះប្រមូលទិន្នន័យខាងលើតាមការគួរ។

សូម លោក លោកស្រី ប្រធាន ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុវណ្ណា

**ចម្លងជូន៖**
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
"ដើម្បីជ្រាបជាព័ត៌មាន"
-អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង អយក
"ដើម្បីជាព័ត៌មាន"
- មន្ទីរអយក រាជធានី ខេត្ត "ដើម្បីសហការ"
- សាមីជន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ
-ឯកសារ៖ វិទ្យាស្ថានជាតិអប់រំ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ: ១៣៤ វជអ. ន៨

# លិខិតឧទ្ទេសនាម

**យោង៖** ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ ឆ្នាំសិក្សា ២០១៩-២០២០។

និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ នៃវិទ្យាស្ថានជាតិអប់រំដូចមានរាយនាមខាងក្រោមត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យស្តីពីការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ នៅតាមមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ចាប់ពីថ្ងៃទី២៩ ខែមិថុនាឆ្នាំ ២០២០តទៅ៖

| ល.រ | គោត្តនាម-នាម | ភេទ | រាជធានី ខេត្ត |
|---|---|---|---|
| 1 | សុខ ផល្លី | ស | កណ្តាល |
| 2 | ទុន វណ្ណៈ | ប | កណ្តាល |
| 3 | វង់ ប៊ុនថាន | ប | កែប |
| 4 | គុយ សេងលី | ប | កំពង់ចាម |
| 5 | សំរ៉េត ពេជ្រតា | ស | កំពង់ចាម |
| 6 | ឈាង សោភា | ប | កំពង់ធំ |
| 7 | ពេជ្រ ចំរុង | ប | កំពង់ធំ |
| 8 | ប៊ុត សមពីសិទ្ធ | ប | កំពង់ស្ពឺ |
| 9 | លាង លីលី | ប | កំពង់ស្ពឺ |
| 10 | ជិន សុធី | ប | តាកែវ |
| 11 | មាន់ ម៉ៅ | ប | តាកែវ |
| 12 | មៀង ង៉ុន | ប | ត្បូងឃ្មុំ |
| 13 | យាន ពិសិដ្ឋ | ប | ត្បូងឃ្មុំ |
| 14 | ឆាន ឆាត | ប | បន្ទាយមានជ័យ |

| | | | |
|---|---|---|---|
| 15 | ឌី សុផល | ប | បន្ទាយមានជ័យ |
| 16 | ថាច់ សន | ប | ប៉ៃលិន |
| 17 | សុត សំអូន | ប | ពោធិ៍សាត់ |
| 18 | ហួន ស៊ីថា | ប | ពោធិ៍សាត់ |
| 19 | ប៊ិន សុផាន់ណាក់ | ប | ព្រៃវែង |
| 20 | រស់ សាយ៉ាន | ស | ព្រៃវែង |
| 21 | សូ ស៊ីណា | ប | ព្រះសីហនុ |
| 22 | កើត មាឃលក្ខិណា | ស | ភ្នំពេញ |
| 23 | សុន ឌីណា | ស | ភ្នំពេញ |
| 24 | ម៉ោញ វង្ថា | ស | មណ្ឌលគីរី |
| 25 | កែវ សុខជា | ប | ស្ទឹងត្រែង |
| 26 | វួច រី | ប | សៀមរាប |
| 27 | ខូ សុខា | ប | ស្វាយរៀង |
| 28 | អ៊ុក សម្ផស្ស | ស | ស្វាយរៀង |
| 29 | រីន សុធី | ប | ឧត្តរមានជ័យ |

ថ្ងៃ ៧ ៩ កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុវណ្ណា

**កន្លែងទទួលៈ**

-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"

-អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង អយក "ដើម្បីជាព័ត៌មាន"

- មន្ទីរអយក រាជធានី ខេត្ត "ដើម្បីសហការ"

- សាមីជន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ

-ឯកសារៈ វិទ្យាស្ថានជាតិអប់រំ

## ឧបសម្ព័ន្ធ ឃ

## លិខិតឧទ្ទេសនាមគ្រូដឹកនាំនិក្ខេបបទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ : ២៧៧ វជអ.ឥក

### លិខិតឧទ្ទេសនាម

**យោង៖** ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ ឆ្នាំសិក្សា ២០១៩-២០២០។

គណៈគ្រប់គ្រង និងគ្រូឧទ្ទេសនៃវិទ្យាស្ថានជាតិអប់រំដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងឱ្យដឹកនាំការសរសេរនិក្ខេបបទរបស់និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ស្តីពីការ **"ប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ"** នៅតាមរាជធានី ខេត្ត៖

| ល.រ | គ្រូដឹកនាំ | និស្សិត | ភេទ | ករណីសិក្សា |
|---|---|---|---|---|
| 1 | លោក លឹម វ៉ាន់ | សុខ ផល្លី | ស | កណ្តាល |
| 2 | លោក លឹម វ៉ាន់ | ទុន វណ្ណៈ | ប | កណ្តាល |
| 3 | លោក ឡុច ចាន់ថន | វង់ ប៊ុនថាន | ប | កែប |
| 4 | លោក ប៉ូ ប៊ុន្នន | គុយ សេងលី | ប | កំពង់ចាម |
| 5 | លោក ប៉ូ ប៊ុន្នន | សំរ៉េត ពេជ្រតា | ស | កំពង់ចាម |
| 6 | លោកបណ្ឌិត អាន វ៉ូប្រាវ | ឈាង សោភា | ប | កំពង់ធំ |
| 7 | លោកបណ្ឌិត អាន វ៉ូប្រាវ | ពេជ្រ ចំរុង | ប | កំពង់ធំ |
| 8 | លោកបណ្ឌិត គួយ សូគាន | ប៊ុត សមពីសិទ្ធ | ប | កំពង់ស្ពឺ |
| 9 | លោកបណ្ឌិត គួយ សូគាន | លាង លីលី | ប | កំពង់ស្ពឺ |
| 10 | លោក ម៉ន មុនិន្ទ | ជិន សុជី | ប | តាកែវ |

1

| | | | | |
|---|---|---|---|---|
| 11 | លោក ម៉ន មុនិន្ទ | មាន់ ម៉ៅ | ប | តាកែវ |
| 12 | លោកស្រី នូ ចន្ទី | មៀង ង៉ុន | ប | ត្បូងឃ្មុំ |
| 13 | លោកស្រី នូ ចន្ទី | យាន ពិសិដ្ឋ | ប | ត្បូងឃ្មុំ |
| 14 | លោកបណ្ឌិត នី វឌ្ឍា | ឆាន ឆាត | ប | បន្ទាយមានជ័យ |
| 15 | លោកបណ្ឌិត នី វឌ្ឍា | ឌី សុផល | ប | បន្ទាយមានជ័យ |
| 16 | លោកបណ្ឌិត នូវ វីរ៉ា | ថាច់ សន | ប | ប៉ៃលិន |
| 17 | លោកស្រី ខែក សំណាង | សុត សំអូន | ប | ពោធិ៍សាត់ |
| 18 | លោក លន លីណា | ហួន ស៊ីថា | ប | ពោធិ៍សាត់ |
| 19 | លោក ចាប រតនា | ប៊ិន សុផាន់ណាក់ | ប | ព្រៃវែង |
| 20 | លោក ចាប រតនា | រស់ សាយ៉ាន | ស | ព្រៃវែង |
| 21 | លោក សៀង វាសនា | សូ ស៊ីណា | ប | ព្រះសីហនុ |
| 22 | លោក ម៉ៅ សារឿន | កើត មាឃលក្ខិណា | ស | ភ្នំពេញ |
| 23 | លោក ម៉ៅ សារឿន | សុន ឌីណា | ស | ភ្នំពេញ |
| 24 | លោក សៀង វាសនា | ម៉ោញ វឌ្ឍា | ស | មណ្ឌលគីរី |
| 25 | លោកបណ្ឌិត នូវ វីរ៉ា | កែវ សុខជា | ប | ស្ទឹងត្រែង |
| 26 | ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា | វួច វី | ប | សៀមរាប |
| 27 | លោកបណ្ឌិត ឈាង សង្វាត | ខូ សុខា | ប | ស្វាយរៀង |
| 28 | លោកបណ្ឌិត ឈាង សង្វាត | អ៊ុក សម្ផស្ស | ស | ស្វាយរៀង |
| 29 | ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា | វីន សុធី | ប | ឧត្តរមានជ័យ |

ថ្ងៃ អង្គារ ១៣រោច ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២០

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុវណ្ណា

**កន្លែងទទួល៖**

-នាយក នាយករង នាយិការងវជអ "ដើម្បីជ្រាបជាព័ត៌មាន"

-ប្រធានដេប៉ាតឺម៉ង់-ការិយាល័យក្រោមឱវាទវជអ "ដើម្បីសហការ"

-សាមីជន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ

-ឯកសារ៖ ដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការវជអ